ឧបសម្ព័ន្ធ ១

# របាយការណ៍បូកសរុប
# ប្រចាំឆ្នាំ២០១៧



## អង្គការកែប្រែសហគមន៍

<u>ប្រភពមូលនិធិ:</u>

មាតិការ

I. អំពីអង្គការកែប្រែសហគមន៍
II. ពត៌មានគម្រោង
III. ពិពណ៌នាការរីកចម្រើនរបស់គម្រោង (ឧបសគ្គរាំងស្ទះនិងមេរៀន)
IV. របាយការណ៍ហិរញ្ញវត្ថុ
V. ផែនការទិសដៅការងារបន្ត

## I. អំពីអង្គការកែប្រែសហគមន៍

អង្គការកែប្រែសហគមន៍ Community Translation Organization, អក្សរកាត់ (CTO) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលត្រូវបានចុះបញ្ជីរនៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា លេខ ១៩៩៣ សជណ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៩។ ស្នាក់ការកណ្តាលរបស់អង្គការមានទីតាំងស្ថិតអាគារបុរីប្រឹមប្រិយ ផ្ទះលេខ សេ២៧ ផ្លូវ ក្ងម៉ែ ភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។ ដែលជាទីតាំងយុទ្ធសាស្រ្តមួយសម្រាប់សម្របសម្រួលកិច្ចការអភិវឌ្ឍន៍ សម្រាប់ខេត្តក្នុង ភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជាដូចជាខេត្ត សៀមរាប ព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង និងកំពង់ធំ។

អង្គការកែប្រែសហគមន៍ ធ្វើការងារដើម្បីកសាងមូលដ្ឋានគ្រឹះ សម្រាប់សហគមន៍ដែលអាស្រ័យផលនឹងរបរកសិកម្ម ដោយផ្តោតលើការងារកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ ការកសាងសមត្ថភាពក្រុមអង្គការកសិករ ដែលមានដូចជាក្រុមសន្សំប្រាក់ សហគមន៍កសិកម្ម សហគមន៍ព្រៃឈើ សហគមន៍ទេសចរធម្មជាតិ សហគមន៍ជម្រកត្រីមេ ពូជ និងជម្រុញការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ការអប់រំផ្សព្វផ្សាយដល់សហគមន៍ លើបញ្ហាបម្រែបម្រួលអាកាសធាតុ ការបន្សុំនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយគ្រោះភ័យធម្មជាតិ ដើម្បីឆ្ពោះទៅរកការកសាងសម្តភាពសហគមន៍ ដែលធន់ទ្រាំទៅនឹងបញ្ហាសង្គម និងសេដ្ឋកិច្ច។

អង្គការកែប្រែសហគមន៍ ធ្លាប់ជាកម្មវិធីមួយរបស់អង្គការ Human Translation ដែលជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយមានមូលដ្ឋាននៅសហរដ្ឋអាមេរិក (គេហទំព័រwww.humantranslation.org)។ ក្នុងឆ្នាំ២០០៩ តាមរយៈការកែទម្រង់អង្គការកែប្រែសហគមន៍ បានប្រែក្លាយមកជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យក្នុងស្រុកមួយ ដែលបានចុះបញ្ជីរទទួលស្គាល់ស្របច្បាប់ជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅក្រសួងមហាផ្ទៃ។

- <u>បាវចនា</u> ៖ ប្រែក្លាយចំណេះដឹងទៅជាសកម្មភាព
- <u>ទស្សនវិស័យ</u> ៖ កសិករអាចធ្វើកិច្ចការដើម្បីកែលំអរជីវភាព និងសេដ្ឋកិច្ចបានប្រសើរឡើង នៅពេលដែលពួកគាត់ទទួលបាននូវសម្ភារៈ ចំណេះដឹង ជំនាញ និងធនធានសមស្រប
- <u>បេសកកម្ម</u> ៖ ចូលរួមជាមួយសហគមន៍ ដើម្បីការត់បន្ថយភាពក្រីក្រ អភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការគាំទ្រ ហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ អេកូទេសចរណ៍ និងធ្វើអោយប្រសើរឡើងនូវការ ចិញ្ចឹមជីវិតដោយភាពថ្លៃថ្នូរនិងមានការការគោរពសិទ្ធិសេរីភាពពេញលេញ។

## ក្រុមប្រឹក្សាភិបាលរបស់អង្គការ

| ឈ្មោះ | ឋានៈ និង ស្ថាប័ន | អាស័យដ្ឋាន |
|---|---|---|
| Tobias Rose-Stockwell | ស្ថាបនិក<br>ប្រធានក្រុមប្រឹក្សាភិបាល | California, USD<br>E-mail: tobias@humantranslaionn.org |
| Jon Morgan | សមាជិកក្រុមប្រឹក្សាភិបាល<br>/ប្រធាន LAKECLINIC.org | សាលាកំរើក ក្រុងសៀមរាប<br>E-mail: jmorgan@lakeclinic.org |
| Kat Bun Heng | ស្ថាបនិក<br>សមាជិកក្រុមប្រឹក្សាភិបាល | សាលាកំរើក ក្រុងសៀមរាប<br>E-mail: kat.bunheng@gmail.com |
| Kristen Davies | សមាជិកក្រុមប្រឹក្សាភិបាល<br>ទីប្រឹក្សា GIZ ប្រចាំសៀមរាប | សាលាកំរើក ក្រុងសៀមរាប<br>E-mail : kdavies025@gmail.com |

## បុគ្គលិកលេខាធិការដ្ឋាន

| ល.រ | នាម និងគោត្តនាម | ឋានៈ និង ស្ថាប័ន | អាស័យដ្ឋាន | ទំនាក់ទំនង |
|---|---|---|---|---|
| ១ | លោក យិញ យ៉ា | នាយកប្រត្តិបត្តិ(ពេញម៉ោង) | សៀមរាប | ០១២៧០៧៨៧៨ |
| ២ | លោកស្រី សៀង សុធារី | ប្រធានគ្រប់គ្រងហិរញ្ញវត្ថុ(ពេញម៉ោង) | សៀមរាប | ០១២៨៥១៨៧៧ |
| ៣ | លោក ថៃ ពិសី | អ្នកសម្រួលសម្រួលកម្មវិធី(ពេញម៉ោង) | សៀមរាប | ០៩២៦២២១៨១ |
| ៤ | លោក ម៉យ រ៉ាមន | មន្ត្រីកម្មវិធី(ពេញម៉ោង) | សៀមរាប | ០៩២៧២៨១៩២ |
| ៥ | លោក សួន វាសនា | មន្ត្រីកម្មវិធី(ពេញម៉ោង) | សៀមរាប | ០៩២៥៥៣០១៣ |
| ៦ | លោក ស៊ាន ព្រំ | ប្រធានកម្មវិធី (ញម៉ោងពេ) | សៀមរាប | ០៨៥៥៥៨៨៩៥ |
| ៧ | លោក រិត បូ | ប្រធានសម្របសម្រួលខេត្ត(ពេញម៉ោង) | ឧត្តមានជ័យ | ០១២៣៥១៦៩៦ |
| ៨ | លោកស្រី ទេព សាម៉េត | មន្ត្រីកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៩២៥០២៦២០ |
| ៩ | លោក រ៉េម គឿត | មន្ត្រីជំនួយការកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៩៣២៨០១០១០ |
| ១០ | លោកស្រី លួម សុខណា | មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ(ពេញម៉ោង) | ឧត្តមានជ័យ | ០១២៧២៦៣៧៦ |
| ១១ | លោក កែវ ប្រាំង | មន្ត្រីកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០១៧៦០៥២២២ |
| ១២ | កញ្ញា សួន សោភា | មន្ត្រីកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៨៨៩៩១៨០៥០ |
| ១៣ | លោក សឿង វិបុល | មន្ត្រីគម្រោង(ក្រៅម៉ោង) | សៀមរាប | ០១២២៩៩៧១១ |
| ១៤ | លោក ជន ចំណាន | មន្ត្រីគម្រោង(ក្រៅម៉ោង) | សៀមរាប | ០១២៩៨០៨២៥ |
| ១៥ | លោក ស្រី ប៊ុន | មន្ត្រីគម្រោង(ក្រៅម៉ោង) | សៀមរាប | ០៩២៩៣២៨៣០ |
| ១៦ | កញ្ញា ទីវ សារិន្តែ | ជំនួយការរដ្ឋបាល(ពេញម៉ោង) | សៀមរាប | ០៩៩៧០១៣៧៣ |
| ១៧ | កញ្ញា ប៉ុក ស្រីល័ក្ខណ៍ | អ្នកស្ម័គ្រចិត្ត | សៀមរាប | ០៩១ ៦៩៩៩៨៩៨ |
| ១៨ | កញ្ញា ភាត ស្រីលិះ | អ្នកស្ម័គ្រចិត្ត | សៀមរាប | ០៨៨២៥៨៨០៥៩ |
| ១៩ | លោក រ៉េត តុន តាន | អ្នកស្ម័គ្រចិត្ត | សៀមរាប | ០៨៨២៦២៧៧២៧ |
| ២០ | Mr. Charles Vignal | អ្នកស្ម័គ្រចិត្ត | បារាំង | charles.vignal@gmail.com |
| ២១ | Ms. Lea Prous | អ្នកស្ម័គ្រចិត្ត | បារាំង | lea.proust.martin@hotmail.fr |
| ២២ | Mr. Mehdi Sondarjee | អ្នកស្ម័គ្រចិត្ត | បារាំង | mehdi.latreche@etu.univ-poitiers.fr |
| ២៣ | Ms.Marie Castengnier | អ្នកស្ម័គ្រចិត្ត | បារាំង | marie.castegnier@gmail.com |

## វិស័យផ្តោតការយកចិត្តទុកដាក់

| ប្រភេទនៃកម្មវិធី សកម្មភាព/គម្រោង/ | ទីកន្លែង | រយៈពេល | ដៃគូគម្រោង | ប្រភពថវិកា / ជំនួយ | ស្ថានភាព បញ្ចប់/បន្តកំពុងដំណើរការ) |
|---|---|---|---|---|---|
| សន្តិសុខស្បៀង ពង្រឹងសិទ្ធមូលដ្ឋាន អភិបាលកិច្ច អប់រំនិងយែនឌ័រ | សៀមរាប | ៣ឆ្នាំ | -ក្រុមប្រឹក្សឃុំ<br>-ការិយាល័យអប់រំស្រុក | Actionaid | បញ្ចប់ ០១មេសា២០១៦ |
| និយ័តកម្មព្រៃឈើ ទឹកស្អាតនិងអនាម័យ | ព្រះវិហារ | ៣ ឆ្នាំ | -សហគមន៍ព្រៃឈើ<br>-រដ្ឋបាលព្រៃឈើ | OXFAM GB | បញ្ចប់ ០៨សីហា២០១៥ |

| | | | | | |
|---|---|---|---|---|---|
| | | | -មន្ទីរអភិវឌ្ឍន៍ជនបទ | | |
| អេកូទេសចរណ៍ គ្រប់គ្រងធនធានធម្មជាតិបំរែបំរួលអាកាសធាតុការចិញ្ចឹមជីវិត | សៀមរាប | ២ ឆ្នាំ | ក្រុមប្រឹក្សឃុំ | UNDP SGP | បញ្ចប់ ៣០ធ្នូ២០១៣ |
| សេដ្ឋកិច្ចកសិកម្ម និងទីផ្សារ | សៀមរាប | ៧ឆ្នាំ | សហគមអភិវឌ្ឍកសិកម្ម | SIDA/ WEFFECT | បន្ត |
| សេដ្ឋកិច្ចកសិកម្ម និងទីផ្សារ | សៀមរាប | ៥ ឆ្នាំ | មន្ទីរកសិកម្ម | AusAID | បញ្ចប់ ០៦កក្កដា២០១៤ |
| សន្តិសុខស្បៀង ពង្រឹងសិទ្ធមូលដ្ឋាន អភិបាលកិច្ច អប់រំ និងយែនឌ័រ គ្រប់គ្រង់គ្រោះមហន្តរាយ | ឧត្តរមានជ័យ | ៧ឆ្នាំ | -បណ្តាញសហគន៍ព្រៃឈើ<br>-បណ្តាញគាំទ្រសហគមន៍ | Actionaid | បន្ត |
| គ្រប់គ្រងធនធានធម្មជាតិបំរែបំរួលអាកាសធាតុការចិញ្ចឹមជីវិត | សៀមរាប | ១.៨ ឆ្នាំ | ក្រុមប្រឹក្សឃុំ<br>ឧទ្យានជាតិ<br>រដ្ឋបាលស្រុក | UNDP SGP | កំពុងអនុវត្តន៍ |

## II. ពត៌មានគម្រោង

១.ខេត្តសៀមរាប មាន២គម្រោងដែលប្រភពថវិកាមកពីអង្គការWeEffect និង អង្គការ UNDP GEF SGP

គម្រោងទី១

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងជម្រុញភាពសកម្មនិងសេវាកម្មសហគមន៍កសិកម្មនៅខេត្តសៀមរាប |
| គោលដៅរួម | ចូលរួមកាត់បន្ថយភាពក្រីក្រប្រជាពលរដ្ឋតាមរយៈការពង្រឹងសេដ្ឋកិច្ចកសិករ និងសមត្ថ ភាពអង្គការសហគមន៍ |
| តំបន់គោលដៅ | -ខេត្តៈ សៀមរាប<br>-ស្រុកៈ ពួក ស្រុកបន្ទាយស្រី ស្រុកប្រាសាទបាគង ស្រុកសូត្រនិគមន៍<br>-ឃុំៈ កែវពណ៌ សំរោងយា ពួក ត្បែង ខ្វាស់ ត្រពាំងធំព្រះដាក់ រលួស កន្ទ្រាំង |
| ក្រុមគោលដៅ | សហគមន៍កសិកម្ម ១២ ក្រុមសន្សំ២៥ក្រុម សហភាពសហគមន៍កសិកម្ម១ យុវជនកំរិតអនុ វិទ្យាល័យ៣០០នាក់ |
| អ្នកទទួលផលផ្ទាល់ | ១៤៨៦គ្រួសារ |
| អ្នកទទួលផលប្រយោល | ៣០០០នាក់ ស្ត្រី ១៥៨៨នាក់ |

គម្រោងទី២

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងការពារ និងស្តារឡើងវិញនូវតំបន់ប្រព័ន្ធផ្តល់ទឹកជប់តំបន់ទេសភាពភ្នំគូលែន តាម រយៈការការពារ ការដាំដើមឈើឡើងវិញ និងក្សេត្របរិស្ថាន បែបច្នៃប្រឌិត ឆ្លាតវៃ តាមលក្ខ ខណ្ឌអាកាសធាតុ CSA កសិកម្មបែបអភិរក្ស CA ដោយសហគមន៍ |
| គោលដៅរួម | ធ្វើអោយ “តំបន់ខ្ពង់រាបស្នូលលើខ្នងភ្នំគូលែនដែលរិចរិល ឈានទៅរកការអន្តរាយ មានផ្ទៃដីចំនួន១៩៩ហិចតា ត្រូវបានការពារ និងស្តារឡើងវិញនូវមុខងារនៃតំបន់ ប្រព័ន្ធក្បាលទឹកជប់ចំបងៗ និងប្រជាសហ គមន៍ចំនួន១០០គ្រួសារ មកពីភូមិចំនួន៦ យ៉ាងតិច ក្នុងចំណោមភូមិគោលដៅសរុបចំនួន៨ភូមិ នៃឃុំ ខ្នងភ្នំដែលរងផលប៉ះពាល់ |

| | |
|---|---|
| | ពីគម្រោងមានកើនឡើងជីវភាព ២៥%ធៀបនឹងពេលមុន តាមរយៈការអនុវត្ត កសិកម្មត្រ បរិស្ថានបែបឆ្នៃប្រឌិត ឆ្លាតវៃតាមលក្ខ័ណ្ឌអាកាសធាតុ សំរាប់និរន្តរភាពនៃបរិស្ថាន តំបន់ឧទ្យាន ជាតិភ្នំគូលែនហើយបន្តផ្សព្វផ្សាយ ចែករំលែកចំណេះដឹងបទពិសោធន៍ ទៅដល់ប្រជាជនផ្សេងនៅក្នុងឃុំដើម្បីអោយមានស្ថេរភាពប្រាក់ចំណូល។ |
| តំបន់គោលដៅ | -ខេត្តៈ សៀមរាប<br>-ស្រុកៈ ស្វាយលើ<br>-ឃុំៈ ខ្នងភ្នំ |
| ក្រុមគោលដៅ | (១)-ប្រជាពលរដ្ឋមូលដ្ឋាន និងប្រជាសហគមន៍ចំនួន ៨០០គ្រួសារ ក្នុងនោះស្រី ៥០% មកពី ៨ភូមិ ដែល កំពុងរស់នៅជុំវិញតំបន់ក្បាលទឹកជប់លើខ្នងភ្នំគូលែន<br>(២)-និងក្រុមជនគោលដៅ ផ្សេងទៀតមានដូចជាគណៈកម្មការ គ្រប់គ្រងប្រើប្រាស់ទឹក គណៈ កម្មការសហគមន៍គ្រប់គ្រងព្រៃការពារនៅក្នុងឃុំខ្នងភ្នំ និងមន្ត្រីឧទ្យានុរក្សដែល ជាបុគ្គលឹក ប្រចាំ ការនៅលើខ្នងភ្នំ។ ហើយក្រុមគោលដៅមិនផ្ទាល់ផ្សេងទៀតនោះគឺ ក្រុមប្រជាពលរដ្ឋដែលកំពុង ប្រកបមុខរបរលក់ដូររកស៊ីនៅក្បែរទឹកជ្រោះភ្នំគូលែន ដែលអាចទទួលបានផលប្រយោជន៍នៅ ពេលដែលមាននិរន្តរភាពលំហូរទឹក ដូច្នេះ ពួកគាត់ត្រូវដាក់បញ្ចូលក្នុងប្រព័ន្ធនៃ សកម្មភាពយូរ អង្វែងទៅមុខ។ |
| អ្នកទទួលផលផ្ទាល់ | ៣៥០គ្រួសារ |
| អ្នកទទួលផលប្រយោល | ១៥៧៥នាក់ ស្រី៨៥៥នាក់ |

<u>២.ខេត្តឧត្តរមានជ័យ</u> មានគម្រោងមេ១ដែលប្រភពថវិកាមកពី actionaid ហើយនិងអនុគម្រោង២ដែលប្រភពថវិកា អនុគម្រោងទិ១មកពី Tavola ប្រទេសអុីតាលី និងអនុគម្រោងទី២មកពីសហគមន៍អុឺរុបតាមរយៈ actionaid Cambodia

<u>គម្រោងមេ</u>

| | |
|---|---|
| ឈ្មោះគម្រោង | កម្មវិធីសិទ្ធិមូលដ្ឋាន (LRP) |
| គោលដៅរួម | កសិករនិងកុមារក្រីក្រនៅក្នុងតំបន់គោលដៅរបស់គម្រោងនឹងទទួលបាននូវសន្តិសុខ ស្បៀង និងឱកាសទទួលបានការសិក្សាប្រសើរជាងមុន ដោយពួកគេមាន លទ្ធភាព ទទួលបាននូវសិទ្ធិជាមូលដ្ឋាន ហើយអនុវត្តសិទ្ធិទាំងនោះតាមផ្លូវច្បាប់ ដើម្បីរស់នៅ ប្រកបដោយភាពថ្លៃថ្នូរនៅ ក្នុងសង្គម។ |
| តំបន់គោលដៅ | -ខេត្តៈ ឧត្តរមានជ័យ<br>-ស្រុកៈ សំរោង បន្ទាយអំពិល ចុងកាល់ អន្លង់វែង<br>-ឃុំៈ សំរោង បន្សាយរាក់ កូនក្រៀល គោកខ្ពស់ ពង្រ លំទង |
| ក្រុមគោលដៅ | សហគមន៍ព្រៃឈើ ៤ ក្រុមសន្សំ៨ក្រុម បណ្ដាញសហគមន៍ព្រៃឈើខេត្ត១ ក្រុមជង្រុកស្រូវ ៨សាលាបឋមសិក្សា២០ |
| អ្នកទទួលផលផ្ទាល់ | ១៨៦៣គ្រួសារ |
| អ្នកទទួលផលប្រយោល | ៩៣៣៨នាក់ ស្រី៤៧៥០នាក់ ក្នុងនោះកុមារសរុប៣២៦៨នាក់ |

<u>អនុគម្រោងទី១(Tavola)</u>

| | |
|---|---|
| ឈ្មោះគម្រោង | ពង្រឹងគុណភាពអប់រំតាមរយៈការលើកកំពស់សិទ្ធិកុមារក្នុងសាលាហើយនិងការចូលរួមសកម្ម ភាពផ្តួចផ្តើមក្លឹបកុមាររីករាយ (IQE_PRS_CACI) |
| រយៈពេល | មិនា ២០១៧ ដល់ កុម្ភៈ ២០១៨ |

| អ្នកទទួលផល | សរុប | ស្ត្រី |
|---|---|---|
| ផ្ទាល់ | 343 | 201 |
| ប្រយោល | 1,510 | 713 |
| សរុបរួម | 1,853 | 914 |

អនុគម្រោងទី២(EUL)

| | |
|---|---|
| ឈ្មោះគម្រោង | ពង្រឹងសមត្ថភាពអង្គការសហគមន៍ និងសហគមន៍ងាយរងគ្រោះ ដើម្បីលើកកម្ពស់សុវត្ថិភាពក្នុងការកាន់កាប់ដី ជលផល និងព្រៃឈើ និងជីវភាពរស់នៅរបស់ពលរដ្ឋក្រីក្រ |
| រយៈពេល | ចាប់ពីខែកក្កដា ឆ្នាំ ២០១៧ រហូតដល់ខែធ្នូ ឆ្នាំ២០១៨ |
| ទីតាំងគម្រោង | ភូមិ ស្រះកែវ ឃុំពង្រ ស្រុកចុងកាល់។ ភូមិបាក់នឹម សង្កាត់សំរោង ក្រុងសំរោង។ ភូមិគោកសំព័រ ឃុំ លំទង ស្រុកអន្លង់វែង។ ភូមិទំនប់ថ្មីឃុំត្រពាំងតាវ ស្រុកអន្លង់វែង ឧត្តរមានជ័យ។ |
| អ្នកទទួលផល | 574 គ្រួសារ |

**ពិពណ៌នាការរីកចម្រើនរបស់គម្រោង**

**១.ខេត្តសៀមរាប**

*គម្រោងទី១*

**វិភាគលទ្ធផល**

ដោយមានកំលាំងសេដ្ឋកិច្ចពីវិស័យទេសចរ ខេត្តសៀមរាបបានក្លាយទៅជាទីផ្សារដ៏ធំ ដើម្បីស្រូបយកផលិតផលកសិកម្ម។ ដែលបង្កើតជាឱកាសដ៏មានសក្តានុពលសម្រាប់កសិករក្នុងខេត្ត ជាពិសេសជាងគេគឺអ្នករស់នៅតាមស្រុកដែលនៅជុំវិញក្រុងសៀមរាបតែម្តង។ យើងសង្កេតឃើញថា យើងអាចជួយ យើងអាចជួយកសិករដើម្បីកែលំអរស្ថានភាពជីវភាពតាមរយៈ *ការកាត់បន្ថយភាពក្រីក្រ ដោយធ្វើការកសាងសមត្ថភាពសេដ្ឋកិច្ចកសិករ និងអង្គការសហគមន៍* ។ ក្នុងគម្រោងនេះវាអាចជួយគាំទ្រដោយផ្ទាល់ដល់សហគមន៍កសិកម្មចំនួន១២ ក្នុងការអភិវឌ្ឍសេវាកម្ម និងអភិបាលកិច្ចស្ថាប័នរបស់ពួកគាត់។ ម្យ៉ាងវិញទៀត តាមទិន្នន័យគោលក្នុងឆ្នាំ២០១៣ យើងរកឃើញថាមានសហគមន៍កសិម្មតែ១៨គត់ដែលបានចុះបញ្ជីរនៅក្នុងខេត្តសៀមរាប។ ប៉ុន្តែរហូតមកដល់បច្ចុប្បន្នចំនួនសហគមន៍កសិកម្មបានកើនដល់៤៥ហើយទូទាំងខេត្ត។ នេះជាលទ្ធផលដែលនឹកស្មានមិនដល់ ដែលវាពិតជាបានចូលរួមឆ្លើយតបទៅនឹងគោលបំណងគម្រោងគឺ *ជម្រុញចលនា និងសេវាកម្មសហគមន៍កសិកម្មក្នុងខេត្តសៀមរាប*។ ដូច្នេះសម្រាប់ពេលអនាគត់ យើងនឹងមានអង្គការសហគមន៍កាន់តែច្រើនចូលរួមក្នុងសកម្មភាពអភិវឌ្ឍនៅជនបទ។

សរុបមក គម្រោងគឺស្ថិតក្នុងទំរង់នៃការអភិវឌ្ឍសហគមន៍ ដែលអ្នកទទួលផលគម្រោងកំពុងរស់នៅក្នុងសហគមន៍ជាអ្នកដែលប្រកបរបរបង្កបង្កើនផលនៃខេត្តសៀមរាប។ ដើម្បីសម្រេចបាននូវគោលបំណងគម្រោង សម្រាប់ឆ្នាំ ២០១៥ ដល់ ២០១៧ អង្គការកែប្រែសហគមន៍ និងអង្គការវីអេហ្វិក បានព្រមព្រៀងបន្តទៅពង្រីកវិសាលភាពអោយកាន់តែធំទូលាយដើម្បីជួយជម្រុញទៅដល់ *ចលនានិងសេវាកម្មសហគមន៍កសិកម្មក្នុងខេត្តសៀមរាប*។ ការចងក្រងបង្កើតជាសហភាពសហគមន៍កសិកម្ម គឺជាគោលបំណងគន្លឹះសម្រាប់ដំណាក់កាល់ទីពីរនេះ។ និយមន័យនៃការងារអភិវឌ្ឍសហគមន៍ត្រូវបានប្រជាពលរដ្ឋ និងអាជ្ញាធរដែនដីក្នុងភូមិ ភាគច្រើនគិតថាជាការងារដែលផ្តោតតែលើការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។ យ៉ាងណាមិញគម្រោងនេះមានការយល់ដឹងទូលំទូលាយទៅនឹងគោលគំនិតនៃការងារអភិវឌ្ឍជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានដែលវាមិនសំដៅការគាំទ្រផ្តោតទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនោះទេ។ ប៉ុន្តែវាក៏ពាក់ព័ន្ធទៅនឹងការងារពង្រីកការយល់ដឹងសិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋ ការពង្រឹងអំណាចម្ចាស់ការទាំងផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ចទៅដល់ប្រជាកសិករ និងអង្គការសហគមន៍របស់ពួកគាត់

ផងដែរ។ ដូចជាការកសាងសមត្ថភាពទៅដល់ ក្រុមជួយខ្លួនឯង សមាគមសន្សំកំចីភូមិ សហគមន៍ និងសហភាពសហគមន៍កសិកម្មជាដើម។

ប្រជាកសិករ និងអាជ្ញាធរមូលដ្ឋានក្នុងតំបន់គោលដៅគម្រោង ចាប់ផ្តើមយល់តម្លៃរបស់វាបន្តិចម្តងៗ និងបានចូលរួមកាន់តែសកម្មជាមួយគម្រោង។ សុរបទៅទាំងប្រជាកសិករ និងភាគីពាក់ព័ន្ធគម្រោងយល់ស្របថាក្រុមជួយខ្លួន ឯង សមាគមសន្សំនិងកំចីភូមិ សហគមន៍និងសហភាពសហគមន៍កសិកម្ម គឺជាហេដ្ឋារចនាសម្ព័ន្ធប្រភេទទន់មានសារៈសំខាន់ ដែលអាចចូលរួមចំណែកទៅលើនិរន្តភាពនៃកិច្ចខិតខំសម្រាប់ការងារអភិវឌ្ឍសហគមន៍ដូចគ្នាដែរ។ គម្រោងដែលយើងរៀបចំឡើងគឺដើម្បីបើកទ្វារអោយសហគមន៍ខ្លួនឯង អាចមើលឃើញពីស្ថានភាពរបស់ពួកគាត់ផ្ទាល់ បន្ទាប់មកអាចចាត់ចែងដោះស្រាយវាដើម្បីឆ្ពោះទៅកាន់អនាគត់មួយដ៏ត្រឹមត្រូវដោយខ្លួនឯង។ តាមរយៈសកម្មភាពគន្លឹះដែលគ្រោងក្នុងគម្រោង យើងអាចធ្វើការដោះស្រាយយ៉ាង សកម្មទៅលើបញ្ហាជាច្រើនដែលកើតមានក្នុងសហគមន៍។ អ្វីដែលជាមោទនភាពដែលយើងសម្រេចបានជាលទ្ធ ផលចំបងៗដូចតទៅ៖

- ចំនួនអង្គការសហគមន៍មានការកើនឡើង ដែលយើងបានចាប់ផ្តើមពីពេលដែលមិនមានសហគមន៍កសិកម្មសោះហើយនឹងក្រុមសន្សំប្រាក់៣៥ដែលទន់ខ្សោយគ្រប់គ្រង។ រហូតពេលនេះយើងបានបង្កើតសហគមន៍កសិកម្មបានចំនួន៨ ដែលមានសមាជិកសរុប២១៦គ្រួសារ ជួយគាំទ្រដល់សហគមន៍កសិកម្មមានស្រាប់៩ផ្សេងទៀតអោយនៅក្រោមឆ័ត្ររបស់សហភាពសហគមន៍កសិកម្មដែលទើបបង្កើត។ ហើយគាំទ្រក្រុមសន្សំប្រាក់ចំនួន២៥ក្រុម អាចដើរដោយឯករាជ្យខ្លួនឯងយ៉ាងសកម្មក្នុងការផ្តល់ការសេវាដល់សមាជិកដែលមានកំនើនសមាជិក៣៥%បន្ថែម លើសមាជិកចំនួន៨០៥នាក់ដែលចាប់ផ្តើមដំបូង។ យើងបានធ្វើសមាហរណកម្មនូវចំណេះដឹងបែបគំនិតច្នៃប្រឌិតថ្មីៗ ផ្នែកកសិកម្មតាមកសិដ្ឋានគម្រូមានដូចជា កសិដ្ឋានចិញ្ចឹមសត្វ ដំណាំស្រូវ ដំណាំឈើហូបផ្លែ ដំណាំបន្លែ ផ្សេងៗទៅដល់សមាជិករបស់សហគមន៍កសិកម្ម និងក្រុមសន្សំប្រាក់ទាំងនោះ។ ដើម្បីអាចអោយកសិករធ្វើពិសោធន៍នូវបច្ចេកទេសដែលរៀនសូត្រថ្មីៗ ទៅធ្វើការកែលំអរកំហុសឆ្គងការអនុវត្តកន្លងមក។ ហើយនិងធ្វើការអនុវត្តចំនេះដឹង ដែលបានរៀនសូត្រទាំងនេះយកទៅពង្រីកផ្សព្វផ្សាយ និងអនុវត្តបន្តដើម្បីទទួលបានជោគជ័យ។
- យើងរកឃើញថា៨០% នៃសមាជិកសរុបរបស់ក្រុមសន្សំប្រាក់២៥ក្រុម និង៦០%នៃសមាជិកសហគមន៍កសិកម្មទាំង១២គឺជាស្ត្រី។ ហើយដែលស្មើរតែ៩០%ក្នុងក្រុមសន្សំប្រាក់ និង៣៥%ក្នុងសហគមន៍កសិកម្មមានស្ត្រីកាន់តំណែងក្នុងជួរថ្នាក់ដឹកនាំក្រុម។ យើងតែងតែជម្រុញការពង្រឹងការចូលរួមរបស់ស្ត្រីយ៉ាងសកម្មនៅក្នុងគ្រប់កំរិតទាំងអស់ ជាពិសេសនៅក្នុងកំរិតការសម្រេចចិត្ត។ ហើយទោះបីជានៅមានឧបសគ្គរាំងកើតឡើងខ្លះៗក៏ដោយក៏យើងនៅតែមានសុទិដ្ឋិនិយមថាតាមរយៈគម្រោងនេះគឺពិតជាអាចផ្តល់ប្រយោជន៍ច្រើនដល់ស្ត្រីតាមរយៈការប្រើប្រាស់ឧបករណ៍FRAS ដែលបានណែនាំអោយអនុវត្តក្នុងគម្រោងដោយអង្គការវីអេហ្វិក។
- យើងកត់សំគាល់ឃើញពីការវិវឌ្ឍនូវផ្នែកអភិបាលកិច្ច ក្នុងចំនោមសហគមន៍កសិកម្ម និងក្រុមសន្សំប្រាក់មានការប្រសើរឡើងជាងមុន ដែលចំនុចនេះធ្វើអោយពួកគាត់អាចចាប់ផ្តើមដើរតួនាទី សកម្មដូចដែលមានចែងក្នុងលក្ខន្តិកៈរបស់ក្រុមគាត់។ បន្ថែមលើសហ្នឹងទៀតក៏មានការកើនឡើងនូវសមាជិក យ៉ាងហោចណាស់១៥%ជារៀងរាល់ឆ្នាំ ដែលជាកត្តាជម្រុញអោយមានការបង្កើននូវជំនួញលើសពី១ក្នុងសហគមន៍កសិកម្ម៧នៃចំនួនសរុប១២។ ហើយអ្វីដែលយើងមានការកោតសសើរថែមទៀតនោះគឺ ២/៣នៃជួរថ្នាក់ដឹកនាំរបស់សហគមន៍កសិកម្មមានការយល់ច្បាស់អំពីគោលការណ៍ នៃដំណើរការសហគមន៍កសិកម្មក៏ដូចជាការចាត់ចែងជំនួញហើយពួកគាត់អាចចាត់ចែងដោយខ្លួនឯងបានដើម្បីចែករម្លែកការយល់ដឹងទាំងនេះបន្តទៅដល់សមាជិករបស់ខ្លួនធ្វើអោយមានការកែប្រែនូវការអនុវត្តដែលមិនត្រឹមត្រូវពីមុនអោយកាន់តែប្រសើរឡើង។
- យើងឯពិតជាអាចជួយដល់ប្រជាកសិករ ធ្វើការកែប្រែស្ថានភាពសេដ្ឋកិច្ចរបស់ពួកគាត់ តាមរយៈការពង្រឹង

<table>
<tr><td colspan="2">សេដ្ឋកិច្ចរបស់ប្រជាកសិករ ហើយនឹងអង្គការមូលដ្ឋានរបស់ពួកគាត់។ កសិករសរុប ១៦៨នាក់ ៩០%ជាស្ត្រី ដែលជាសមាជិកមកពី ១២សហគមន៍ក្នុងតំបន់គោលដៅដឹងច្បាស់ពីគោលការណ៍កសិកម្មសរីរាង្គ (Organic Farm) ឬគោលការណ៍អនុវត្តកសិកម្មល្អ(GAP)។ ក្នុងនោះប្រហែល៥៣%ក្នុងចំនោម១៦៨នាក់ ធ្លាប់បានចូលរួមពាក់ព័ន្ធវគ្គពិគ្រោះយោបល់ស្តីពីគោលការណ៍(GAP)និងគោលការណ៍កសិកម្មដែលផ្សារភ្ជាប់នឹងបរិស្ថានល្អ ។ ជាងពាក់កណ្តាលនៃកសិកដ្ឋានគម្រូសាកល្បងចំនួន៦ បានអនុវត្តបច្ចេកទេសគោលការណ៍សរីរាង្គដោយសារបានទទួលចំណេះដឹងបច្ចេកទេសពីក្រុមការងារអង្គការកែប្រែសហគមន៍ និងមន្ទីរកសិកម្ម។<br>▪ សហភាពសហគមន៍កសិកម្ម១ត្រូវបានបង្កើតឡើងដោយមានសមាជិក១០សហគមន៍ត្រូវបានទទួលការចុះបញ្ជីរផ្លូវការពីអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម។ សហភាពនេះមានសមាសភាពសមាជិកសរុប ៩នាក់ ស្រី៤នាក់ ហើយប្រធានសហភាពជាស្ត្រី ដែលមានកសិករជាសមាជិកជិត៩០០គ្រួសារ។</td></tr>
<tr><td>គោលបំណងរួមគម្រោង</td><td>គោលដៅត្រូវសម្រេចឆ្នាំ២០១៧</td></tr>
<tr><td>ជម្រុញភាពសកម្មអង្គការកសិករ ដើម្បីកែលម្អរអោយមាននិរន្តភាព ទិន្នផលកសិកម្មនិងប្រាក់ចំនូល ដល់សហគមន៍ក្នុងខេត្តសៀមរាប</td><td>• សហភាពសហគមន៍កសិកម្មមួយនឹងត្រូវបានបង្កើតហើយអនុញ្ញាតិអោយចុះបញ្ជីរទទួលស្គាល់ដោយក្រសួងកសិកម្ម ការចុះបញ្ជីរត្រូវបានពន្យាដោយត្រូវរង់ចាំការអនុម័ត ច្បាប់ពាក់ព័ន្ធដោយរដ្ឋសភាជាតិនៅឆ្នាំ២០១៦។<br>• ផែនការជំនួញ និងសេវាកម្មគាំទ្រ (ផែនការមេ) នឹងត្រូវបានរៀបចំនិងអនុវត្តដោយសហភាពសហគមន៍កសិកម្ម ហើយត្រូវបានចូលរួមអនុម័តដោយសមាជិក និងមន្ទីឬក្រសួងកសិកម្ម។<br>• យ៉ាងហោចណាស់ផែនការជំនួញត្រូវបានពង្រីកថែមតាមសហគមន៍កសិកម្មទាំង១២ ហើយសមាជិករបស់សហគមន៍កើនឡើងប្រាក់ចំណូល២០%<br>• យ៉ាងហោចណាស់ក្រុមសន្សំមានស្រាប់ ៥ ត្រូវបានបំលែងនិងអនុវត្តគោលការណ៍ VSLA<br>• យ៉ាងហោចក្រុមសន្សំប្រាក់ ២០ក្រុមត្រូវបានទទួលការគាំទ្របច្ចេកទេសដើម្បីបន្តនិរន្តរភាពក្រុម<br>• យ៉ាងហោចក្រុមសន្សំប្រាក់១០ក្រុម ត្រូវាបានច្របាច់បញ្ចូលទុនសន្សំទៅជាការទិញភាគហ៊ុនរបស់សហគមន៍<br>• កសិករជាសមាជិកសហគមន៍កសិកម្មចំនួន ៦០០នាក់ និងប្រហែល ១៥០០នាក់មកពីក្រុមសន្សំប្រាក់ ត្រូវបានពង្រឹងសមត្ថភាពនិងភាពអង់អាចម្ចាស់ការតាមរយៈចំណេះដឹងពីឧបករណ៍ HRBA/Study-Circle<br>• សហភាពសហគមន៍កសិកម្មត្រូវបានភ្ជាប់បណ្តាញទៅប ណ្តាញកសិករថ្នាក់ជាតិ<br>• ទីផ្សារចរាចរណ៍ផលិតផលរបស់សហភាពសហគមន៍កសិកម្មយ៉ាងហោចចំនួន១ត្រូវបានបង្កើតឡើងដើម្បីធានការ ទទួលយកផលិតផលរបស់សមាជិកមកលក់</td></tr>
<tr><td colspan="2">លទ្ធផលសម្រេចបានឆ្នាំ ២០១៧</td></tr>
</table>

កំឡុងពេលនេះ គម្រោងសម្រេចបាននូវលទ្ធផលតាមផែនការជាច្រើន។ កសិករជាង១១៣៩នាក់ បានពង្រីកចំនេះដឹងជុំវិញការធ្វើកសិកម្មជំនាំស្រូវដែលអាចឈានទៅកែលំអរផលិតកម្មដំណាំស្រូវរបស់ពួកគាត់អោយបានទិន្នផលពី៣៥០០គ.ក្រ ទៅ៤០០០គ.ក្រ ក្នុងមួយហិចតា។ ស្របពេលហ្នឹងដែលសហាគមន៍កសិកម្មក៏បាន រាយការណ៍មកថាសមាជិកសហាគមន៍ពួកគាត់ចំនួន៦៤៩នាក់ បានកែលំអរផលិតកម្មដំណាំបន្លែនិងឈើហូបផ្លែ កើនឡើង២៤% ក្រោយពីបានចូលរួមវគ្គបណ្តុះបណ្តាលជាសេរីនៃប្រធានបទនេះ និងទទួលបានការ ពិគ្រោះ យោបល់បច្ចេកទេសតាមរយៈការគាំទ្រគម្រោងនិងមន្ត្រីជំនាញនៃមន្ទីរកសិកម្ម។ សម្រាប់ការកែលំអរប្រាក់ ចំណូលចំណោមកសិករ គម្រោងបានចុះអង្កេតដើម្បីប្រមូលពត៌មាននិងរបាយការណ៍ឃើញថា អត្រាភាពក្រីក្របានធ្លាក់ចុះ១៣.៣%បើធៀបទៅនឹងអត្រាឆ្នាំ២០១៥ មាន ២៧.៣%។ គម្រោងបាន ត្រួតពិនិត្យឃើញថា កសិករជាង៤០៥នាក់ នៃសមាជិកសហាគមន៍ទាំង១២ មានការកើនឡើងប្រាក់ចំណូល២០% ដែលមានប្រាក់ចំនូលចន្លោះ ១១៥ដល់ ១៨០ដុល្លា មកពីពីជំនួញរបស់សហាគមន៍កសិកម្ម។

ដំណើរការនៃការចុះបញ្ជីរសហាភាពសហាគមន៍បានស៊ីពេលច្រើនជាងការរំពឹងទុកដោយសារហេតុផលដូចតទៅៈ ទី១គឺដោយសារស្របពេលដែលដំណើរការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ក្នុងខែមិថុនាឆ្នាំ២០១៧ ដែលវាបង្កជាការលំបាកក្នុងការទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានដោយសារពួកគាត់ជាប់មមាញឹកជុំវិញការឃោសនាបោះឆ្នោត។ ទី២ដោយមានការពន្យាពីការចេញសារចរណែនាំស្តីពីនិតិវិធីក្នុងការបង្កើតសហាភាពសហាគមន៍កសិកម្មដែលចេញដោយក្រសួងកសិកម្ម។ ជាចុងក្រោយ ក្នុងខែកញ្ញាឆ្នាំ ២០១៧ អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្មបានព្រមទទួលការចុះបញ្ជីរសហាភាពសហាគមន៍កសិកម្មតាមសំណើរ។ នេះជាសហាភាពសហាគមន៍កសិកម្មទី៥ហើយនៅទូទាំងប្រទេសកម្ពុជាដែលទទួលបានការចុះបញ្ជីរ។ ដើម្បីជាការអបអរប្រធាននាយកដ្ឋានបានស្នើរមកតាមរយៈអង្គការកែប្រែសហាគមន៍អោយចាត់ចែងរៀបចំពិធីប្រកាស ដោយលោកនឹងពិភាក្សាអញ្ជើញលោក អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម និងអភិបាលខេត្តសៀមរាបចូលរួមជាអធិបតី។ ហើយក្នុងនោះក៏មានការចូលរួម ពីមន្ទីរកិច្ចការនារី មន្ទីរកសិកម្ម មន្ទីរពាណិជ្ជកម្ម អភិបាលស្រុក ក្រុមប្រឹក្សាឃុំនៃតំបន់គោលដៅគម្រោង រួមជាមួយនឹងសមាជិកសមាជិកានៃសហាភាពសហាគមន៍កសិកម្មសៀមរាបអង្គរផងដែរ។ ពិធីបានប្រព្រឹត្តិទៅប្រកបដោយជោគជ័យនិងផ្លែផ្កាជាមួយនឹងស្មារតីសហប្រតិបត្តិការរឹងមាំសម្រាប់ថ្ងៃអនាគត់។

ក្រុមប្រឹក្សាភិបាលរបស់សហាគមន៍កសិកម្ម និងសហាភាពសហាគមន៍កសិកម្មបានទទួលការបណ្តុះបណ្តាលអំពីការរៀបចំសំណើរគម្រោងដើម្បីដាក់ទៅស្វែងរកការគាំទ្រ និងកិច្ចសហការណ៍ពីរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍនានា។ ដើម្បីអោយសហាភាពមានផែនការជាក់លាក់ក្រោយពេលទទួលបានវិញ្ញាប័នបត្រស្របច្បាប់។ ក្រោយពីចប់វគ្គនេះ សិក្ខាកាមមានការពេញចិត្តនិងប្រធានបទ ព្រោះវាបានធ្វើអោយពួកគាត់បានយល់និងមានចំណេះដឹងបន្ថែមជុំវិញការគៀងគរដៃគូពីភាគីខាងក្រៅ។ ជាង ៧០%នៃសមាជិកក្រុមប្រឹក្សាភិបាលសហាភាពសហាគមន៍កសិកម្មមានការយល់ដឹងបន្ថែមពីវិធីសាស្រ្តដើម្បីទទួលបានការគាំទ្រថវិកាឬមូលនិធិពីប្រភពខាងក្រៅ។ ផែនការមេឬផែនការជំនួញរបស់សហាភាពត្រូវបានរៀបចំក្រោមការសម្របសម្រួលគាំទ្រតាមរយៈគម្រោងដើម្បីភ្ជាប់ទៅនឹងសំណើរចុះបញ្ជីរសហាភាពសហាគមន៍កសិម្ម ដែលជាឧបសម្ព័ន្ធតម្រូវដោយច្បាប់។

គម្រោងបានផ្តល់វគ្គកសាងសមត្ថភាពទៅលើ ការប្រតិបត្តិការមុខជំនួញទៅដល់សហាភាពសហាគមន៍កសិកម្មសៀមរាបអង្គរទៅលើមុខជំនាញរដ្ឋបាល ហើយនឹងការផ្តល់សេវាទៅដល់សមាជិកក្រុមប្រឹក្សាភិបាលទាំងង៩រូប ដែលក្នុងនោះមានស្រ្តី៤រូប។ វគ្គបណ្តុះបណ្តាលគឺចង់បាញ់ឆ្ពោះដើម្បីអោយប្រាកដថា គណាកម្មការសហាភាពយល់ច្បាស់អំពីតួនាទី និងសេវាកម្មដែលជាតម្រូវការរបស់សមាជិកដែលពួកគេត្រូវផ្តល់អោយ។ ដើម្បីអោយសមត្ថភាពនៃការធ្វើទំនាក់ទំនងរបស់សហាភាពសហាគមន៍កសិកម្ម យើងបានផ្តល់វគ្គកសាងសមត្ថភាព ក៏ដូចជាការបែងចែកតួនាទី

ការទទួលខុសត្រូវដល់ក្រុមប្រឹក្សាភិបាលផងដែរ។ អំពីយន្តការឬទំរង់ការ នៃការទំនាក់ទំនងរវាងសហាគមន៍កសិកម្មជាសមាជិករបស់សហភាពសហគមន៍កសិកម្មសៀមរាប។ វគ្គបណ្តុះបណ្តាលក៏ដាក់បញ្ចូលផងដែរអំពីសីលធម៌នៃការងារ ភាពជាអ្នកដឹកនាំ និងបទបញ្ជាផ្ទៃក្នុងដូចដែលមាន ចែងក្នុងច្បាប់និងគោលការណ៍ណែនាំរបស់សហាគមន៍កសិកម្ម និងលក្ខខ័ណ្ឌលំអិតមុខងារតួនាទីរៀងខ្លួនៗ។ សហាគមន៍កសិកម្មចំនួន ៦ក្នុងចំណោម១២ បានបន្ថែមមុខជំនួញតាមសហាគមន៍ដល់ចំនួន២ ប៉ុន្តែសហាគមន៍ផ្សេងទៀត នៅមានមុខជំនួញតែ១នៅឡើយ។ របាយការណ៍ប្រាក់ចំណេញតាមសហាគមន៍មានការកើនបាន១៥% ជាមធ្យម។

យើងបានរៀបចំជាវេទិកាស្រូវអង្គរសហាគមន៍កសិកម្មដើម្បីស្វែងរកធាតុចូល ក៏ដូចជាកិច្ចសហការណ៍ និងការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធដើម្បីជម្រុញសហគ្រាសសហាគមន៍កសិកម្ម ក្នុងការធ្វើជំនួញបង្កើតប្រាក់ចំណេញក្នុងដំណើរឆ្ពោះទៅរកនិរន្តរភាពផងដែរ។ ហើយក៏ធ្វើការភ្ជាប់សហាគមន៍កសិកម្មទៅកាន់ដៃគូរជំនួញដែលមានសក្តានុពលនិងអ្នកវិនិយោគជាក្រុមហ៊ុនលើវិស័យកសិកម្ម ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក៏ដូចជាការភ្ជាប់សហាគមន៍កសិកម្មទៅកាន់ភ្នាក់ងារផ្តល់សេវារបស់រដ្ឋ និងដៃគូអភិវឌ្ឍ ឬម្ចាស់ជំនួយ។ ផ្អែកទៅលើការយល់ឃើញជាក់ស្តែង សហភាពសហាគមន៍កសិកម្ម គឺជាច្រកសំខាន់ដើម្បីសម្របសម្រួលសហាគម៍កសិកម្មថ្នាក់មូលដ្ឋានតាំងពីមិនទាន់បានចុះបញ្ជីរផ្លូវការ។ ដោយបានដើរតួនាទីសកម្មជម្រុញចលនារបស់សហាគមន៍ ដូចមានចែងក្នុងច្បាប់ស្តីពីសហាគន៍កសិកម្ម។ ពោលគឺសហភាពសហាគមន៍កសិកម្ម បានភ្ជាប់ទៅកាន់បណ្តាញថ្នាក់ជាតិមានដូចជា សហព័ន្ធស្រូវអង្គរ កម្ពុជា វេទិកាកសិករថ្នាក់ជាតិ វេទិការកសិករស្ត្រីឆ្នើម ។ល។ ជាបណ្តោះអាសន្នសហភាពសហាគមន៍កសិកម្មបានអនុញ្ញាតិអោយប្រើប្រាស់ភ្នែកខាងក្រោមនៃការិយាល័យរបស់អង្គការកែប្រែសហាគមន៍ជាការិយាល័យសម្រាប់ធ្វើការក៏ដូចជាដាក់តាំងបង្ហាញផលិតផលដើម្បីភ្ជាប់ទីផ្សារ ហើយជាបណ្តើរៗខិតខំធ្វើការចចារសម្របសម្រួលជាមួយអាជ្ញាធរខេត្តដើម្បីទទួលបានសម្បទានគាំទ្រផ្តល់ជាទីកន្លែងអចិន្ត្រៃសម្រាប់ប្រើប្រាស់ទៅអនាគត់ផងដែរ។

ក្រុមសន្សំគម្រូ VSLA ចំនួន២ត្រូវបានប្តូរពីក្រុមសន្សំគម្រូចាស់ ហើយក្រុមសន្សំប្រាក់២០ក្រុមផ្សេងទៀតកំពុងភ្ជាប់ការគាំទ្រដោយបន្តផ្តល់ជូនការបង្វឹកបច្ចេកទេសដើម្បីអាចកែលំអរការប្រតិបត្តិការ និងអភិបាលកិច្ចក្រុម។ ក្នុងនោះដែរក្រុមសន្សំប្រាក់១០ក្រុមត្រូវបានបណ្តុះបណ្តាលអំពីរបៀបចាត់ចែង និងច្របាច់បញ្ចូលប្រាក់សន្សំរបស់ពួកគាត់អោយទៅជាការគ្រប់គ្រងក្នុងសហាគមន៍កសិកម្មវិញ។ គ្រូបង្គោល១៨៩នាក់ត្រូវបានកសាងសមត្ថភាពទៅលើប្រធានបទ HRBA/Study-Circle រួចពួកគាត់បន្តការផ្សព្វផ្សាយទៅកាន់សមាជិកក្នុងសហាគមន៍ដើម្បីផ្តល់ភាពសកម្ម និងអង់អាចម្ចាស់ការទៅកាន់កសិករចំនួន២៥០០នាក់ផ្សេងទៀតដែលជាសមាជិកសហាគមន៍ក្នុងគោលដៅគម្រោង ហើយក៏ដើម្បីធ្វើការបង្កើនស្មារតី នៃការចូលរួមទៅលើជំនាញនៃការបញ្ចុះបញ្ចូល និងទាមទារដោយសន្តិវិធីជាប្រយោជន៍រួមដល់ក្រុមរបស់ពួកគាត់។

| គោលបំណងជាក់លាក់ | គោលដៅត្រូវសម្រេចឆ្នាំ២០១៧ |
| --- | --- |
| **ទី១៖ ជម្រុញបន្ថែមហើយនិងធ្វើសមាហរណកម្ម គោលការណ៍ HRBA /STUDY-CIRCLEក្នុងចំណោមថ្នាក់ដឹកនាំក្រុមសន្សំប្រាក់ និងសហាគមន៍កសិកម្ម ក្លឹបយុវជន ហើយនឹងអាជ្ញាធរដែនដី (យ៉ាងហោចមាន ៥៤%ជាស្ត្រីចូលរួម)** | • យ៉ាងហោចណាស់សមាជិកគណកម្មការ១២០នាក់ ស្រី៦៨នាក់មកពីសហាគមន៍កសិកម្មនិងក្រុមសន្សំប្រាក់ទទួលបានការបណ្តុះបណ្តាលជំនាញគ្រូបង្គោលក៏ដូចជាចូលរួមសិក្ខាសាលានិងឯកសារមេរៀនពាក់ព័ន្ធជុំវិញគោលការណ៍ HRBA/STUDY-CIRCLEនិងច្បាប់ផ្សេងៗ<br>• យ៉ាងហោច៩០%នៃសមាជិកសហាគមន៍កសិកម្ម ក្រុមសន្សំ ទទួលបានវគ្គបណ្តុះបណ្តាល ការអប់រំទៅលើនិងអនុវត្តគោល ការណ៍ HRBA/STUDY-CIRCLE |
| លទ្ធផលសម្រេចបានឆ្នាំ ២០១៧ | |

<table>
<tr><td colspan="2">
ដោយគោលការណ៍ HRBA/study-circle គឺឧបករណ៍មានប្រសិទ្ធិភាពមួយជួយក្នុងការលើកកំពស់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យ មានគណនេយ្យភាព និងតម្លាភាព។ ហើយឧបករណ៍នេះក៏បានបញ្ចូលនូវការពន្យល់អំពីតួនាទីរវាងម្ចាស់សិទ្ធិនិងអ្នកទទួលខុសត្រូវលើការការពារម្ចាស់សិទ្ធិ ដែលម្ចាស់សិទ្ធិអាចប្រើប្រាស់ដោយស្របច្បាប់ដើម្បីអោយអ្នកទទួលខុសត្រូវពាក់ព័ន្ធមានដូចជា ក្រុមប្រឹក្សាឃុំ រដ្ឋបាលស្រុក មន្ទីរជំនាញ ក៏ដូចជាក្រសួងកសិកម្ម ដែលពេលខ្លះទាមទាអោយម្ចាស់សិទ្ធិមានការសកម្មក្នុងការក្នុងដំណើរការស្វែងរកការគាំទ្រនិងដំណោះស្រាយ។ វគ្គបណ្តុះបណ្តាលពី HRBA/study-circle ហើយនឹងការបង្ហាញផ្លូវក្នុងការស្វែងរកការគាំទ្រត្រូវបានរៀបចំ និងផ្តល់ជូនទៅដល់ក្រុមកសិករគោលដៅដែលជាអ្នកទទួលផលគម្រោង។ វាត្រូវបានសម្រិតសម្រាំងពន្យល់យ៉ាងច្បាស់នៅក្នុងជំហ៊ានទាំង៤រួមមាន ១-កសាងរចនាសម្ព័ន្ធ និងសម្ព័ន្ធភាពដើម្បីអោយមានសំលែងច្រើន ២-កសាងសម្ពភាពក្នុងការស្វែងរកការគាំទ្រ ៣-លើកពីបញ្ហានិងកង្វល់ដែលជាតម្រូវការដើម្បីអ្នកទទួលខុសត្រូវបានដឹងឮ ៤-ត្រូវយល់អោយច្បាស់ថាសិទ្ធិរបស់គាត់ពិតមានក្នុងច្បាប់ដែលត្រូវបានទទួលខុសត្រូវ។<br><br>
ការបណ្តុះបណ្តាលនេះមាន២ជុំ នៅជុំទី១ប្រធានបទ HRBA ជុំទី២ប្រធានបទ Study Circle ក្នុង១ជុំនៃវគ្គបណ្តុះបណ្តាលមានសមាជិកគណកម្មការ១២០នាក់ក្នុងនោះស្រី៦៨នាក់ មកពីសហភាពសហគមន៍កសិកម្ម១ សហគមន៍កសិកម្ម១២ ក្រុមសន្សំប្រាក់២៥ក្រុម បានបញ្ចប់វគ្គ HRBA/Study Circle ហើយទទួលបានសម្ភារៈមេរៀន និងកម្រងឯកសារចែកជូនមួយកំប្លេ។ ២/៣នៃអ្នកចូលរួមសរុបត្រូវបានជ្រើសរើសជាគ្រូបង្គោលទៅលើប្រធានបទនៃវគ្គបណ្តុះបណ្តាលនេះផងដែរ។ ពួកគាត់ទាំងអស់ត្រូវបានបណ្តុះបណ្តាលទៅលើជំនាញនៃការស្វែងរកការគាំទ្រផ្អែកលើសិទ្ធិស្របច្បាប់ពលរដ្ឋ សិទ្ធិស្ត្រីនិងកុមារ និងសិទ្ធិដីធ្លី សិទ្ធិលើសេដ្ឋកិច្ច យន្តការដោះស្រាយទំនាស់។ល។<br><br>
ចំណេះដឹងជុំវិញគោលការណ៍ HRBA/Study Circle គឺជាផ្នែកនៃសមាហរណកម្មទៅក្នុងការលើកកំពស់និរន្តរភាព និងសមភាពមុខងាររបស់អង្គការមហាជន។ ដោយផ្អែកទៅលើកត្តានេះ គម្រោងបានធ្វើសមាហរណកម្មជាប្រព័ន្ធដើម្បីបញ្ចូលការអនុវត្ត HRBA/Study Circle នៅរាល់ការប្រជុំប្រចាំខែរបស់អង្គការមហាជននេះ។ បន្ទាប់ពីបានចូលរួមក្នុងវគ្គជំនាញនៃការស្វែងរកការគាំទ្រ និង Study Circle នេះ សិក្ខាកាមប្រហែល ៨០% ដែលជាសមាជិកក្រុមសន្សំប្រាក់ បានបង្ហាញពីការចាប់អារម្មណ៍និងការប្តេជ្ញាចិត្តដើម្បីយកចំនេះដឹងដែលទទួលបានពីវគ្គនេះទៅអនុវត្តដើម្បីជួយដល់សហគមន៍និងក្រុមរបស់ខ្លួន។ កសិករជាសិក្ខាកាមបង្ហាញចំណាប់អារម្មណ៍រីករាយ ដោយពួកគាត់យល់ពីសិទ្ធិស្របច្បាប់ សិទ្ធិប្រើប្រាស់គ្រប់គ្រងចាត់ចែងដីធ្លី សិទ្ធិស្ត្រី សិទ្ធិកុមារ ដែលផ្តល់ជូនពួកគាត់តាមការចូលរួមសកម្មភាពគម្រោង។ ហើយពួកគាត់បានលើកឡើងដោយផ្ទាល់មាត់ថា គាត់នឹងយកស្មារតីនៃចំណេះដឹង គោលគំនិតទាំងនេះចែករម្លែកផ្សព្វផ្សាយទៅដល់អ្នកដ៏ទៃទៀតក្នុងសហគមន៍ផងដែរ។ កសិករ ២១០៦/២៥០០នាក់ ដែលជាសមាជិករបស់សហគមន៍កសិកម្ម១២ ក្រុមសន្សំប្រាក់៣០ បានរាយការណ៍ថាបានទទួលនូវវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពដោយមន្ត្រីគម្រោង និងការចូលរួមការផ្សព្វផ្សាយបន្តដោយគ្រូបង្គោលក្នុងសហគមន៍ ហើយមានការកើនចំណេះដឹងច្រើនជុំវិញប្រធានបទនៃវគ្គ HRBA/Study Circle នេះ។
</td></tr>
<tr><td>ទី២៖ ធ្វើនិយ័តកម្មសហភាពសហគមន៍ កសិកម្មនិងកសាងផែនការយុទ្ធសាស្ត្រ ក៏ដូចជាបញ្ចប់ដំណើរការចុះបញ្ជីរសហគមន៍កសិកម្មមួយដែលនៅមិនទាន់សម្រេច (ឃុំត្រីញ័រ)</td><td>• សហភាពសហគមន៍កសិកម្មសៀមរាបអង្គ នឹងត្រូវបានបញ្ចប់ដំណើរការចុះបញ្ជីរហើយមានការទទួលស្គាល់ស្របច្បាប់ពីអគ្គនាយដ្ឋានកសិកម្មនៃក្រសួងកសិកម្ម<br>• ដំណើរការចុះបញ្ជីរសហគមន៍កសិកម្មដែលនៅមិនទាន់សម្រេច (ឃុំត្រីញ័រ)នឹងត្រូវបានបញ្ចប់និងទទួលស្គាល់ជាផ្លូវការ</td></tr>
<tr><td colspan="2">លទ្ធផលសម្រេចបានឆ្នាំ ២០១៧</td></tr>
</table>

ដំណើរការនៃការចុះបញ្ជីរសហភាពសហគមន៍បានស៊ីពេលច្រើនជាងការរំពឹងទុកដោយសារហេតុផលដូចតទៅៈ ទី១គឺដោយសារស្របពេលដែលដំណើរការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ក្នុងខែមិថុនាឆ្នាំ២០១៧ ដែលវាបង្កជាការលំបាកក្នុងការទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានដោយសារពួកគាត់ជាប់មមាញឹកជុំវិញការឃោសនាបោះឆ្នោត។ ទី២ដោយមានការពន្យាពីការចេញសារចរណែនាំស្តីពីនិតិវិធីក្នុងការបង្កើតសហភាពសហគមន៍កសិកម្មដែលចេញដោយក្រសួងកសិកម្ម។ ជាចុងក្រោយ ក្នុងខែកញ្ញាឆ្នាំ ២០១៧ អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្មបានព្រមទទួលការចុះបញ្ជីរសហភាពសហគមន៍កសិកម្មតាមសំណើរ។ នេះជាសហភាពសហគមន៍កសិកម្មទី៥ហើយនៅទូទាំងប្រទេសកម្ពុជាដែលទទួលបានការចុះបញ្ជីរ។ ដើម្បីជាការអបអរប្រធាននាយកដ្ឋានបានស្នើរមកតាមរយៈអង្គការកែប្រែសហគមន៍អោយចាត់ចែងរៀបចំពិធីប្រកាស ដោយលោកនឹងពិភាក្សាអញ្ជើញលោក អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម និងអភិបាលខេត្តសៀមរាបចូលរួមជាអធិបតី។ ហើយក្នុងនោះក៏មានការចូលរួម ពីមន្ទីរកិច្ចការនារី មន្ទីរកសិកម្ម មន្ទីរពាណិជ្ជកម្ម អភិបាលស្រុក ក្រុមប្រឹក្សាឃុំនៃតំបន់គោលដៅគម្រោង រួមជាមួយនឹងសមាជិកសមាជិកានៃសហភាពសហគមន៍កសិកម្មសៀមរាបអង្គរផងដែរ។ ពិធីបានប្រព្រឹត្តិទៅប្រកបដោយជោគជ័យនិងផ្លែផ្កាជាមួយនឹងការប្តេជ្ញាចិត្តដែលជាស្មារតីសហប្រតិបត្តិការរឹងមាំសម្រាប់ថ្ងៃអនាគត។

រចនាសម្ព័ន្ធសម្រាប់ប្រតិបត្តិការនិងគ្រប់គ្រងសហភាពសហគមន៍កសិកម្មត្រូវបានរៀបរយ ជាមួយនឹងគោលនយោបាយ ផែនការសកម្មភាព និងលក្ខខ័ណ្ឌបែងចែកតួនាទីភារកិច្ចរបស់គណៈគ្រប់គ្រងផងដែរ។ អង្គការកែប្រែសហគមន៍បានផ្តល់ការកសាងសមត្ថភាពដល់សមាជិកគណៈគ្រប់គ្រងដោយផ្អែកលើគោលការណ៍ដែលមានរបស់សហភាព ផែនការសកម្មភាពនិងលក្ខខ័ណ្ឌការងារដែលមាន។ ផែនការជំនួញមួយត្រូវបានរៀបចំឡើងក្រោមការសម្របសម្រួលពីកម្មវិធីដែលផ្តល់មូលនិធិនិងបច្ចេកទេសពីអង្គការរីអេហ្វិកតាមរយៈអង្គការកែប្រែសហគមន៍។ ដើម្បីភ្ជាប់ជាមួយនឹងសំណៅឯសារស្នើរសុំចុះបញ្ជីរ ដែលជាឧបសម្ព័ន្ធមួយតម្រូវដោយច្បាប់អោយមានសម្រាប់ការចុះបញ្ជីរ។

គណៈគ្រប់គ្រងដឹកនាំសហភាពបានជួបប្រជុំគ្នាយ៉ាងហោចណាស់៣ដងក្នុងមួយខែ ដើម្បីត្រួតពិនិត្យ និងតាមដានវឌ្ឍនភាព និងការប្រឈមដែលកើតមាន ក៏ដូចជាដើម្បីរៀបចំគោលនយោបាយដែលពាក់ព័ន្ធ ចូលរួមវគ្គកសាងសមត្ថភាព ជួបជាមួយអ្នកពាក់ព័ន្ធដើម្បីស្វែងរកកិច្ចសហការណ៍ពីដៃគូរជំនួញនានាជាដើម។ ម្យ៉ាងវិញទៀត កម្រិតនៃការប្រតិបត្តិការរបស់សហភាពសហគមន៍កសិកម្មក៏នៅមានសមត្ថភាពតិចតួចនៅឡើយទៅលើសមត្ថភាពដើមទុនពីប្រភពគម្រោង និងបរិមាណភាគហ៊ុនបានទិញរបស់សមាជិក បើធៀបទៅនឹងទំហំនៃតម្រូវការក្នុងផែនការជំនួញ។

ថ្នាក់ដឹកនាំសហភាពបានធ្វើការចុះស្វាបស្ទង់សមត្ថភាពផលិតកម្ម អំពីបរិមាណ និងប្រភេទផលិតផលដែលកសិករជាសមាជិកអាចភ្ជាប់មកកាន់ទីផ្សារ។ ហើយក៏បានជួយទៅដល់គណកម្មការដឹកនាំសហគមន៍ជាសមាជិកដែលទន់ខ្សោយទៅលើ ការគ្រប់គ្រងកត់ត្រាបញ្ជីរស្នាម ការបិតបញ្ជីរ ហើយនឹងធ្វើការតំរង់ទិសពីគោលការណ៍នៃសហគមន៍កសិកម្ម ដើម្បីអោយពួកគាត់មានការយល់ច្បាស់ ដែលអាចជួយទៅដល់ការជួយក្នុងការប្រមូលពត៌មានស្វាបស្ទង់ពីតម្រូវការនៃធាតុចូលកសិកម្ម សំដៅឈានទៅស្វែងរកដៃគូជំនួញដើម្បីផ្គត់ផ្គង់ដល់សមាជិកផងខ្លួន។ មេដឹកនាំសហភាពក៏បានធ្វើការយ៉ាងជិតស្និទ ដើម្បីជួយដល់គណៈកម្មការសហគមន៍ជាសមាជិកដើម្បីរៀបចំការធ្វើមហាសន្និបាតជាទៀតទាត់ដើម្បីជម្រុញអោយការអនុវត្តខ្ជាប់ខ្ជួនតាមនិតិវិធីរបស់សហគមន៍ដូចមានចែងក្នុងច្បាប់។

សហគមន៍កសិកម្ម១ត្រូវបានបញ្ចូលក្នុងគោលដៅគម្រោងដើម្បីបញ្ចប់ដំណើរការចុះបញ្ជីរ ដែលមានឈ្មោះសហគមន៍កសិកម្មត្រីញ៉ រ សហគមន៍នេះមានសមាជិកសរុប៣២គ្រួសារ។ គម្រោងបានផ្តល់ការកសាងសមត្ថភាព និងជួយគាំទ្រដល់ដំណើរការចុះបញ្ជីរនៅមន្ទីរកសិកម្មខេត្ត។ ការចុះបញ្ជីរសហគមន៍នេះបានត្រូវមន្ទីរស្នើរអោយពន្យារហូតមានការដោះស្រាយជម្រះបញ្ចប់ សហគមន៍កសិកម្មមុនដែលជួបបញ្ហាមិនទាន់ដោះស្រាយចប់ ហើយការស្នើរសុំចុះ

| | |
|---|---|
| បញ្ជីរនេះរំពឹងថាប្រហែលនឹងទទួលបានការអនុម័តនៅឆ្នាំ២០១៨វិញ។ | |
| **ទី៣៖ផ្តល់ការគាំទ្របច្ចេកទេសទៅដល់ក្រុមសន្សំប្រាក់ សហគមន៍ និងសហភា ពសហគមន៍កសិកម្ម** | • ក្រុមសន្សំប្រាក់២០ដែលនៅទន់ខ្សោយនឹងមានសមត្ថភាពប្រសើរឡើងក្នុងដំណើរការក្រុម<br>• ផ្តល់ការគាំទ្របច្ចេកទេសទៅដល់សហគមន៍កសិកម្ម១២ និងសហភាពសហគមន៍កសិកម្មដែលនឹងបង្កើតឡើងថ្មីៗ ហើយនឹងធ្វើការកែលំអរការគ្រប់គ្រងសមត្ថភាពមីក្រូហិរញ្ញវត្ថុ ដើម្បីអោយអាចបញ្ច្រាបំលែងទុនក្រុមសន្សំទៅជាទុនសហគមន៍<br>• សហគមន៍ និងសហភាពសហគមន៍កសិកម្ម នឹងក្លាយជាសមាជិកបណ្តាញទាំងថ្នាក់ខេត្តនិងថ្នាក់ជាតិ |
| លទ្ធផលសម្រេចបានឆ្នាំ ២០១៧ | |

ក្រុមសន្សំបែប VSLA១០ក្រុម ក្រុមសន្សំធម្មតា២០ក្រុម ក្នុង៩ឃុំ ត្រូវបានសើរើកែសម្រួលរចនាសម្ព័ន្ធ លក្ខ័ន្តិកៈ ហើយថ្នាក់ដឹកនាំក្រុមត្រូវបានធ្វើការតំរង់ទិសដើម្បីមានសមត្ថភាពគ្រប់គ្រងបញ្ជីរស្មោម និងការប្រតិបត្តិការក្រុម។ ប្រហែល ៧៨% នៃក្រុមសន្សំដែលបានជ្រើសរើស គឺបានប្រតិបត្តិការចាត់ចែងក្រុមស្របតាមបច្ចេកទេសគោលការណ៍ណែនាំ ចំណែកឯក្រុមដ៏ទៃទៀតកំពុងយ៉ាប់យឺនជុំវិញការគ្រប់គ្រងកត់ត្រាបញ្ជីរស្មោម ជាពិសេសពាក់ព័ន្ធទៅនឹងការគណនាអត្រាការប្រាក់នៅពេលដែលសមាជិកដាក់សន្សំចំនួនតូចធំខុសគ្នា។ ប៉ុន្តែក្រុមដែលមានគណកម្មការដឹកនាំខ្លាំងនៅតែអាចដំនើរការក្រុមដោយរលូន ហើយចាប់ផ្តើមចែករម្លែកបន្ត ឬផ្តល់ការបណ្តុះបណ្តាលបង្វឹកដល់ក្រុមឯទៀតដែលខ្សោយដើម្បីអោយក្រុមទាំងនោះកែលំអរចំនុចខ្វះខាតរបស់ក្រុមដោយខ្លួនឯងផ្ទាល់តែម្តង។

វគ្គបណ្តុះបណ្តាល៣វគ្គលើប្រធានបទស្ត្រីក្នុងភាពជាអ្នកដឹកនាំត្រូវបាផ្តល់ជូន ក្រុមសន្សំប្រាក់ ២០ក្រុមនៅក្នុងឆមាសទី១នៃឆ្នាំ២០១៧។ គម្រោងបានជួយរៀបចំកាលវិភាគសម្រាប់ការគ្រប់គ្រងចាត់ចែងក្រុម រួចប្រគល់អោយទៅមេដឹកនាំក្រុម។ ក្រុមសន្សំ៨ក្រុមដែលមានសមត្ថភាពឈានមុខ បានផ្ទេរចំណេះដឹងពីការអនុវត្តល្អដែលធ្លាប់មានទៅដល់ក្រុមសន្សំ១៥ក្រុមផ្សេងទៀត។ កំឡុងពេលនេះដែរក្រុមសន្សំប្រាក់២០ក្រុម ក្រុម VSLA១០ក្រុមដែលទើបប្តូរមកពីក្រុមសន្សំធម្មតា កំពុងត្រូវបានជួយជ្រោមជ្រែង ដែលមានការគាំទ្រជាប់ជាប្រចាំដើម្បីកែលំអរការប្រតិបត្តិការ និងស្ថាភាពអភិបាលកិច្ចរបស់ក្រុមពួកគេ។ ២/៣នៃក្រុមទាំងអស់នេះមានស្វ័យភាព ហើយមិនមានការរអ៊ូរទាំលើកឡើងពីបញ្ហាពីសមាជិកក្រុមឡើយនៅពេលការចុះជួបចុងក្រោយ។ ២/៣នៃថ្នាក់ដឹកនាំក្រុមយ៉ាងហោចមាន៥ព្រឹត្តិការធំៗត្រូវបានអញ្ជើញដោយខេត្ត និងបណ្តាញនានា។

គម្រោងក្រោមការសហការជាមួយមន្ទីរកសិកម្ម បានរៀបចំបើកវគ្គទៅលើ ការធ្វើជំនួញ និងពាណិជ្ជកម្មទៅដល់សហគន៍កសិកម្មទាំង១២។ ជាលទ្ធផលសហគមន៍កសិកម្ម បានធ្វើការបង្កើតនិងកែលំអរផែនការមុខជំនួញដែលអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងសមាជិករបស់សហគមន៍។ ក្រៅពីការកសាងផែនការជំនួញសហគមន៍គម្រោងក៏បានផ្តល់ការបង្វឹកជំនាញធ្វើជំនួញទៅដល់សមាជិកជាលក្ខណៈឯកជន ដើម្បីលើកកំពស់ការប្រើប្រាស់កំចីពីសហគមន៍អោយបានត្រឹមត្រូវ។ សមាជិកសហគមន៍ក៏អាចទទួលកំចីដើម្បីយកទៅពង្រីកមុខរបរខ្លួនផងដែរ។ ៦៣% នៃសមាជិកសហគមន៍កសិកម្មរាយការណ៍មកថា ទទួលបានកំចីពីសេវាឥណទានរបស់សហគមន៍កសិកម្មជាមួយនឹងទឹកប្រាក់ជាមធ្យម ១៩៥ដុល្លារក្នុងសមាជិកម្នាក់ ដែលមានអត្រាការប្រាក់ទាបបើធៀបទៅនឹងភ្នាក់ផ្តល់ឥណទានផ្សេងៗនៅទីនោះ។ គោលបំណងធំៗនៃការប្រើប្រាស់កំចី គឺដើម្បីធ្វើលើមុខរបរចិញ្ចឹមសត្វ ដំណាំស្រូវ រៀបចំជំនួញខ្នាតតូច និងការដាំបន្លែ។

ជាងនេះទៅទៀត ៦៣%នៃសមាជិកដែលយកកំចីពីសហគមន៍យកទៅរកស៊ីបានទទួលប្រាក់ចំនេញ ហើយ២៧% រកស៊ីបានរួចថ្លៃដើម និង១០%មានការខាត ដោយសារមុខជំនួញចិញ្ចឹមជ្រូកជួបបញ្ហាផ្ទុះជំងឺជ្រូកងាប់ ហើយដំណាំរងនូវសត្វល្អិតបំផ្លាញធ្វើអោយខូចទិន្នផល។ ក្នុងឆ្នាំនេះសហគមន៍កសិកម្ម៩បានរៀបចំការប្រជុំដើម្បីកសាងផែនការមុខជំនួញដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារនិងសមាជិក។ សមាជិកសហគមន៍៣៦០នាក់បានទទួលសេវាផ្គត់ផ្គង់ធាតុចូលកសិកម្មយកមកប្រើប្រាស់បានថោកជាងមុន ព្រោះតំលៃនៃការទិញរួមតាមរូបភាពសហគមន៍គឺអាចថោកជាងការទិញរាយបើធៀបទៅលើតម្លៃទីផ្សា។ ម្យ៉ាងវិញទៀតអាត្រាការប្រាក់ថោកតាមរយៈកំចីពីសហគមន៍ក៏ជាលទ្ធភាពល្អសម្រាប់កសិករអាចទទួលបានប្រាក់កំចីយកទៅពង្រីកមុខរបរកសិកម្មអោយកាន់តែធំជាងមុន។

គម្រោងបានរៀបចំវគ្គរំលឹកឡើងវិញអំពីការវិភាគ និងសិក្សាពីតម្រូវការទីផ្សារ គណនេយ្យ ផែនការជំនួញហើយនឹងការប្រតិបត្តិមុខជំនួញទៅដល់សហគមន៍កសិកម្មទាំង៩។ ដោយមានការសំណូមពរពីកសិករ គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលទៅលើការបន្សុាំការប្រែប្រួលអាកាសធាតុ ក្នុងវិស័យដាំដុះទៅដល់ថ្នាក់ដឹកនាំសហគមន៍ទាំង១២ ដែលមានអ្នកចូលរួម ៨៩នាក់ ស្រី៣៧នាក់។ ក្រោយពីបញ្ចប់វគ្គគម្រោងក៏បានជួយគាំទ្រដល់គណៈកម្មការសហគមន៍ដែលមានចំណេះដឹងពីវគ្គបន្តយកចំណេះដឹងទៅជួយដល់កសិករជាសមាជិកអោយជៀសផុតពីបញ្ហាការប្រែប្រួលអាកាសធាតុនេះដែរ។ សិក្ខាសាលាចំនួន៣អំពីយន្តការ និងទម្រង់ការដើម្បីជាការទំនាក់ទំនងរវាងកសិករជាសមាជិកសហគមន៍កសិកម្មក្នុងខេត្តសៀមរាប បានរៀបចំឡើង ដែលមានតំណាងគណកម្មការសហគមន៍ទាំង៨៩រូប ក្នុងស្រី៣៧រូប ហើយក្រុមប្រឹក្សាឃុំមកពីឃុំទាំង១២ និងមន្ត្រីមន្ទីរជំនាញ២រូបចូលរួម។ សហគមន៍៩ក្នុងចំនោម១២ ថ្នាក់ដឹកនាំសហគមន៍បានកែលំអរការគ្រប់គ្រងទាំងមុខជំនួញ និងរដ្ឋបាល។ គណកម្មការសហគមន៍៧ក្នុងចំនោម ១២បានកែលំអរជំនាញការដឹកនាំជំនួញហើយនឹងការគ្រប់គ្រងសហគ្រឹនសង្គម។

ថ្នាក់ដឹកនាំសហភាពទាំងអស់បានបញ្ចប់វគ្គបណ្តុះបណ្តាលលើការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ៧០% នៃពួកគាត់បានយល់ច្បាស់ពីគោលការណ៍ក៏ដូចជាស្មារតីនៃចលនារបស់សហភពសហគមន៍កសិកម្ម។ ថ្នាក់ដឹកនាំសហភាពក៏ដូចជាសហគមន៍ទាំង១២ដែលជាសមាជិកបានចូលរួមនូវរាល់សិក្ខាសាលាឆ្លុះបញ្ចាំង ព្រមទាំងទទួលបាននូវឯកសារពាក់ព័ន្ធនឹងច្បាប់មានប្រយោជន៍ជាច្រើនប្រភេទជុំវិញដំណើររបស់សហភាព។ ជាទូទៅគ្រប់គណកម្មកាទាំងអស់មកពីសហគមន៍ទាំង១២ ធ្លាប់បានចូលរួមយ៉ាងហោចណាស់៥ ព្រឹត្តការណ៍សំខាន់ៗដែលអញ្ជើញដោយមន្ទីរឬក៏ក្រសួងជុំវិញការងារដឹកនាំគ្រប់គ្រងសហគមន៍កសិកម្ម។ សហគមន៍២ក្នុងចំណោម១២បានជ័យលាភីទទួលបានអំណោយគោយន្តពីក្រសួងចំនួន១គ្រឿងក្នុងសហគមន៍។ បច្ចុប្បន្ន សហគមន៍៧ក្នុងចំនោម១២កំពុងតែផុសផុលលើជំនួញឥណទានក្នុងសហគមន៍ជាផ្នែកមួយនៃមុខជំនួញសហគមន៍។ ហើយសហគមន៍ខ្លះក៏មានលទ្ធភាពយកកំចីពីស្ថាប័នក្រៅដើម្បីមកប្រតិបត្តិការផ្តល់ឥណទានខ្នាតតូចដល់សមាជិកខ្លួនផងដែរ។

| | |
|---|---|
| **ទី៩៖ការដាំដំនាំតាមគោលការណ៍សរីរាង្គ និងគោលការណ៍ដំណាំការពារបរិស្ថាន រួមជាមួយការណែនាំនូវបច្ចេកទេសដាំដំ ណាំដែលសន្សំសំចៃទឹក ព្រមទាំងការ បណ្តុះបណ្តាលកសិករអោយសម្រប ទៅនឹងការប្រែប្រួលអាកាសធាតុ** | • កសិកដ្ឋានគម្រូបង្ហាញពីគោលការណ៍សរីរាង និងកសិដ្ឋានបែបការពារបិរស្ថាន ត្រូវបានរៀបចំ១កន្លែងដោយមានការគាំទ្របច្ចេកទេសនិងឯកភាពពីមន្ទីរកសិកម្មខេត្ត<br>• កសិករទទួលបានការបណ្តុះបណ្តាលពីគោលការណ៍ដំណាំ សរីរាង្គ និងកសិដ្ឋានបែបការពារបរិស្ថាន<br>• កសិករទទួលបានការបណ្តុះបណ្តាលពីគោលការណ៍រៀបចំដំណាំដែលសន្សំសំចៃទឹកដើម្បីសម្របទៅនឹងការប្រែប្រួលអាកា សធាតុ (លក្ខខ័ណ្ឌទឹកភ្លៀងមិនគ្រប់គ្រាន់)<br>• កសិករមានចំណេះដឹងពីការសន្សំសំចៃទឹក ហើយចំនួនស្រះទឹក ឬប្រព័ន្ធរក្សាស្តុកទឹកត្រូវបានបង្កើន៣០%ធៀបពីមុន |

<table>
<tr><td></td><td>

• ផលិតកម្មដំណាំ ហើយនឹងបច្ចេកទេសប្រើប្រាស់ជីកំប៉ុសនិងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតចង្រៃបែបធម្មជាតិកើនឡើង ៣០% ធៀបនឹងពេលមុន

</td></tr>
<tr><td colspan="2">លទ្ធផលសម្រេចបានឆ្នាំ ២០១៧</td></tr>
<tr><td colspan="2">កសិករតែងតែខ្វះមូលដ្ឋានចំណេះដឹងទៅលើជំនញាប្រើប្រាស់ និងគ្រប់គ្រងទឹកលើកសិដ្ឋានដំណាំបានអស់សក្តានុពលដើម្បីបម្រើការស្រោចស្រព្វតាមរូបភាពដែលសន្សំសំចៃទឹក ក៏ដូចជាវិធីបំលែងកាកសំណល់អោយទៅជាមានប្រយោជន៍ក្នុងវិស័យកសិកម្ម។ ពួកគាត់សុខចិត្តទិញផលិតផលស្រាប់ដែលខ្ជះខ្ជាយថវិកាហើយជារបស់មានសារធាតុគីមីគ្រោះថ្នាក់ក៏ដោយជាជាងកែច្នៃរបស់ធនធានដែលមានស្រាប់អោយមានប្រយោជន៍។ ដូច្នេះគម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលមានប្រយោជន៍ជាច្រើនទៅដល់ថ្នាក់ដឹកនាំរបស់សហគមន៍កសិកម្មទាំង១២ ដើម្បីអោយពួកគាត់អាចបន្តផ្សព្វផ្សាយចែករម្លែកទៅកាន់សមាជិករបស់គាត់ពេលក្រោយ។ ជាញឹកញាប់សមាជិកដែលទិញជីពីសហគមន៍តែងតែសួរសំនួរពីរបៀបប្រើប្រាស់ជី ប៉ុន្តែពេលខ្លះយើងសង្កេតឃើញថាអ្នកទទួលខុសត្រូវគ្រប់គ្រងជំនួញជីនេះមិនទាន់បានឆ្លើយសំនួររបស់អ្នកប្រើប្រាស់បានត្រឹមត្រូវនៅឡើយ។ ជាការឆ្លើយតបនឹងក្តីកង្វល់នេះ គម្រោងបានទាក់ទងទៅក្រុមហ៊ុនដែលផ្គត់ផ្គង់ជី ហើយនឹងមន្ត្រីជំនាញពីមន្ទីរកសិកម្មមកផ្តល់វគ្គបណ្តុះបណ្តាលតាមសហគមន៍នីមួយៗ ទៅលើការគ្រប់គ្រងប្រើប្រាស់ជីនិងថ្នាំពុលកសិកម្មទៅដល់ថ្នាក់ដឹកនាំសហគមន៍២០៧នាក់ ក្នុងនោះស្រ្តី១២៥នាក់។ ក្រោយចប់វគ្គ ហើយមានការចុះតាមដានទៅលើករណីនេះ អ្នកចូលរួមភាគច្រើនបានបញ្ជាក់ថាវគ្គបណ្តុះបណ្តាលពីប្រធានបទនេះពិតជាជួយបង្កើនចំណេះដឹងពួកគាត់ដែលមាន៦០%នៃអ្នកចូលរួមបានយល់ពីការប្រើប្រាស់ត្រឹមត្រូវ ហើយពួកគាត់អាចពន្យល់និងណែនាំទៅដល់កសិករដ៏ទៃពីវិធីប្រើប្រាស់ជីនិងថ្នាំគីមីបានត្រឹមត្រូវតាមក្បួនបច្ចេកទេស។ ឯកសារបណ្តុះបណ្តាលមួយសេរីបានផ្តល់ជូនជុំវិញប្រធានបទការដាំដុះបែបសរីរាង្គនិងការដាំដុះដែលធ្វើអោយប្រសើរដល់បរិស្ថាន ត្រូវបានរៀបចំដោយមានការឯកភាពពីមន្ទីរជំនាញផងដែរ ពោលគឺឯកសារចំលងមេរៀនត្រូបានត្រូវបានផ្តល់ជូនដល់សិក្ខាកាមក្រោយវគ្គបណ្តុះបណ្តាល។ កសិករ២១០៦នាក់ ក្នុង២៥០០នាក់មកពី ១២សហគមន៍ និងក្រុមសន្សំប្រាក់ចាស់ថ្មី២៥ក្រុមក៏ទទួលបាននូវវគ្គបណ្តុះបណ្តាលនេះផងដែរ។ ក្រៅពីវគ្គនេះកសិករ ២១០៦នាក់ក្នុងចំនោម ២៥០០នាក់ក៏ទទួលបានការបណ្តុះបណ្តាល និងការផ្សព្វផ្សាយអំពីប្រធានបទប្រសិទ្ធិភាពនៃការគ្រប់គ្រងនឹងប្រើប្រាស់ទឹកលើការដាំដុះ ដែលអាចសម្របទៅនឹងងការប្រែប្រួលអាកាសធាតុ។ ២៥% នៃកសិករ២១០៦នាក់ដែលទទួលបានការបណ្តុះបណ្តាលរាយការណ៍មកថាមានការកើនឡើងនូវការគ្រប់គ្រងសមត្ថភាពស្តុកទឹក ដូចជាការបង្កើនចំនួនពាងឬធុងទឹកដើម្បីប្រមូលទឹកភ្លៀងរក្សាទុកសម្រាប់ប្រើប្រាស់ក្នុងខែប្រាំង ហើយនឹងស្តារស្រះទឹកអោយមានសមត្ថភាពបង្រុងទឹកដើម្បីបំលែងជាប្រព័ន្ធដំណក់ទឹកសម្រាប់ស្រោចស្រព្វស្ពួនដំណាំ។ ៣០%នៃកសិករ២១០៦នាក់ដែលទទួលបានការបណ្តុះបណ្តាលមានការថយចុះការប្រើប្រាស់ថ្នាំគីមី ឬបានប្រើជីនិងថ្នាំគីមីត្រឹមត្រូវតាមបច្ចេកទេស ហើយកសិករខ្លះងាកមកប្រើបច្ចេកទេសតាមបែបធម្មជាតិជំនួសវិញដោយបានបទពិសោធន៍ពីវគ្គបណ្តុះបណ្តល។ កសិដ្ឋានបង្ហាញគម្រូពីការប្រើប្រពន្ធដំណក់ទឹកចំនួន ៩ កន្លែងត្រូវបានរៀបចំនៅតាមសហគមន៍ទាំង១២ ហើយតាមរយៈកសិដ្ឋានគម្រូនេះវាបានផ្តល់ការបង្ហាញទៅដល់កសិករ២២៥នាក់បានចូលរួមរៀនសូត្រយកបទពិសោធន៍ទៅលើទីវាលនៃកសិកដ្ឋានគម្រូនេះផ្ទាល់តែម្តង។</td></tr>
<tr><td colspan="2">បទពិសោធន៍ឬមេរៀនដែលរៀនសូត្រពីគម្រោង</td></tr>
</table>

ចរន្តជំនួញបែបសហគមន៍កសិកម្មគឺកំពុងមានសក្តានុពល ប៉ុន្តែសហគមន៍តាមតំបន់គោលដៅហាក់មានសំទុះយឺតដើម្បីចាប់យកឱកាសនេះ។ តួយ៉ាងដូចជាផលិតកម្មកែច្នៃត្រីឆ្អើដែលគម្រោងបានជួយជ្រោមជ្រែង ឃើញថាផលិតកម្មនៅមានបរិមាណតូចដែលធ្វើអោយទទួលបានប្រាក់កំរៃស្តួចស្តើង។ ហើយម្យ៉ាងវិញទៀតមុខជំនួញប្រភេទនេះងាយអ្នកដ៏ទៃដែលមានធនធានច្រើនចម្លងយកទៅរកស៊ីដែរនៅពេលដែលពួកគាត់មើលឃើញពីឱកាសរបស់វា។ នេះជាការគម្រាមគម្លែងយ៉ាងខ្លាំងសម្រាប់ការចាប់ផ្តើមមុខជំនួញរបស់សហគមន៍ ស្រដៀងគ្នាចឹងដែរ មុខរបរទិញលក់ស្រូវរបស់សហគមន៍ ដូចជាសហគមន៍នៅសំរោងយា ដោយធ្វើការប្រមូលទិញស្រូវពីសមាជិកក្នុងឆ្នាំ២០១៥ ក្នុងកម្រិតសមត្ថភាពតូចតាចហើយកែច្នៃយកទៅលក់ដើម្បីបង្កើនប្រាក់ចំណេញ។ មើលឃើញរបៀបរកស៊ីនេះថាកាក់កបមានទីផ្សារ ឈ្មួញក្នុងតំបន់គោលដៅក៏ចាប់ផ្តើមប្រមូលទិញពីកសិករដែលមិនមែនជាសមាជិកសហគមន៍ ហើយកែច្នៃមកលក់ប្រកួតជាមួយសហគមន៍ ហើយឈ្មួញមានទុនបង្វិលច្រើនដែលអាចទូទាត់អោយកសិករដែលលក់ស្រូវបានភ្លាមៗ ហើយពេលខ្លះឈ្មួញបានកក់លុយអោយមុនក៏មាន។ កត្តានេះជាឧបសគ្គដែលរារាំងមិនអោយកសិករចាប់អារម្មណ៍មកចូលរួមក្នុងជំនួញរបស់សហគមន៍ ហើយមានទាំងសមាជិកសហគមន៍ក៏បានចាកចេញហើយរត់ទៅលក់ស្រូវអោយឈ្មួញកណ្តាលវិញដដែល។ យ៉ាងណាក៏ដោយ គម្រោងនៅតែអាចមានលទ្ធភាពជួយដល់សហគមន៍ដើម្បីប្រកួតជាមួយនឹងឈ្មួញសម្រាប់ការរកស៊ីយូរអង្វែង ដោយជួយអោយសហគមន៍មានឯកទេស ដូចជារៀបចំផលិតផលអោយមានផ្លាកសញ្ញាសំគាល់ផលិតផលត្រឹមត្រូវ។ ពង្រឹកសមត្ថភាពដើម្បីភ្ជាប់ទៅក្រុមហ៊ុនដែលប្រមូលទិញផលិតផលផ្ទាល់តាមរូបភាពបញ្ជាទិញឬដោយកក់ប្រាក់ជាមុន។ គម្រោងក៏គិតបានពិចារណាជួយដល់ការវេចខ្ចប់ដែលអាចនាំនាំទៅកាន់ទីផ្សារបាន។ ហើយគម្រោងមើលឃើញថា មានចំណេះដឹងតែលើការដាំដុះតែប៉ុណ្ណឹងមិនគ្រប់គ្រាន់ដើម្បីផ្លាស់ប្តូរជីវភាពនិងសេដ្ឋកិច្ចកសិករក្រីក្របានឡើយ ប៉ុន្តែកសិករក្រីក្រត្រូវធ្វើសមាហរណកម្មចូលទៅក្នុងក្រុមឬប្រព័ន្ធ ដើម្បីអោយពួកគាត់អាចរៀនសូត្រហើយនឹងជួយគ្នាទៅវិញទៅមក និងរួមកម្លាំងគ្នាដើម្បីមានសម្លេងគ្រប់គ្រាន់ដើម្បីជជែករកផលប្រយោជន៍អោយក្រុម។ ឧបករណ៍ HRBA ក្នុងបរិបទនេះពិតជាអាចក្លាយជាឧបករណ៍ពង្រឹងអំណាចផ្នែកសង្គមសម្រគ្រួសារក្រីក្រ នៅពេលដែលពួកគាត់យល់ពីតម្រូវការដែលពួកគាត់គួត្រូវបានស្នើឡើងដើម្បីអោយពួកគាត់អាចបន្តដំណើរទៅមុខបាន។ ជាការសន្និដ្ឋានរួម គម្រោងបានរៀនសូត្រថាមានចំណេះជំនាញផ្នែកកសិកម្មតែម្យ៉ាងគឺមិនគ្រប់គ្រាន់ឡើយ (បើយោងទៅលើការពង្រឹងសមត្ថភាពសេដ្ឋកិច្ច) កសិករពិតជាមិនអាចធ្វើការផ្លាស់ប្តូរជីវភាពនិងសេដ្ឋកិច្ចពួកគាត់បានដោយប្រសិទ្ធិភាពទេ ប៉ុន្តែមានតែធ្វើការបញ្ចូលគ្នារវាងចំណេះជំនាញទៅនឹងការប្រើប្រាស់សិទ្ធិរបស់ពួកគាត់អោយបានពេញលេញ (យោងទៅលលការពង្រឹងសមត្ថភាពផ្នែកសង្គមកិច្ច) ទើបកសិករអាចធ្វើការផ្លាស់ប្តូរនិងកែលំអរស្ថាបនភាពជីវភាពនិងសេដ្ឋកិច្ចរបស់ពួកគាត់បានដោយប្រសិទ្ធិភាពនិងនិរន្តរភាព។

*គម្រោងទី២*

<u>គោលបំណងទី១៖</u> នៅក្រោយថ្ងៃ ៣០ មិថុនាឆ្នាំ២០១៨ យ៉ាងហោចណាស់ប្រជាសហគមន៍ ចំនួន ១០០ គ្រួសារ នៅភូមិចំនួន៦ យ៉ាងតិចក្នុងចំណោមភូមិគោលដៅសរុបចំនួន៨ភូមិ ក្នុង ឃុំខ្នងភ្នំមានការកើនឡើងនូវប្រាក់ចំណូល ២៥%ធៀបនឹងពីមុនតាមរយៈ (CSA) និង (CA) និង ៥០ នាក់(ស្រ្តី២៥នាក់) ទទួលចំណេះដឹងបន្ត។

<u>គោលបំណងទី២៖</u> នៅក្រោយថ្ងៃ៣០ មិថុនា ឆ្នាំ២០១៨ ដីតំបន់ក្បាលជប់ទឹកសំខាន់ៗចំនួន៨ ក្នុង៦ភូមិ ដែលមានផ្ទៃដីសរុបចំនួន ៩៩ហិចតា ត្រូវបានការពារជាផ្លូវការ ដោយមានការដឹង ឮទទួលស្គាល់ពីប្រជាជនក្នុងភូមិ ក្រុមប្រឹក្សាឃុំ អង្គភាពឧទ្យានុរក្សឧទ្យានជាតិព្រះជ័យវរ្ម័ននរោត្តមភ្នំគូលែន មន្ទីរបរិស្ថាន និងរដ្ឋបាលខេត្តសៀមរាប។

<u>គោលបំណងទី៣៖</u> នៅក្រោយថ្ងៃ៣០ មិថុនា ឆ្នាំ២០១៨ ចំណេះដឹង និងបទពិសោធន៍ជោគជ័យ ត្រូវបានចែករំលែក ចងក្រង សំរាប់អនុវត្តបន្តរដោយសហគមន៍ និងភាគីពាក់ព័ន្ធ

**១. សេចក្តីសង្ខេបពីស្ថានភាពគម្រោងតាំងពីចាប់ផ្តើមអនុវត្តរហូតមកដល់ពេលរាយការណ៍៖**

នៅក្នុងពាក់កណ្តាលនៃគំរោងនេះ ការចាប់ផ្តើមមានការយឺតយ៉ាវលើផ្នែកការរៀបចំផែនការសកម្មភាព ថវិការ និងការជួបប្រជុំជាមួយភាគីពាក់ព័ន្ធ សំរាប់ការចូលរួមអនុវត្តគំរោង។ តែអង្គការកែប្រែសហគមន៍បានបង្កើនល្បឿនអនុវត្តសកម្មភាពគំរោងនៅខែទី ៤តមក។ សំរាប់ជាយុទ្ធសាស្ត្រសហការ អង្គការកែប្រែសហគមន៍បានធ្វើការជាដៃគូជាមួយការិយាល័យឧទ្យានុរក្ស ភ្នំគូលែន អាជ្ញាធរអប្សរា ក្រុមប្រឹក្សាឃុំខ្នងភ្នំ និង អង្គការ TCO, OOO និង ANKO។ ដោយសារការរៀបចំផែនការ ការពង្រាងខិត្តប័ណ្ណគំរោង ផ្លាកសញ្ញាគំរោង ត្រូវការពេលវេលាច្រើន អង្គការកែប្រែសហគម៍ក៏បានគៀងគរបុគ្គលិកគំរោងផ្សេងមកអោយជួយការងារនេះផងដែរ។ សំរាប់ការងារតាមដានជាពិសេសផ្នែកកសិកម្ម មន្ត្រីការិយាល័យឧទ្យានុរក្សភ្នំគូលែនបានជួយអនុវត្តដោយស្មារតីចូលរួមសហការល្អ។ អង្គការកែប្រែសហគមក៏បានសហការជាមួយគណៈកម្មការសហគមន៍តំបន់ការពារក្នុងការចុះរក កំណត់ទីតាំង និងព្រំប្រទល់ក្បាលទឹកជប់សំរាប់ការពារ និងអភិរក្ស។ គំរោងក៏បានធ្វើការជាមួយប៉ុស្តប៉ូលីស ក្នុងការជូនដំណឹង រៀបចំការប្រជុំផ្សព្វផ្សាយដល់អាជីវករក្នុងតំបន់ទឹកធ្លាក់អំពីគោលបំណងគំរោងក្នុងការអភិរក្សតំបន់ក្បាលទឹកជប់ ដែលមានប្រយោជន៍សំរាប់ទាំងអស់គ្នា។ អង្គការកែប្រែសហគមក៏បានសហការជាមួយក្រសួងបរិស្ថាន តាមរយៈមន្ទីរបរិស្ថានខេត្តសៀមរាបក្នុងការចូលរួមរៀបចំការដាំកូនឈើឡើងវិញ។ សំរាប់ផ្នែកជីវភាព និងក្បៀតបរិស្ថាន គំរោងបាន សិក្សានិងសហការជាមួយកសិករគំរូក្នុងឃុំ ក្នុងការផលិតផ្គត់ផ្គង់ពូជសត្វក្នុងស្រុកដល់កសិករគោលដៅ។ តាមបទពិសោធន៍របស់អ្នកភូមិ ពូជសត្វក្នុងស្រុកអាចមានភាពបន្សាំបានល្អទៅតាមបរិយាកាស និង ការប្រែប្រួលអាកាសធាតុនៅលើតំបន់ខ្នងភ្នំ ហើយពូជសត្វដែលនាំចូលពីក្រៅភាគច្រើនមិនអាចបន្សាំបាន ហើយឆាប់ស្លាប់។ តាំងពីចាប់ផ្តើម រហូតមកដល់ពាក់កណ្តាលគំរោងនេះ គំរោងទទួលបានលទ្ធផលចំបងៗដូចខាងក្រោមៈ

- នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ នៅការិយាល័យ UNDP ភ្នំពេញ ចូលរួមការប្រជុំណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុគម្រោងចំនួន១ថ្ងៃ មានអ្នកចូលរួមពីអង្គការដៃគូ ANKO, CTO, OOO, TCO និង CRID។ សរុបចំនួន១០នាក់ ទម្រង់កត់ត្រា និងគោលការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញ និងធ្វើការណែនាំដោយលោកស្រី គឹម សុជាតា ជាបុគ្គលិកជំនួយការកម្មវិធីនៃUNDP។ បុគ្គលិកគម្រោង, ហិរញ្ញវត្ថុ និង គណនេយ្យករបានទទួលនូវចំណេះដឹង និងមានសមត្ថភាពអាចកត់ត្រា ប្រតិបត្តិការ និងចុះបញ្ជីការ គណនេយ្យ។
- ថ្ងៃទី២៣-២៤ ខែកុម្ភៈ ឆ្នាំ២០១៧ នៅការិយាល័យ UNDP ភ្នំពេញចូលរួមការប្រជុំណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុគម្រោងចំនួន២ថ្ងៃ មានអ្នកចូលរួមពីអង្គការដៃគូ ANKO, CTO, OOO, TCO និង MAFF សរុបចំនួន១៥នាក់។ ទម្រង់កត់ត្រា និងគោលការណ៍ហិរញ្ញវត្ថុ រួមទាំងការធ្វើរបាយការណ៍រីកចម្រើន និងបញ្ចប់ត្រូវបានបង្ហាញ និងធ្វើការណែនាំដោយលោកស្រី គឹម សុជាតា ជាបុគ្គលិកជំនួយការកម្មវិធី និងលោកស្រី ងិន ណារីរៈ ជាមន្ត្រីសម្របសម្រួលកម្មវិធីជំនួយខ្នាតតូចនៃUNDP។ បុគ្គលិកគម្រោង, ហិរញ្ញវត្ថុ និងគណនេយ្យករបានទទួលនូវចំណេះដឹង និងមានសមត្ថភាពអាចកត់ត្រា ប្រតិបត្តិការ និងចុះបញ្ជីការគណនេយ្យ រួមទាំងការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍លទ្ធផល នៃការអនុវត្តន៍គម្រោងបាន។
- នៅថ្ងៃទី៨-១១ ខែមីនា ឆ្នាំ២០១៧ នៅការិយាល័យ UNDP ភ្នំពេញ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការតស៊ូមតិដែលមានអ្នកចូលរួម ពីអង្គការដៃគូ ANKO, CTO, CTA, OOO, TCO និង MAFF សរុបចំនួន ២៣នាក់។
- ដោយមានការសហការរៀបចំពិធីប្រកាសបើកគម្រោងរួមគ្នាជាមួយអង្គការដៃគូ TCO, OOO និង ANKO ក្រោមអធិបតីភាពតំណាងអភិបាលខេត្ត និងមន្ទីរវិស័យពាក់ព័ន្ធសំខាន់ៗ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ នៅសាលាស្រុកស្វាយលើ បានរៀបចំឡើងនូវពិធីសម្ពោធគម្រោង ដែលមានអ្នកចូលរួមសរុប៩១នាក់ ស្រី១៤នាក់ ក្នុងនោះលោក នួន មុនី ប្រធានមន្ទីរបរិស្ថានតំណាងគណៈអភិបាលខេត្តជាគណៈអធិបតី លោកឡុង រតនៈកុមារ សមាជិកគណៈកម្មាធិការគ្រប់គ្រងជំនួយខ្នាតតូចជាគណៈអធិបតី លោកយោ សុផានី សមាជិកក្រុមប្រឹក្សាស្រុកស្វាយលើជាគណៈអធិបតី លោកសួរ សុន អភិបាលនៃគណៈអភិបាលស្រុកបន្ទាយស្រីជាគណៈអធិបតី លោកសំ សៅ អភិបាលរងនៃគណៈអភិបាលស្រុកស្វាយលើជាគណៈ អធិបតី

និងមានតំណាងមន្ទីរ អង្គភាពពាក់ព័ន្ធនានា៥នាក់ ព្រះចៅអធិការវត្តចំនួន២អង្គក្រុមប្រឹក្សាឃុំខ្នងភ្នំ, ស្វាយលើនិងតែ្បងចំនួន៣នាក់ មេភូមិអនុភូមិ សមាជិកភូមិ១០នាក់គណៈកម្មការ និងសមាជិកសហគមន៍ ៥៥នាក់ បុគ្គលិកអង្គការ ដៃគូ UNDP ១១នាក់។

- ប្រជាជន អាជីវករ មន្ត្រីប៉ូលីស ក្រុមប្រឹក្សាឃុំ ការិយាល័យឧទ្យានុរក្ស និង សិស្សទទួលបានព័ត៌មាន និងការអប់រំតាមរយៈការចូលរួមផ្ទាល់ផង តាមរយៈខិតប័ណ្ណផង ផ្លាកសញ្ញាគំរោងផង និងការអនុវត្តជាក់ស្តែងផងដូចជារការដាំកូនឈើ ការរុករក និងកំណត់ព្រំតំបន់ក្បាលទឹកជប់ផង មានការយល់ដឹងអំពីសារៈសំខាន់ក្នុងការការពារ និងអភិរក្សាតំបន់ក្បាលទឹកជប់ ហើយប្រជាជនបានស្ម័គ្រចិត្តប្រគល់តំបន់ក្បាលទឹកជប់មកទុកជាតំបន់អភិរក្សវិញ។
- ផ្លាកសញ្ញាគំរោងចំនួន ៩ ត្រូវបានតំឡើងរួចរាល់ក្នុងភូមិសាស្ត្រគោលដៅគំរោង
- គំរោងបានស្រង់ទិន្ន័យពេញលេញអំពីព័ត៌មាន និងចំនួនគ្រួសារដែលបាន់កាន់កាប់តំបន់ដីក្បាលទឹកជប់ ហើយពួកគាត់យល់ព្រម ប្រគល់តំបន់នេះមកជាតំបន់អភិរក្សវិញ។ សរុបទាំង៦ភូមិមាន៣៩ក្បាលទឹកជប់ និងមាន១០១គ្រួសារពាក់ព័ន្ធមានដីចំការ ២៤១,៨៥ហ.ត
- សំរាប់ជីវភាពសហគមន៍៥៩គ្រួសារក្រីក្រ និងគ្រួសារដែលមានការពាក់ព័ន្ធតំបន់ក្បាលទឹកជប់ត្រូវបានទទួលនូវការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម បញ្ជ្រាបពីទស្សនទាន នៃការអនុវត្តក្សេត្របរិស្ថានបែបច្នៃប្រឌិតឆ្លាតវៃតាមលក្ខខណ្ឌអាកាសធាតុ និងកសិកម្មបែបអភិរក្ស និងមានការយល់ដឹងពីសារៈសំខាន់ នៃប្រភពទឹក ធនធានព្រៃឈើ និងផលវិបាកនាំឱ្យប៉ះពាល់ដល់ផលិតកម្ម សុខភាពជីវភាពដែល បណ្តាលមកពីការបំផ្លិចបំផ្លាញធនធានធម្មជាតិបរិស្ថានដោយការកាប់ឆ្ការព្រៃ ការប្រើប្រាស់ថ្នាំពុលកសិកម្ម ជីគីមី កសិកម្មរួមទាំងភាពអសកម្មនៃការស្តារឡើងវិញ និងការមានវិធានការទប់ស្កាត់ប្រកបឆន្ទៈ ស្មារតីទទួលខុសត្រូវខ្ពស់ពីអ្នកប្រើប្រាស់ផ្ទាល់ ភាគីពាក់ព័ន្ធទាំងអស់ទេនោះគ្រួសារកសិករគំរូចំនួន៖
  - ៣៩គ្រួសារបានទទួលពូជជ្រូកកូនកាត់
  - ចំនួន៩គ្រួសារបានទទួលពូជមាន់ និង
  - ចំនួន១គ្រួសារបានទទួលពូជទាកាប៉ា
- ក្នុងគោលបំណងលើកទកចិត្ត ក៏ដូចជាការកសាងសមត្ថភាព និងភាពជាម្ចាស់ផងនោះ គណៈកម្មការគំរោងរួមមានបុគ្គលិកអង្គការកែប្រែសហគមន៍ តំណាងការិយាល័យឧទ្យានុក្សរ ក្រុមប្រឹក្សាឃុំ និងគណៈកម្មការសហគមន៍បានសំរេចជ្រើសរើសលោក នាងណេត ដែលជាសមាជិកគណៈកម្មការតំបន់ការពារសហគមន៍ មានបទពិសោធន៍ក្នុងការងារជាងស៊ីប៉ងតិ ជាអ្នកទទួលមៅការផលិតបង្គោលព្រំតំបន់ការពារទឹកជប់ចំនួន៤០០បង្គោល។ ដោយរៀបចំការដេញថ្លៃនៅការិយាល័យCTOដោយមានការចូលរួមពីគណៈកម្មការគំរោង។
- សំរាប់ការងាសហការ និងសំរបសំរួលគំរោងបានរៀបចំ កិច្ចប្រជុំប្រចាំត្រីមាសត្រូវបានរៀបចំឡើងនៅការិយាល័យCTOថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ក្នុងនោះមានការចូលរួមពីអង្គការ TCO, OOO, ANKO ក្រុមប្រឹក្សាឃុំមេភូមិ និង គណៈកម្មការ សហគមន៍មន្ត្រីឧទ្យានុរក្សសរុបចំនួន២១នាក់ស្រី០នាក់។

## ២. សកម្មភាពគម្រោងនានាដែលបានគ្រោង និងលទ្ធផលដែលសម្រេចបាននៅក្នុងរយៈពេលរាយការណ៍

<u>សកម្មភាព១.១.១</u> ខិតប័ណ្ណផ្សព្វផ្សាយស្តីពីការ ការពារ និងអភិរក្សតំបន់ក្បាលទឹកជប់ ការដាំ ឈើឡើងវិញ និងការអនុវត្តក្សេត្របរិស្ថានបែបច្នៃប្រឌិត ឆ្លាតវៃតាមលក្ខណ្ឌអាកាសធាតុ និងកសិកម្មបែបអភិរក្សទំហំA4 ចំនួន ៦០០ សន្លឹក, ទំហំA3 ចំនួន៣០សន្លឹក ត្រូវបានផលិត និង ចែកចាយជូនដល់ គណៈកម្មការ សមាជិក សហគមន៍ អាជ្ញាធរដែនដី និងបិតផ្សាយ តាមសាលារៀន និងតាមវត្តអារាម និងសាលាឆទាននានាគ្រប់ភូមិ។ ស្លាកសញ្ញាអប់រំដែលមានទំហំ1m X 1.5m ចំនួន៩ផ្ទាំង ធ្វើអំពីស័ង្កសី ស៊ុំដែក អ៊ុតរូបភាព សងខាងត្រូវបានផលិត និង

| |
|---|
| លើកស្លាកទាំងអស់ នៅតំបន់ទីប្រជុំជន តំបន់ទឹកធ្លាក់។ |
| <u>សកម្មភាព ១.១.២</u> ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ នៅវត្តអន្លង់ធំ មានអ្នកចូលរួមសរុប៦០នាក់ ស្រី៤៤នាក់, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ នៅវត្តអន្លង់ធំ មានអ្នកចូលរួមសរុប៦១នាក់ ស្រី៣៨នាក់, ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ នៅវត្តអន្លង់ធំ មានអ្នកចូលរួមសរុប៥៨នាក់ និងស្រី៣៥នាក់, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ នៅភូមិថ្មជ្រួញមានអ្នកចូលរួម សរុប៦០នាក់ និងស្រី៤៨នាក់, ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ នៅភូមិ ខ្លាឃ្មុំមានអ្នកចូលរួមសរុប៧៧នាក់ និងស្រី៣៩នាក់, ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ នៅសង្កែឡាក់ មានអ្នកចូលរួមសរុប៧៦នាក់ និងស្រី៣៩នាក់, ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ នៅតាពេញមានអ្នក ចូលរួមសរុប៧២នាក់ និងស្រី៣៩ នាក់, ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ នៅភូមិតាពេញ មានអ្នក ចូលរួមសរុប៥៧នាក់ និង ស្រី៣៣នាក់ បានរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយស្តីពី ការការពារតំបន់ ក្បាលទឹកជប់ និង ការអនុវត្ត ក្សេត្របរិស្ថានបែបច្នៃប្រឌិតឆ្លាតវៃ តាមលក្ខណ្ឌអាកាសធាតុ CSA និង កសិកម្មបែបអភិរក្សCA អ្នកចូលរួមបានយល់ដឹងពីសារៈសំខាន់ក្បាលទឹកជប់ ភាពគ្រោះថ្នាក់នៃការបាត់បង់ប្រភពទឹក និង ព្រៃឈើ និង ការប្រើប្រាស់ថ្នាំពុលគីមី និង ជីគីមីជាដើម។ |
| <u>សកម្មភាព១.១.៣</u> លក្ខណៈវិនិច្ឆ័យចំនួន៦ត្រូវបានកំណត់បន្ទាប់ពីមានកិច្ចប្រជុំពិគ្រោះ យោបល់រវាងក្រុមប្រឹក្សាឃុំមេភូមិ មន្ត្រីឧទ្យានុរក្សនិងគណៈកម្មការសហគមន៍តាមបណ្តាភូមិគោលដៅទាំង៦រួចមករួមមាន៖ កសិករគំរូជាគ្រួសារក្រីក្រស្ត្រីមេម៉ាយ ជនពិការ មានការស្ម័គ្រចិត្ត មានទីលំនៅ អចិន្ត្រៃយ៍មិនមែនជាអ្នកទទួលផលគម្រោង ផ្សេងជាគ្រួសារពាក់ព័ន្ធតំបន់ក្បាលទឹកជប់ សមាសភាពចូលរួមប្រជុំទាំង៦លើកសរុប១៤០នាក់ ស្រី៥៣នាក់មកពី៦ភូមិគោលដៅរួមមាន៖ ភូមិអន្លង់ធំ, ថ្មជ្រួញ, ពពេល, តាពេញ, ខ្លាឃ្មុំ និង សង្កែឡាក់។ |
| <u>សកម្មភាព១.១.៤</u> របាយការណ៍ស្តីអំពីការសិក្សាបច្ចេកទេសសមស្រប (Feasibility study) លើក្សេត្របរិស្ថានបែបច្នៃប្រឌិតឆ្លាតវៃតាមលក្ខខណ្ឌអាកាសធាតុ និងកសិកម្មបែបអភិរក្ស ត្រូវបានរៀបចំសម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការអនុវត្តន៍សកម្មភាពគម្រោងនានា ដែលស្របតាម តម្រូវការជាក់ស្តែង ស្ថានភាពភូមិសាស្ត្របរិយាកាស ប្រភេទពូជ កសិកម្មផងដែរ។ |
| <u>សកម្មភាព១.១.៥</u> យោងតាមលក្ខណៈវិនិច្ឆ័យទាំង៦ដែលបានកំណត់ គណៈកម្មការជ្រើសរើសទាំង៦ភូមិ បានចុះតាមខ្នងផ្ទះពិនិត្យជាក់ស្តែង និងជ្រើសរើសបានកសិករគំរូចំនួន៤៧នាក់ តំណាងអោយ៤៧គ្រួសារ សម្រាប់ផ្តល់ការបណ្តុះបណ្តាល និង ពូជ សមាសភាពចូលរួមប្រជុំក្នុងការជ្រើសរើសមានសរុប១៣៨នាក់ ស្រី៥២ នាក់មកពីភូមិគោលដៅទាំង៦។ |
| <u>សកម្មភាព១.១.៦</u> វគ្គបណ្តុះបណ្តាលស្តីពី ក្សេត្របរិស្ថានបែបច្នៃប្រឌិតឆ្លាតវៃតាមលក្ខខណ្ឌអាកាសធាតុ CSA និង កសិកម្មបែបអធិរក្ស CA គឺមាន ការបណ្តុះបណ្តាលស្តីពីការជ្រើស រើសទីតាំង និង ការសង់ទ្រុង សត្វ រោងជីកំប៉ុស្តការជ្រើរើសពូជសត្វ ការចិញ្ចឹមសត្វ ការផលិត ចំណើ ការថែទាំ និង ព្យាបាលជម្ងឺ ដាំដំណាំបន្លែ និង ឈើហូបផ្លែជាដើម ត្រូវបានរៀបចំឡើងចំនួន៥ថ្ងៃ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ នៅអនុវិទ្យាល័យអន្លង់ធំ មានអ្នកចូលរួមសរុបចំនួន ៣២នាក់ ស្រី ១១នាក់ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ នៅ សាលាឃុំខ្នងភ្នំ មានអ្នកចូលរួមសរុបចំនួន៣៤នាក់ ស្រី១៩នាក់ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៧ នៅផ្ទះមេភូមិអន្លង់ធំ មានអ្នកចូលរួមសរុបចំនួន៣១នាក់ ស្រី១៨នាក់ នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧ នៅសាលាឆទានភូមិ ពពេល មានអ្នកចូលរួមសរុបចំនួន១៨នាក់ ស្រី១០នាក់ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ នៅផ្ទះមេភូមិ សង្កែឡាក់ មានអ្នកចូលរួមសរុបចំនួន១៨នាក់ ស្រី១០នាក់ ៧០% នៃសិក្ខាកាមមានការយល់ ដឹងពីទស្សទាន គោលគំនិត នៃ CSA និង CA ហើយអាចអនុវត្តន៍បាននូវបច្ចេកទេសដែលបានផ្តល់។ |
| <u>សកម្មភាព១.១.៧</u> ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ ២៤គ្រួសារ និង ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ២៥គ្រួសារ សរុបកសិករ៤៩គ្រួសារក្រីក្រ និងគ្រួសារដែលមានការពាក់ព័ន្ធតំបន់ក្បាលទឹកជប់ ត្រូវបានទទួលនូវការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម បញ្ជ្រាបពីទស្សនទាន នៃការអនុវត្តក្សេត្របរិស្ថាន បែបច្នៃប្រឌិតឆ្លាតវៃតាមលក្ខខណ្ឌ |

អាកាសធាតុ និងកសិកម្មបែបអភិរក្ស និងមានការយល់ដឹងពី សារៈសំខាន់នៃប្រភពទឹកធនធាន ព្រៃឈើ និងផលវិបាកនាំឱ្យប៉ះពាល់ដល់ផលិតកម្ម សុខភាពជីវភាពដែល បណ្តាលមកពីការបំផ្លិចបំផ្លាញធនធានធម្មជាតិ បរិស្ថានដោយការកាប់ឆ្ការព្រៃ ការប្រើប្រាស់ថ្នាំពុលកសិកម្ម ជីគីមីកសិកម្ម រួមទាំងភាពអសកម្ម នៃការស្តារ ឡើងវិញ និងការមានវិធានការ ទប់ស្កាត់ប្រកបឆន្ទៈ ស្មារតីទទួល ខុសត្រូវខ្ពស់ពីអ្នកប្រើប្រាស់ផ្ទាល់ ភាគីពាក់ព័ន្ធទាំងអស់ទនោះ គ្រួសារកសិករគំរូចំនួន៣៩គ្រួសារបានទទួលពូជជ្រូកកូនកាត់ចំនួន២ក្បាល/គ្រួសារ និង ចំនួន៩គ្រួសារបានទទួលពូជមាន់ ស្រុកចំនួន២០គ.ក្រ/គ្រួសារ និងចំនួន១គ្រួសារបានទទួលពូជ ទារកាប៉ាចំនួន២០គ.ក្រផងដែរ គ្រប់គ្រួសារកសិករគំរូទាំង៤៩គ្រួសារ បានទទួលលក្ខខ័ណ្ឌ និងមានការព្រមព្រៀងចូលរួមបដិភាគក្នុងការចំណាយកម្លាំងពលកម្ម និង ថវិកាសម្រាប់សង់ទ្រុងសត្វ។

<u>សកម្មភាព១.១.៨</u> បាន និងកំពុងអនុវត្តន៍ជាបន្តបន្ទាប់ ចុះតាមដានផ្តល់បច្ចេកទេសពេលអនុវត្តន៍ និងការលើកទឹកចិត្តដល់កសិករដែលអនុវត្តន៍ក្សេត្របរិស្ថានបែបច្នៃប្រឌិតឆ្លាតវៃតាមលក្ខខណ្ឌអាកាសធាតុ (CSA) និងកសិកម្មបែបអភិរក្ស (CA) និងផ្តល់យោបល់អំពីការប្រើប្រាស់ថ្នាំកសិកម្មប្រកបដោយសុវត្ថិភាពនៅតាមគ្រួសារកសិករគំរូទាំង៤៩គ្រួសារបានចំនួន៤លើក។

<u>សកម្មភាព១.១.១០</u> បាន និងកំពុងអនុវត្តន៍ជាបន្តបន្ទាប់ចុះត្រួតពិនិត្យតាមដាន និង វាយតំលៃអំពីប្រសិទ្ធភាពការអនុវត្ត និងលទ្ធផល និងចងក្រងករណីសិក្សា និង Lesson Learn ចំពោះគ្រួសារអនុវត្តបានជោគជ័យ និងបរាជ័យនៅតាមបណ្តារភូមិ។

<u>សកម្មភាព១.២.១</u> ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ ស្លាកសញ្ញាចំនួន៩ ត្រូវបានដឹកជញ្ជូនពីខេត្តសៀមរាប ទៅរក្សាទុកនៅសាលាឃុំដើម្បីចែកចាយ ជូនដល់សហគមន៍ទាំង៦ភូមិយកទៅលើកនៅតាមទីប្រជុំជនក្នុងភូមិ។ ថ្ងៃទី៣, ១០, ១៨ ខែកក្កដា ឆ្នាំ២០១៧ ស្លាកសញ្ញាទាំង៩ត្រូវបានដឹកជញ្ជូន និង លើកនៅភូមិអន្លង់ធំ, វីរៈកាត់, ពពេល, ខ្លាឃ្មុំ, សង្កែឡាក់, តាពេញ និង ថ្មជ្រួញទឹកធ្លាក់ព្រះអង្គធំ។

<u>សកម្មភាព២.១.៤</u> កូនឈើផ្ចង់កំពស់0.5m-0.7mចំនួន២.០០០ដើម កូនឈើគ្រញូង កំពស់0.3m-0.5m ចំនួន៥០០ ដើម និងកូនឈើគគី កំពស់0.3m-0.7m ចំនួន៥០០ដើម ត្រូវបានទិញ និងដឹកជញ្ជូន ទៅរក្សាទុកនៅលើខ្នង ភ្នំគូលែន ក្នុងនោះមានការបដិភាគពីមន្ទីរបរិស្ថានខេត្តសៀមរាបចំនួន១.៥០០ដើម។

<u>សកម្មភាព២.១.៥</u> នៅថ្ងៃទី២៤ មន្ត្រីឧទ្យានុរក្សចំនួន ១៨នាក់, ថ្ងៃទី២៧ មន្ត្រីឧទ្យា នុរក្ស ចំនួន១៣នាក់ ខែឧសភា ឆ្នាំ២០១៧ បានដាំកូនឈើទាំង ៣.០០០ដើម លើផ្ទៃដី១ហិចតា នៅតំបន់អូរស្មាច់ ភូមិវីរៈកាត់។

<u>សកម្មភាព២.២.១</u> ចុះសិក្សាអំពីចំនួនគ្រួសារ និងទំហំផ្ទៃដីពាក់ព័ន្ធនឹងតំបន់ទឹកជប់ និងទទួលបានលទ្ធផលដូចខាងក្រោមនេះ៖

- ភូមិអន្លង់ធំមានតំបន់ក្បាលទឹកជប់សំខាន់ៗចំនួន១២កន្លែង រួមមាន៖
  1. តំបន់ក្បាលទឹកជប់អូរអាឡឺអន្លង់ធំមាន៨គ្រួសារពាក់ព័ន្ធ មានដីចំការ១៥ហ.ត
  2. តំបន់ក្បាលទឹកជប់ស្ពានព្រីងមាន៧គ្រួសារពាក់ព័ន្ធមានដីចំការ៨ហ.ត
  3. តំបន់ក្បាលទឹកជប់ប្រាសាទអូរថ្មដាប់មាន៨គ្រួសារពាក់ព័ន្ធ មានដីចំការ៨ហ.ត
  4. តំបន់ក្បាលទឹកជប់អណ្តូងប្រេងមានច្រើនគ្រួសារពាក់ព័ន្ធតែមិនទាន់ប្រមូលបានទិន្នន័យនៅឡើយទេ
  5. តំបន់ក្បាលទឹកជប់អូរក្របីក្រាបមាន៤គ្រួសារពាក់ព័ន្ធ មានដីចំការ៤ហ.ត
  6. តំបន់ក្បាលទឹកជប់ពើងព្រះរូបគ្មានអ្នកពាក់ព័ន្ធទេ
  7. តំបន់ក្បាលទឹកជប់ពើងប្រចៀវគ្មានអ្នកពាក់ព័ន្ធទេ
  8. តំបន់ក្បាលទឹកជប់អូរហោលគ្មានអ្នកពាក់ព័ន្ធទេ
  9. តំបន់ក្បាលទឹកជប់អូរផ្អុងគ្មានអ្នកពាក់ព័ន្ធទេ
  10. តំបន់ក្បាលទឹកជប់អូរតាចក់គ្មានអ្នកពាក់ព័ន្ធទេ

11. តំបន់ក្បាលទឹកជប់អូរតូបគ្មានអ្នកពាក់ព័ន្ធទេ
12. តំបន់ក្បាលទឹកជប់ទំនប់ដាច់ និង ដីខ្មៅមាន៥គ្រួសារពាក់ព័ន្ធ មានដីចំការ៤០ហ.ត។

- ភូមិតាពេញមានតំបន់ក្បាលទឹកជប់សំខាន់ៗចំនួន៦កន្លែង រួមមាន៖
  1. តំបន់ក្បាលទឹកជប់អូរតាពេញមាន៧គ្រួសារពាក់ព័ន្ធ មានដីចំការ៣,៥ហ.ត
  2. តំបន់ក្បាលទឹកជប់តាហាស់មាន១គ្រួសារពាក់ព័ន្ធមានដីចំការ០,២៥ហ.ត
  3. តំបន់ក្បាលទឹកជប់គគីមាន៤គ្រួសារពាក់ព័ន្ធ មានដីចំការ៣ហ.ត
  4. តំបន់ក្បាលទឹកជប់ទឹកពុះមាន៣គ្រួសារពាក់ព័ន្ធមានដីចំការ២ហ.ត
  5. តំបន់ក្បាលទឹកជប់អណ្តូងលើមាន៣គ្រួសារពាក់ព័ន្ធមានដីចំការ០,៦០ហ.ត
  6. តំបន់ក្បាលទឹកជប់ក្បាលអូរមាន៣គ្រួសារពាក់ព័ន្ធមានដីចំការ២ហ.ត។
- ភូមិសង្កែឡាក់មានតំបន់ក្បាលទឹកជប់សំខាន់ៗចំនួន២ រួមមាន៖
  1. តំបន់ក្បាលទឹកជប់អណ្តូងតាម៉ិចទឹកទរមាន៩គ្រួសារពាក់ព័ន្ធមានដីចំការ ២២ហ.ត
  2. តំបន់ក្បាលទឹកជប់ដីដងអូរមាន២គ្រួសារពាក់ព័ន្ធមានដីចំការ២ហ.ត។
- ភូមិថ្មជ្រួញមានតំបន់ក្បាលទឹកជប់សំខាន់ៗចំនួន២កន្លែង រួមមាន៖
  1. តំបន់ក្បាលទឹកជប់មៀមឆ្លើយមាន២គ្រួសារពាក់ព័ន្ធមានដីចំការ២ហ.ត
  2. តំបន់ក្បាលទឹកជប់ដីដងជប់មាន៩គ្រួសារពាក់ព័ន្ធមានដីចំការ៤១ហ.ត។
- ភូមិខ្លាឃ្មុំមានតំបន់ក្បាលទឹកជប់សំខាន់ៗចំនួន២កន្លែង រួមមាន៖
  1. តំបន់ក្បាលទឹកជប់អូរស្រែមាន៣គ្រួសារពាក់ព័ន្ធមានដីចំការ៦ហ.ត
  2. តំបន់ក្បាលទឹកជប់តាឡាត និង ដីដងអូរមាន៣គ្រួសារពាក់ព័ន្ធ មានដីចំការ៥ហ.ត។
- ភូមិពពេលមានតំបន់ក្បាលទឹកជប់សំខាន់ៗចំនួន៨កន្លែង រួមមាន៖
  1. តំបន់ក្បាលទឹកជប់ថ្មល់គ្មានអ្នកពាក់ព័ន្ធ
  2. តំបន់ក្បាលទឹកជប់គគីគ្មានអ្នកពាក់ព័ន្ធ
  3. តំបន់ក្បាលទឹកជប់ចេតតាសៅគ្មានអ្នកពាក់ព័ន្ធ
  4. តំបន់ក្បាលទឹកជប់អូរព្រះបាទ និង ផ្គុង មាន៥គ្រួសារ ពាក់ព័ន្ធមានដីចំការ៦៥ហ.ត
  5. តំបន់ក្បាលទឹកជប់ល្វមាន៤គ្រួសារពាក់ព័ន្ធ មានដីចំការ៥ហ.ត
  6. តំបន់ក្បាលទឹកជប់ស្ពានគ្រាំងមាន១គ្រួសារពាក់ព័ន្ធមានដំចំការ២ហ.ត
  7. តំបន់ក្បាលទឹកជប់អណ្តូងព្រីងមាន៣គ្រួសារពាក់ព័ន្ធមានដីចំការ៤,៥ហ.ត
  8. តំបន់ក្បាលទឹកជប់តាត្រាវមាន៣គ្រួសារពាក់ព័ន្ធមានដីចំការ៤ហ.ត

សរុបទាំង៦ ភូមិមាន៣៤ក្បាលទឹកជប់ មាន១០១គ្រួសារពាក់ព័ន្ធមានដីចំការ ២៤១,៨៥ហ.ត។

<u>សកម្មភាព២.២.២</u> សំរបសំរួលកិច្ចពិភាក្សាមិត្តភាពជាមួយគ្រួសារដែលមានដីពាក់ព័ន្ធ នឹងតំបន់ទឹកជប់ក្នុងការរកដំណោះស្រាយ និងប្រគល់ដីសំរាប់អភិរក្សវិញ និងទទួលបានលទ្ធផលដូចខាងក្រោម៖

តំបន់ក្បាលទឹកជប់ចំនួន៤កន្លែងនៃភូមិអន្លង់ធំ, សង្កែឡាក់, តាពេញ និង ខ្លាឃ្មុំ ត្រូវបានប្រជាសហគមន៍ ២៧ គ្រួសារមានការឯកភាពប្រគល់ជូនដីសរុបចំនួន៤៦,៥ហ.ត ដែលនៅជាប់តំបន់ក្បាលទឹកសម្រាប់ការអភិរក្សវិញ ក្នុងនោះមាន៖ តំបន់ក្បាលទឹកជប់អូរអាឡី នៃភូមិអន្លង់ធំមានចំនួន៨គ្រួសារ ស្មើនឹង១៥ហ.ត តំបន់ ក្បាលទឹកជប់ អណ្តូងតាម៉ិចទឹកទរសង្កែឡាក់ មានចំនួន៩គ្រួសារ ស្មើនឹង ២២ហ.ត តំបន់ក្បាលទឹកជប់អូរតាពេញមាន ចំនួន៧ គ្រួសារស្មើនឹង៣,៥ហ.ត តំបន់ក្បាលទឹកជប់អូរស្រែខ្លាឃ្មុំ មានចំនួន៣គ្រួសារស្មើនឹង ៦ហ.ត

ថ្ងៃទី០៤ ខែសីហា ពិភាក្សានៅភូមិអន្លង់ធំ មានអ្នកចូលរួម៣៣នាក់ ស្រី២០នាក់ ថ្ងៃទី០៧ ខែសីហា ពិភាក្សានៅភូមិសង្កែឡាក់ មានអ្នកចូលរួម៣១នាក់ ស្រី១១នាក់ ថ្ងៃទី០៨ ខែសីហា ពិភាក្សា នៅភូមិតាពេញ

| |
|---|
| មានអ្នកចូលរួម២០នាក់ ស្រី៨នាក់ថ្ងៃទី០៩ ខែសីហា ពិភាក្សានៅភូមិខ្លាឃ្មុំ មានអ្នកចូលរួម២៣នាក់ ស្រី៦នាក់ ថ្ងៃទី១០ ខែសីហា ពិភាក្សានៅភូមិថ្មជ្រួញ មានអ្នកចូលរួម៣០នាក់ ស្រី២៣នាក់ថ្ងៃទី១១ ខែសីហា ពិភាក្សានៅភូមិ ពពេល មានអ្នកចូលរួម២១នាក់ ស្រី៧នាក់។ |
| <u>សកម្មភាព២.២.៣</u> ចុះសំរបសំរួលស្រង់ដីធ្លីពាក់ព័ន្ធនឹងតំបន់ទឹកជប់ដែលប្រជាជនប្រគល់អោយវិញទទួលបានលទ្ធផលដូចតទៅ៖ តំបន់ក្បាលទឹកជប់ចំនួន៤កន្លែង អូរអាឡឺអន្លង់ធំមាន៨គ្រួសារពាក់ព័ន្ធ មានផ្ទៃដីចំការ ១៥ហ.ត អូរតាពេញ មាន៧គ្រួសារពាក់ព័ន្ធនិង មានផ្ទៃដីចំការ ៣,៥ហ.ត អណ្តូងតាម៉ិចទឹកទរសង្កែឡាក់ មាន៩គ្រួសារពាក់ព័ន្ធ និង មានផ្ទៃដីចំការ២២ ហ.ត អូរស្រែខ្លាឃ្មុំមាន៣គ្រួសារពាក់ព័ន្ធ និង មានផ្ទៃដីចំការ៦ហ.ត សរុបទាំង៤កន្លែងមាន២៧គ្រួសារពាក់ព័ន្ធ និង មានផ្ទៃដីចំការ ៤៦,៥ហ.ត។ |
| <u>សកម្មភាព២.២.៤</u> ប្រជុំជាមួយសហគមន៍អំពីការផលិតបង្គោលព្រំ និងពិភាក្សាអំពីកិច្ចសន្យាផលិតបង្គោល ហើយបានសម្រេចជារួមថា៖ បង្គោលមេចំនួន៣២ដើម និងបង្គោលរងចំនួន៤០០ដើម ដោយផ្អែកលើគម្រូបង្គោលដែលផលិតដោយស្ថាប័នជំនាញត្រូវបានកំណត់ថា រៀបចំការដេញថ្លៃនៅការិយាល័យ CTO ខ្នាតបង្គោលមេ គឺមានកំពស់១,២ ម៉ែត្រ កម្រាស់១តឹក គុណនឹង ២ជ្រុង ៤តឹកគុណនឹង២ជ្រុង ខ្នាតបង្គោលរង គឺមានកំពស់១,៥ ម៉ែត្រ កម្រាស់១,៥តឹក គុណនឹង ១,៥តឹកគុណនឹង៤ជ្រុង គ្រប់បង្គោលមានលាបថ្នាំពណ៌៣ប្រភេទ គឺក្រហម ស និង ខៀវចាស់។ |
| <u>សកម្មភាព២.២.៥</u> បង្គោលរង៤០០ដើម ត្រូវបានផលិត និង ផ្គង់ផ្គង់ដោយ លោក នាង ណោត ជាអ្នកម៉ៅការលក់។ |
| <u>សកម្មភាព២.២.៦</u> ធ្វើការសម្របសម្រួលចុះកំណត់ព្រំប្រទល់ផ្ទាល់នៅតំបន់ក្បាលជប់សំខាន់ៗបានចំនួន៣កន្លែង៖<br>▪ តំបន់ក្បាលទឹកជប់ចំនួន៣កន្លែងនៃភូមិអន្លង់ធំ,សង្កែឡាក់និង ភូមិតាពេញត្រូវបានចុះកំណត់ព្រំប្រទល់រួចរាល់តាមការចង្អុលបង្ហាញរបស់ប្រជាសហគមន៍<br>▪ តំបន់ក្បាលទឹកជប់អូរអាឡឺ នៃភូមិអន្លង់ធំមានចំនួន៤៤ចំណុច<br>▪ តំបន់ក្បាលទឹកជប់អណ្តូងតាម៉ិចទឹកទរសង្កែឡាក់មានចំនួន២៧ចំណុច<br>▪ តំបន់ក្បាលទឹកជប់អូរតាពេញមានចំនួន២២ចំណុច<br>▪ ផែនទីតំបន់ក្បាលទឹកជប់កំពុងតែរៀបចំតម្លើងដោយអ្នកជំនាញ។ |
| <u>សកម្មភាព៣.១.៣</u> កិច្ចប្រជុំប្រចាំត្រីមាសត្រូវបានរៀបចំ ឡើងនៅការិយាល័យ CTO ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ ក្នុងនោះមានការចូលរួមពីអង្គការTCO, OOO, ANKO ក្រុមប្រឹក្សាឃុំមេភូមិ និងគណៈកម្មការ សហគមន៍មន្ត្រីឧទ្យានុរក្សសរុបចំនួន២១នាក់ស្រី០នាក់ របាយការណ៍លទ្ធផលសម្រេចបាន បញ្ហាប្រឈមជួបប្រទះ និងផែនការអនុវត្តន៍បន្តត្រូវបានបង្ហាញ និងបានចែករំលែកសិក្សាស្វែងយល់រវាងគ្នា និង គ្នាជាពិសេសបានផ្តល់នូវអនុសាសន៍មួយចំនួនសម្រាប់ដៃគូគម្រោងអនុវត្តន៍ និង មានកិច្ចសហការគ្នាល្អ។ |
| <u>សកម្មភាព៣.១.៥</u> នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ នៅការិយាល័យ UNDP ភ្នំពេញ ចូលរួមការប្រជុំ ណែនាំស្តីពីការគ្រប់ គ្រងហិរញ្ញវត្ថុគម្រោងចំនួន១ថ្ងៃ មានអ្នកចូលរួមពីអង្គការដៃគូ ANKO, CTO, OOO, TCO និង CRID សរុបចំនួន១០នាក់ទម្រង់កត់ត្រា និងគោលការណ៍ ហិរញ្ញវត្ថុត្រូវបានបង្ហាញ និងធ្វើការ ណែនាំដោយលោកស្រី គឹម សុជាតាជាបុគ្គលិកជំនួយការកម្មវិធី នៃUNDP បុគ្គលិកគម្រោង, ហិរញ្ញវត្ថុ និង គណនេយ្យករបានទទួលនូវចំណេះ ដឹង និងមានសមត្ថភាពអាចកត់ត្រា ប្រតិបត្តិការ និង ចុះបញ្ជីការគណនេយ្យបានថ្ងៃទី២៣-២៤ ខែកុម្ភៈ ឆ្នាំ២០១៧ នៅការិយាល័យ UNDP ភ្នំពេញ ចូលរួមការប្រជុំណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុគម្រោងចំនួន២ថ្ងៃ មានអ្នកចូលរួមពីអង្គការដៃគូ ANKO, CTO, OOO, TCO និង MAFF សរុបចំនួន១៥នាក់ ទម្រង់កត់ត្រា និងគោលការណ៍ហិរញ្ញវត្ថុរួមទាំងការធ្វើរបាយការណ៍រីកចម្រើន និង បញ្ចប់ត្រូវបានបង្ហាញ និងធ្វើការណែនាំដោយលោកស្រី គឹម សុជាតាជាបុគ្គលិកជំនួយការកម្មវិធី និងលោកស្រី ងិន ណារីរៈ ជាមន្ត្រីសម្របសម្រួលកម្មវិធីជំនួយខ្នាតតូចនៃUNDP បុគ្គលិកគម្រោង, ហិរញ្ញវត្ថុ និងគណនេយ្យករបានទទួលនូវចំណេះដឹង និងមានសមត្ថភាពអាច កត់ត្រាប្រតិបត្តិការ |

និងចុះបញ្ជីការគណនេយ្យ រួមទាំងការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍លទ្ធផលនៃការអនុវត្តន៍គម្រោងបាននៅថ្ងៃទី៨-១១ ខែមីនា ឆ្នាំ២០១៧ នៅការិយាល័យ UNDP ភ្នំពេញ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការតស៊ូ មតិដែលមានអ្នកចូលរួមពីអង្គការដៃគូ ANKO, CTO, CTA, OOO, TCO និង MAFF សរុបចំនួន ២៣នាក់។

៣. បទពិសោធន៍ មេរៀន និងបញ្ហានានា ដែលកើតឡើងក្នុងរយៈពេលរាយការណ៍នេះ ។

- ភាពស៊ាំញាំរវាងផែនការប្រើប្រាស់ដី កម្មសិទ្ធដីធ្លី និង ការងារអភិរក្ស

ជាក់ស្តែងការអភិរក្ស និងផែនការប្រើប្រាស់ និងកម្មសិទ្ធដីធ្លីមានការពាក់ព័ន្ធគ្នាយ៉ាងខ្លាំង។ គំរោងយើងមានគោលបំណងផ្តោតតែទៅលើការអភិរក្ស ហើយមិនបានផ្តោតខ្លាំងលើផែនការប្រើប្រាស់ និងកម្មសិទ្ធដីធ្លីទេ។ តែពេលអនុវត្តជាក់ស្តែងក្នុងសកម្មភាពអភិរក្ស ទើបគំរោងបានដឹងថា ការងារអភិរក្ស ទាមទាអោយមានភាពច្បាស់លាស់ទាំងក្នុងសហគមន៍ និងផ្លូវច្បាប់អំពីផែនការប្រើប្រាស់ដី និងកម្មសិទ្ធដីធ្លី។ ទាក់ទងនិងដីធ្លីកន្លងមកមិនមានការបែងចែក ចាត់ចំណាត់ថ្នាក់អោយបានស្របតាមច្បាប់ថាដីកម្មសិទ្ធត្រឹមណា ដីអភិរក្សត្រឹមណា ហើយប្រជាជនបានកាន់កាប់តំបន់ក្បាលទឹកជប់ ហើយខ្លះក៏ផ្ទេរ(លក់) ទៅអោយអ្នកផ្សេងហើយពេលខ្លះមានសាក្សីពីក្រុមប្រឹក្សាឃុំលើឯកសារទិញលក់ ផ្ទេរដែលធ្វើអោយអ្នកទិញគិតថាស្របច្បាប់។ ហើយនៅពេលគំរោងបានចាប់ផ្តើមពិភាក្សាអំពីការអភិរក្សតំបន់ក្បាលទឹកជប់នេះ ប្រជាជនពេលដំបូងមិនចូលរួម បង្កការលំបាកដោយគាត់គៀងគរ អ្នកភូមិផ្សេងមិនអោយចូលរួម ឬខ្លះទាមទាសំណងជាថវិការជាដើម។ គំរោងបានចំណាយពេលវេលាច្រើនជាងផែនការក្នុងការអប់រំ សំរបសំរួល និងដោះស្រាយដោយស្វះស្វែងសហការជាមួយអាជ្ញាធរពាក់ព័ន្ធ។ តែទោះជាយ៉ាងណាក៏ដោយ ក្នុងដំណាក់កាលនេះទោះជាប្រជាជនព្រមព្រាងប្រគល់ដីមកដាក់ជាតំបន់អភិរក្សក៏ដោយ តែក្នុងរយៈពេលយូរបើមិនមានផែនការប្រើប្រាស់ និងកម្មសិទ្ធដីធ្លី និងការកំណត់ទីតាំងអភិរក្សអោយបានសុក្រិត និង តាមផ្លូវច្បាប់មាំទាំទេ វានិងនាំអោយមានភាពសាំញ៉ាំ ទាក់ទងនិងផែនការប្រើប្រាស់ និងកម្មសិទ្ធដីធ្លី និងការងារអភិរក្សកើតឡើងដរដែល។

- គោលនយោបាយថ្នាក់ជាតិសំរាប់សហគមក្នុងឧទ្យានជាតិភ្នំគូលែន

នៅពេលអនុវត្តគំរោង ប្រជាជនមានការគិត និងមតិខុសៗគ្នា រួមទាំងក្រុមប្រឹក្សាឃុំផង ទាក់ទងទៅនិងអនាគតសំរាប់សហគមន៍។ មានប្រជាសហគមន៍ខ្លះគិតថាគេនិងដូទីតាំងសហគមគាត់ទៅតំបន់ផ្សេង នៅខាងក្រៅឧទ្យានជាតិ។ ការយល់ឃើញបែបនេះនាំអោយគាត់អសកម្មក្នុងការងារអភិរក្ស ក៏ដូចជាការងារអភិវឌ្ឍក្នុងសហគមន៍ រួមទាំងផ្នែកជីវភាពផងដែរ។ ដោយគាត់គិតថាពេលណាមួយគាត់និងត្រូវរើទៅកាន់តំបន់ថ្មី ហើយការខិតខំរបស់គាត់ពេលនេះ អាចខាតបង់ ឬត្រូវបោះបង់ចោលពេលណាមួយ។ តែបើមានគោលនោបាយច្បាស់លាស់ ហើយគោលនយោបាយនេះត្រូវបានផ្សព្វផ្សាយ អោយប្រជាសហគមបានយល់ដឹងច្រើនវាអាចជួយអោយប្រជាសហគមន៍ដឹងអំពីគោលដៅ និងយុទ្ធសាស្រ្តបែបនេះធ្វើអោយសហគមមានភាពច្បាស់លាស់ និងមិនរួញរាក្នុងការអនុវត្តសកម្មភាពស្របតាមគោលដៅគោលនយោបាយនោះ។ ប្រជាសហគមខ្លះមានសតិអារម្មណ៍ថា អ្វីៗដែលកើតឡើងក្នុងសហគមន៍វាគ្រាន់តែបណ្តោះអាសន្នប៉ុណ្ណោះ ហើយរងចាំតែការសំរេចរបស់ក្រសួងបរិស្ថាន និងរាជរដ្ឋាភិបាលក្នុងការផ្លាស់ប្តូរសហគមន៍ទៅកាន់តំបន់ផ្សេង។ ប្រជាសហគមខ្លះក៏បានលើកឡើងអំពីរករណីជាក់ស្តែងដូចជាការជំលៀសប្រជាជននៅតំបន់វារីអគ្គីសនីឫស្សីជុំក្រោមនៅខេត្តស្ទឹងត្រែង។ ភាពមិនទាន់ច្បាស់លាស់នេះ ជាកត្តាមួយនាំអោយមានភាពអសកម្មក្នុងចំណោមប្រជាសហគមន៍ក្នុងការចូលរួមសកម្មភាពអភិវឌ្ឍសហគមន៍ និងការងារអភិរក្ស។

## ២.ខេត្តឧត្តរមានជ័យ

### ១.គម្រោងមេ (LRP)

| គោលបំណងគំរោង | លទ្ធផលរំពឹងទុក |
| --- | --- |

| | |
|---|---|
| **គោលបំណងជាយុទ្ធសាស្ត្រទី១៖** នៅបំណាច់ឆ្នាំ២០១៧សន្តិសុខស្បៀងកសិករខ្នាតតូចចំនួន៩៣២គ្រួសារក្នុង ភូមិគោលដៅចំនួន២៣នៃឃុំចំនួន៦និង៤ស្រុកត្រូវបានកែលំអរជីវភាពរស់នៅអោយប្រសើរឡើងជាងមុន។ | **លទ្ធផល.១.១:** កសិករខ្នាតតូច ទាំងស្ត្រី និងបុរស ចំនួន ៩០១ នាក់ក្នុងនោះ មានស្ត្រីចំនួន៣០១នាក់ ក្នុងឃុំចំនួន៣នៃខេត្តឧត្តរមានជ័យទទួលបានការរស់នៅប្រសើរឡើងតាមរយៈការគ្រប់គ្រងលើក្រុមសន្សំ ធនាគារស្រូវ កសិករគំរូ និងបង្កើនសមត្ថភាពសហគមន៍ដើម្បីអោយមានភាពធន់នឹងគ្រោះមហន្តរាយ និងស្វែងរកការគាំទ្រធនធានសេវាកម្ម បញ្ហាកសិកម្ម ត្រូវបានដោះស្រាយដោយមន្ទីរកសិកម្ម ឆ្លើយតបនឹងកសិកម្មនិរន្តរភាពដែលធនទ្រាំនឹងការប្រែប្រួលអាកាសធាតុ។ |
| | **លទ្ធផល.១.២:** ៦០%នៃសមាជិកសហគមន៍ព្រៃឈើទាំងបីសហគមន៍ សរុប ៤,៨៣៩នាក់ស្ត្រី/២,៣៣២នាក់ និងបណ្តាញសហគមន៍ព្រៃឈើទាំង១៣ ធ្វើការគ្រប់គ្រងថែរក្សា និងដកហូតធនធានពីព្រៃសហគមន៍ ប្រកបដោយនិរន្តភាព។ |
| | **លទ្ធផល.១.៣:** ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដីសម្បទានសេដ្ឋកិច្ចចំនួន២២១គ្រួសា(១០៩០ហិកតា)ដែលមិនទាន់មានការដោះស្រាយអាចស្វែងរកការគាំទ្រពីរដ្ឋាភិបាលនិងដំណោះស្រាយសមស្របដោយសន្តិវិធី |
| | **លទ្ធផល.១.៤:** ប្រជាពលរដ្ឋដែលរងផលប៉ះពាល់៣៧៣គ្រួសារពីក្រុមហ៊ុន Synohydro នឹងមានសម្ថភាពយល់ដឹងពីសិទ្ធិនានារបស់ខ្លួនដែលមានចែងក្នុងច្បាប់ អាចធ្វើសកម្មភាពស្របច្បាប់ស្វែងរកការគាំទ្រពីរដ្ឋាភិបាលដើម្បីទទួលបានដំណោះស្រាយដោយសន្តិវិធី។ |
| **គោលបំណងជាយុទ្ធសាស្ត្រទី២៖** នៅបំណាច់ឆ្នាំ២០១៧ កុមារចំនួន ២,៨៤១នាក់/កុមារី១,៣១៨នាក់ស្ថិតនៅក្នុងឃុំចំនួនបីទទួលបានការអប់រំនៅថ្នាក់មូលដ្ឋានត្រឹមថ្នាក់ទី៦ប្រសើរជាងមុន។ | **លទ្ធផលទី២.១៖** កុមារចំនួន ២,៨៤១នាក់/កុមារី១,៣១៨នាក់ នៃឃុំសំរោង បន្សាយរាក់ និងគោកខ្ពស់ទទួលបានការសិក្សា បរិយាកាសនៃការសិក្សាប្រសើរជាងមុនតាមរយៈ ក្លឹបកុមារ និងការលើកកំពស់សិទ្ធិក្នុងសាលារៀន |
| | **លទ្ធផលទី២.២:** គណៈកម្មការទ្រទ្រង់សាលាទាំង២០សាលា បានអនុវត្តតួនាទី និងការទទួលខុសត្រូវក្នុងសាលារៀនប្រសើរជាងមុន ហើយប្រជាជន រួមទាំងកុមារចំនួន៧០០នាក់/ស្ត្រី៤០០នាក់ បានយល់ដឹងពីពីការលើកកំពស់សិទ្ធិក្នុងសាលារៀន(PRS)។ |
| **គោលបំណងជាយុទ្ធសាស្ត្រទី៣៖** នៅបំណាច់ឆ្នាំ ២០១៧ ស្ត្រីជាមេដឹកនាំ សហគមន៍ចំនួន៧៦នាក់ រួមទាំងសមាជិកសហគមន៍២០ភូមិ និងក្រុមប្រឹក្សាឃុំ នៅក្នុង ឃុំសំរោង បន្សាយរាក់ និងគោកខ្ពស់ នៃខេត្តឧត្តរមានជ័យ ចូលរួមយ៉ាងសកម្មក្នុងការអនុវត្តតួនាទីរបស់ខ្លួន។ | **លទ្ធផល.៣.១:**ស្ត្រីជាមេដឹកនាំសហគមន៍ចំនួន៧៦នាក់ និងក្រុមប្រឹក្សាឃុំដែលទទួលបន្ទុក(គកនក)៦នាក់ក្នុងឃុំសំរោង បន្សាយរាក់ និងគោកខ្ពស់បានប្រើប្រាស់តួនាទីរបស់ខ្លួនក្នុងការចូលរួមអភិវឌ្ឍន៍ភូមិឃុំរបស់ពួកគាត់ |
| | **លទ្ធផល.៣.២:**សមាជិកសហគមន៍ចំនួន៤០០នាក់/ស្ត្រី៣០០នាក់ បានយល់ដឹងពីតួនាទីយេនឌ័រ និងតួនាទីភេទ។ |

សម្រាប់ឆ្នាំ២០១៧នេះគោលបំនងរួមនៃគម្រោងគឺចង់ឃើញ កសិករក្រីក្រ៩៣២គ្រួសារនៃគ្រួសារសរុបចំនួន ២,៣៣២ គ្រួសារនឹង ទទួលបានសន្តិសុខស្បៀងតាមរយៈការគ្រប់គ្រងព្រៃសហគមន៍។

**សង្ខេបលទ្ធផលទី១៖** សមាជិកសហគមន៍មានការទប់ស្កាត់បទល្មើសព្រៃឈើជាប្រចាំចំនួន១៣ករណីដែលបទ

ល្មើសទាំងនេះមានការរុករានដីព្រៃ ការឈូសឆាយ សង់លំនៅឋាន និងកាប់ឈើខុសច្បាប់។ មានការចូលរួមពីគណៈកម្មការសហគមន៍ព្រៃឈើចំនួន២១១នាក់ក្នុងនោះស្ត្រីចំនួន៤នាក់។ បើប្រៀបធៀបឆ្នាំ២០១៦បទល្មើសមានការកើនឡើង៦ករណី ប៉ុន្តែគណៈកម្មការសហគមន៍ព្រៃឈើពួកគាត់នៅតែមានការខិតខំប្រឹងប្រែងសហការណ៍ជាមួយអាជ្ញាធរពាក់ព័ន្ធ ជាពិសេសរដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់ និងមន្ទីរកសិកម្មខេត្តឧត្តរមានជ័យក្នុងការទុបស្កាត់បទល្មើស។ សមាជិកសហគមន៍នៅតែអាច ថែរក្សា គ្រប់គ្រង អភិរក្សសហគមន៍៣ (សហគមន៍ព្រៃឈើរំដួលវាសនា ភ្នំដងរែកសម្រែកព្រៃស្រស់ និងរតនរុក្ខា)ដែលជាតំបន់គោលដៅផ្ទាល់របស់គម្រោងមានផ្ទៃដីសរុប 20,345ហិកតា។ មានសមាជិកសរុប ២,៣៣៤ គ្រួសារចូលទៅរកអនុផលព្រៃឈើជាប្រចាំដូចជា៖ ជីកដំឡូង បេះផ្សិត រកឃ្មុំ ជីកទំពាំង ឬស្សី ស្បូវ បេះបន្លែព្រៃ ចកអណ្តើក ក្បុក បន្លែព្រិច ស្តៅ រាំង អុស។ល។ សមាជិកសហគមន៍ប្រហែល៣០០គ្រួសារមានដីស្រែ និងចំការ ក្នុងព្រៃសហគមន៍ ដែលពួកគាត់ទទួលផលស្រូវ និងដំឡូងមី ជារៀងរាល់ឆ្នាំ និងប្រហែល៥០គ្រួសារ ក្នុងចំណោម៣០០គ្រួសារ ប្រកបរបរនេសាទ ក្នុងព្រៃសហគមន៍ សម្រាប់បង្កើនប្រាក់ចំណូលសម្រាប់ចិញ្ចឹមជីវភាពគ្រួសារជាប្រចាំ។

សម្រាប់ឆ្នាំ២០១៧ មានការប្រជុំបណ្តាញសហគមន៍ព្រៃឈើចំនួន០៣ដង ដើម្បីរៀបចំផែនការបន្តក្នុងការការពារព្រៃសហគមន៍។ បណ្តាញសហគមន៍បានដាក់ពាក្យបណ្តឹងចំនួន០៤ដង ទៅមន្ទីរកសិកម្ម និងខណ្ឌរដ្ឋបាលព្រៃឈើឧត្តរមានជ័យ និងទៅក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ។ ដើម្បីស្វែងរកការគាំទ្រ និងដំណោះស្រាយ តែពុំទទួលបានលទ្ធផលផលល្អ។ ប៉ុន្តែតំណាងគណៈកម្មការសហគមន៍ព្រៃឈើទាំង១២ នៅតែព្យាយាមជួបគ្នា។ យ៉ាងហោចណាស់រៀងរាល់៣ខែម្តង ដើម្បីប្រជុំពិគ្រោះយោបល់គ្នា សម្រាប់ការស្វែងរកដំណោះស្រាយរួម និងសុំការផ្តល់ យោបល់ពីនាយខណ្ឌរដ្ឋបាលព្រៃឈើឧត្តរមានជ័យ និងប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាតខេត្ត។ ទោះជាមានបទល្មើសកើតឡើងគ្រប់រូបភាពយ៉ាងណាក៏ដោយក៏សហគមន៍ព្រៃឈើទាំង១២ នៅតែរក្សាផ្ទៃដីបានព្រៃឈើ សហគមន៍បានចំនួន៤៦,៩៧៩ហិកតា។ ដែលមានសមាជិកយ៉ាងហោចណាស់ ៣,០៦៥គ្រួសារ គឺស្មើនឹង៤០ភាគរយនៃសមាជិកសរុប ទទួលបាននូវសិទ្ធ ក្នុងការដកហូតអនុផលព្រៃឈើគ្រប់ប្រភេទជាប្រចាំ។ នៅឆ្នាំ២០១៨ សហគមន៍ចំនួន០៦ ដែលកំពុងមានបញ្ហាប្រឈមខ្លាំងរួមមាន៖១-អណ្តូងបរ ២-ដុងបេង ៣-រំដួលវាសនា ៤-សាមគ្គីសង្គ្រោះព្រៃឈើ ៥-ក្បាលអូរសូភីគីរីព្រៃស្រោង ៦-រតនរុក្ខា នឹងលើកផែនការដាក់ពាក្យ បណ្តឹងទៅតុលាការ ចំពោះបទល្មើសព្រៃឈើដែលពួកគាត់កំពុងជួបប្រទះពិសេសករណីការរុករានដីព្រៃធ្វើជា កម្មសិទ្ធ និងការកាប់ឈើសំណង់ និងកាប់ឈើធ្វើអុសធ្យូងជាដើម ។ល។

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដែលទើបជាប់ឆ្នោតចំនួន៤៥នាក់ក្នុងនោះចំនួន០៦នាក់ជាស្ត្រីបានយល់ដឹងពីច្បាប់ ស្តីពីព្រៃឈើនិងអនុក្រិតស្តីពីការបង្កើតសហគមន៍ព្រៃឈើ លើសពីនេះទៀត ពួកគាត់បានចូលរួមសកម្មក្នុងការ ទប់ស្កាត់ បទល្មើសក្នុងព្រៃសហគមន៍របស់ពួកគាត់ តាមរយៈការចុះល្បាត់ព្រៃ។ លើសពីនេះគម្រោងបានសម្របសម្រួលកាយប្រឡាយធ្វើព្រំប្រទល់ព្រំប្រទលព្រៃសហគមន៍ចំនួន០២សហគមន៍ ដែលមានប្រវែងសរុបចំនួន ១,៥២៨ ម៉ែត្រ ក្នុងនោះ ទទឹងមានចំនួន១ម៉ែត្រ និងជម្រៅចំនួន១ម៉ែត្រ ដែលជាព្រំប្រទល់របស់សហគមន៍រតនរុក្ខានិងសហគមន៍ភ្នំដងរែកសម្រែកព្រៃស្រស់។ ការជីកប្រឡាយព្រំប្រទល់ព្រៃសហគមន៍ នេះបានផ្តល់អត្ថប្រយោជន៍ដ៏សំខាន់ដល់សហគមន៍ក្នុងការការពារព្រៃសហគមន៍របស់ពួកគាត់។ ប្រជាពលរដ្ឋនិងប្រជាសមាជិកសហគមន៍ មានការសប្បាយរីករាយជាខ្លាំង នៅពេលដែលបានប្រឡាយព្រំប្រទល់នេះព្រោះវាអាចបង្ហាញអំពីទីតាំង និងព្រំដែនកំណត់ព្រៃសហគមន៍យ៉ាងច្បាស់។ ជាក់ស្តែងនៅសហគមន៍ភ្នំដងរែកសម្រែកព្រៃស្រស់មានការថយចុះនូវបទល្មើសនៃការកាប់រានដីព្រៃ ហើយផ្ទៃដីចំនួន១៥ហិកតាដែលបានរុករានត្រូវបានផ្អាក និងឈប់បន្តការកាប់រុករានក្នុងព្រៃសហគមន៍ពីសំណាអ្នកភូមិខាងក្រៅ។ ចំណែកឯសហគមន៍រតនរុក្ខា កំពុងតែមានការព្រួយបារម្ភណ៍ព្រោះមានប្រជាជនមកពីភូមិក្រៅ និងទាហ៊ាន៤២ ដោយពួកគាត់មក

ធ្វើស្រែប្រហែលជាង១០០ហិកតា នៅក្នុងព្រៃសហគមន៍ ដែលកន្លងមកពួកគាត់បានធ្វើការរុករានពង្រីកក្បាលដីបន្ថែមខុសច្បាប់យ៉ាងអនាធិបតេយ្យ ដោយគ្មានការក្រែងការរអារច្បាប់ ។

ក្រុមការងាររបស់អង្គការកែប្រែសហគមន៍ បានសហការជាមួយសមាជិកសហគមន៍ អាជ្ញាធរដែនដីដាំឬស្សីផ្អែមយកទំពាំង សរុបចំនួន៣៦០ដើម ជាការផ្សាំ និងត្រៀមទុកពូជ សម្រាប់នាំយកទៅដាំតាមបណ្តោយ ព្រំប្រទល់ជុំវិញព្រៃសហគមន៍ នៃសហគមន៍ព្រៃឈើរតនរុក្ខា និងសហគមន៍ព្រៃឈើភ្នំដងរែកសំរែកព្រៃស្រស់។ តាមការសង្កេត និងតាមដាន ការថែទាំកូនឬស្សីរបស់សហគមន៍កន្លងមក យើងឃើញថា៖ រហូតមកដល់ពេលនេះកូនឬស្សីនៅសរុប៣៤៥ដើម ហើយគណៈកម្មការគ្រប់គ្រងសហគមន៍បានភ្ជួរដីព័ទ្ធជុំវិញតំបន់ដាំឬស្សី ដើម្បីការពារភ្លើងឆេះព្រៃ ឬស្សីទាំងអស់ជាពូជ សម្រាប់ដាំបន្តនៅតាមព្រំប្រទល់ព្រៃសហគមន៍នឹងចែកជូនដល់សមាជិកសហគមន៍នៅពេលត្រូវការចង់ដាំយកទំពាំងដើម្បីលក់សម្រាប់ប្រើប្រាស់ជាលក្ខណៈគ្រួសារ និងដើម្បីលក់យកប្រាក់ចំណូល។

តំណាងសហគមន៍ទាំង១៣បានជួបជាមួយអភិបាលរងខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន០១លើក ដើម្បីរកដំណោះស្រាយលើបទល្មើសដែលកើតមានឡើងក្នុងព្រៃសហគមន៍កន្លងមក។ ក្នុងជំនួបនោះ លោកអភិបាលរងខេត្តបានសន្យាថានឹងជួយប្រមូលបញ្ហាទាំងអស់របស់សហគមន៍ ដាក់ជូនដល់ឯកឧត្តមអភិបាលខេត្តពិនិត្យនិងដោះស្រាយនៅកំរិតខេត្ត រីឯបញ្ហាមួយចំនួនដែលមិនអាចដោះស្រាយនៅកំរិតថ្នាក់ខេត្តបាន នឹងត្រូវបញ្ជូនបន្តទៅទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជួយដោះស្រាយបន្ថែម។ អភិបាលខេត្តបានលើកផែនការដើម្បីជួបជាមួយសហគមន៍ទាំង១៣ តែរហូតដល់ពេលនេះមិនទាន់បានជួបនៅឡើយដោយសាររវល់រហូត។ នៅក្នុងឆ្នាំ២០១៨ខាងមុខនេះ សហគមន៍ព្រៃឈើអណ្តូងបរ សហគមន៍ព្រៃឈើដុងបេង និងសហគមន៍ព្រៃឈើសាមគ្គីសង្គ្រោះព្រៃឈើគ្រោងផែនការផ្តិតមេដៃសមាជិកសហគមន៍ទាំងអស់ដាក់ជូនអភិបាលខេត្តជួយដោះស្រាយ។

នៅក្នុងខែធ្នូឆ្នាំ២០១៧កន្លងមកនេះមានសហគមន៍ព្រៃឈើ ចំនួន០៤រួមមាន៖ សហគមន៍ព្រៃឈើរំដួលវាសនា សហគមន៍ព្រៃឈើដុងបេង សហគមន៍ព្រៃឈើ អណ្តូងបរ និងសហគមន៍ព្រៃឈើក្បាលអូរស្វាភីគីរីព្រៃស្រោង បានដាក់ពាក្យបណ្តឹងទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួចហើយ។ ប៉ុន្តែមិនទាន់បានទទួលដំណឹងត្រប់មកវិញ ដូច្នេះយើងកំពុងរងចាំ និងបន្តតាមសួរព័ត៌មាននេះបន្ថែមទៀត ជាមួយក្រសួងកសិកម្ម។

ក្នុងឆ្នាំ២០១៧នេះ មានក្រុមសន្សំសរុបចំនួន២១ក្រុម ស្ថិតក្នុងភូមិគោលដៅចំនួន២០ភូមិ ក្នុងឃុំចំនួន០៤ឃុំ/សង្កាត់ នៃក្រុងសំរោង និងស្រុកបន្ទាយអំពិល របស់ខេត្តឧត្រមានជ័យ។ ក្រុមទាំង២១ មានថវិកាសរុបចំនួន ១១៥,៧១២,៥០០រៀល ដែលមានសមាជិកសរុបចំនួន៤២៦នាក់ ក្នុងនោះស្ត្រីចំនួន៣៦៩នាក់។ ទឹកប្រាក់សរុបដែលក្រុមបានផ្តល់កម្ចីឱ្យទៅសមាជិកក្រុមសរុបចំនួនន១១៥,៧១២,៥០០រៀលស្មើនឹងចំនួន៤២៦នាក់។

គ្រួសារពួកគាត់ខ្ចី៦ខែម្តងវិលគ្នា ហើយប្រាក់ដែលនៅសល់ក្នុងក្រុមនីមួយៗ ពី ១០០,០០០ ម៉ឺន ទៅ ១៥០,០០០ម៉ឺន មិនបានឱ្យកម្ចីសរុបចំនួន ២,១០០,០០០ ទៅ ៣,១៥០,០០០រៀល។ កម្ចីដែលសមាជិក ទាំងអស់ខ្ចីភាគច្រើនប្រើសម្រាប់ក្នុងគោលបំណងប្រើលើករបរដាំដំឡូងធ្វើស្រែ លក់ចាប់ហួយ កសិកម្ម ដាំបន្លែ ឈ្នួលភ្ជួរដី។ ៦ខែពួកគាត់សងម្តង រួចធ្វើពាក្យកំចីសាថ្មី មិនមានសមាជិកណាខ្ចីមិនបានសងទេ។ ក្នុងការសន្សំមានការកើនឡើងជាប្រចាំ ដោយពួកគាត់មានការកាត់បន្ថយកម្ចីពីធនាគារ។ ប្រាក់ដើមឆ្នាំសរុបទាំង ២១ក្រុម មាន២៩,៥៧០,០០០រៀល ទឹកប្រាក់ចុងឆ្នាំមាន ១១៥,៧១២,៥០០រៀល មានការកើនឡើងសរុប ៨៤,៣៩២,៥០០រៀល។

**តារាងសង្ខេបអំពីស្ថានភាពក្រុមសន្សំប្រាក់ក្នុងតំបន់គោលដៅ: ទិន្នន័យសម្រាប់ឆ្នាំ២០១៧ (ចំពោះថវិកាខាងក្រោមមានមេគុណ១០០)**

| ល.រ | ឈ្មោះឃុំគោលដៅ | ចំនួនក្រុម | ចំនួនសមាជិក | សមាជិកស្ត្រី | សរុបទុនចាប់ផ្តើម-រៀល | សរុបប្រាក់សន្សំ-រៀល | សរុបប្រាក់សន្សំសង្គ្រោះ-រៀល | ប្រាក់សរុបចុងឆ្នាំ-រៀល | ប្រាក់ដើមឆ្នាំ-រៀល | រីកចំរើន |
|---|---|---|---|---|---|---|---|---|---|---|

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 1 | សង្កាត់សំរោង | 9 | 185 | 169 | 364,790 | 126,500 | 4,900 | 496,190 | 133,800 | 362,390 |
| 2 | សង្កាត់បន្សាយរាក់ | 5 | 101 | 91 | 161,300 | 60,000 | 1,250 | 222,550 | 46,200 | 158,850 |
| 3 | ឃុំគោកខ្ពស់ | 4 | 73 | 60 | 206,400 | 36,210 | 1,275 | 243,885 | 79,100 | 164,785 |
| 4 | សង្កាត់កូនក្រៀល | 3 | 67 | 49 | 167,000 | ,800 | 700 | 194,500 | 36,600 | 157,900 |
| | សរុបរួម | 21 | 426 | 369 | 899,490 | 249,510 | 8,125 | 1,157,125 | 295,700 | 843,925 |

ធនាគាស្រូវមាន៨ក្រុម ចំនួនស្រូវសរុបដើមឆ្នាំមាន៤៨,១១៦គីឡូក្រាម និងស្រូវសរុបចុងឆ្នាំ៥១,៥១២គីឡូក្រាម ដែលបានកើនឡើង៥,៣៩៦គីឡូក្រាម បើធៀបទៅនឹងដើមឆ្នាំ។ ធនាគាស្រូវពួកគាត់ មានការខ្ចីសងជាប្រចាំឆ្នាំនៅពេល រដូវ បង្កបង្កើនផល។ ការខ្ចីស្រូវក្នុង១០០គីឡូក្រាមត្រូវសងវិញ១២០គីឡូក្រាម។

**សង្ខេបលទ្ធផលទី២៖**សម្រាប់ឆ្នាំ២០១៧ នេះស៊ីធីអូ បានប្រមូលសារក្មេងសរុប៦១២នាក់ ក្នុងនោះកុមារី ៣៥២នាក់។ បានផ្ញើបញ្ជីឈ្មោះ និងសាររបស់កុមារចំនួន៥៨២នាក់ (កុមារី៣៣៩នាក់) ទៅកាន់ការិយាល័យរបស់អង្គការ អាក់សិនអេដ។ បានតាមដានស្ថានភាពកុមារធ្វើចំណាកស្រុកចំនួន៣០នាក់ (កុមារីចំនួន១៣នាក់) ដែលពួកគាត់ធ្វើ ចំណាកស្រុកតាមរូបភាពផ្សេងៗដូចជា៖ កុមារខ្លះធំហើយ ត្រូវទៅធ្វើការនៅប្រទេសថៃ និងខ្លះទៀតទៅធ្វើការ នៅខេត្តផ្សេងៗ។ រីឯកុមការតូចខ្លះទៀតត្រូវធ្វើដំណើតាមឪពុក ម្តាយធ្វើចំណាកស្រុកធ្វើការ ប្រកបរបរចិញ្ចឹមជីវិត្តនៅក្រៅខេត្ត ឬទៅប្រទសថៃ។ ការប្រជុំគ្រូស្ម័គ្រចិត្តមានការចូលរួមចំនួន២៨នាក់/២៤ស្ត្រី។ ដើម្បីជួយសម្របសម្រួលក្នុង កម្មវិធីកុមារ។ បានចែកសម្ភារៈក្លឹបកុមារចំនួន១០សាលា ដែលមានអ្នកចូលរួមសរុប១១៥ នាក់ស្រី៥៦នាក់ ដែលមានសាលាដូចជា សាលាបឋមសិក្សាដូនកែនភ្លៀត បឋមសិក្សា សំរោង បឋមសិក្សាគោកគរ បឋមសិក្សាហ៊ុនសែនឆ្អើប បឋមសិក្សាបន្សាយរាក់ បឋមសិក្សាអូរទេង បឋម សិក្សាត្នោត បឋមសិក្សាពោធិវង្ស បឋមសិក្សាឈើស្លាប់ និងបឋមសិក្សាគោកខ្ពស់ថ្មី ។

**សង្ខេបលទ្ធផលទី៣៖**ការប្រជុំក្រុមប្រឹក្សាភិបាល បានលើកឡើងពី របាយការណ៍វឌ្ឍនៈភាពប្រចាំឆមាសទី១ នៃឆ្នាំ២០១៧របស់អង្គការកែប្រែសហគមន៍ និងពិភាក្សាដើម្បីកែសម្រួលគោលនយោបាយស្តីពីការគ្រប់គ្រងបុគ្គលិក និងគណៈគ្រប់គ្រងអង្គការ និងសំណើជ្រើសរើសប្រធានកម្មវិធី ដែលជានាយកស្តីទី និងពិភាក្សាកែសម្រួលគោលនយោបាយ ប្រាក់បៀវត្សន៍ (ប្រាក់បំណាច់មុខងារ និងប្រាក់បៀវត្សន៍ទីខែទី១៣) និងបច្ចុប្បន្នភាពម្ចាស់ជំនួយ និងប្រភពថវិកា និងលើកទិសដៅផែនការសកម្មភាពដែលត្រូវអនុវត្តបន្ត និងសេចក្តីថ្លែងអំណរគុណដល់ក្រុមប្រឹក្សាភិបាល ការត្រួតពិនិត្យនិងឆ្លុះបញ្ចាំងការអនុវត្តសកម្មភាពប្រចាំត្រីមាស។ អង្គការកែប្រែសហគមន៍មានកែតម្រូវលើការអនុវត្តគម្រោងមួយចំនួន មានការរៀបចំផែនការឆ្នាំ២០១៨ និងមានចូលរួមសិក្ខាសាលាជាមួយអង្គការNEP, NGOs Forum,CCC ទទួលបានចំណេះដឹងថ្មីៗពីគោលការណ៍អប់រំនានា និងពត៌មានពីការគ្រប់គ្រងធនធានធម្មជាតិ និងដីធ្លី សម្រាប់ត្រឡប់មក អនុវត្តគម្រោងបន្តអោយមានប្រសិទ្ធិភាព។

**១.ពិព័ណ៌នាការរីកចំរើនរបស់គម្រោង**

**លទ្ធផល.១:សមាជិកសហគមន៍ព្រៃឈើទាំងបីសហគមន៍សរុប ៣,២២៦នាក់ ស្ត្រី ១,៥៥៥នាក់ និងបណ្តាញសហគមន៍ព្រៃឈើ ដែលមានសហគមន៍ចំនួន១៣ ធ្វើការគ្រប់គ្រង ថែរក្សា និងដកហូតធនធានពីព្រៃសហគមន៍ប្រកបដោយនិរន្តរភាព។**

*១.១.គាំទ្រការទប់ស្កាត់បទល្មើសកាប់ឈើ និងរុករានដីព្រៃសហគមន៍ខុសច្បាប់នៅក្នុងដែនព្រៃរបស់សហគមន៍*

សមាជិកសហគមន៍មានការទប់ស្កាត់បទល្មើសព្រៃឈើជាប្រចាំនិងធ្វើការទប់ស្កាត់បានចំនួន១៣ករណី។ ការចុះល្បាតព្រៃសហគមន៍របស់គណៈកម្មការសហគមន៍ព្រៃឈើបានចូលរួមចំនួន២១១នាក់/ស្រី៤នាក់ និងធ្វើកិច្ចសន្យា

ជាមួយជនល្មើសចំនួន១៧/ស្រី២នាក់ បទល្មើសមានការុករានដីព្រៃ ចូលកាប់ឈើ និងអនុផលព្រៃឈើខុសច្បាប់ សង់លំនៅឋាន ខុសច្បាប់ក្នុងព្រៃសហគមន៍។ មានការឃាត់បានរណាយន្តចំនួន៨គ្រឿង និងដាក់ចូលតុលាការ ២ករណី គោយន្ត១១គ្រឿង ឈើប្រណិតប្រភេទឈើបេងចំនួន៦០ដុំដែលមានទំហំ១០x១០x៨០ដោយមាន កិច្ចសហការជាមួយ មន្ទីបរិស្ថានខេត្ត សង្កាត់ ផ្នែក និងខណ្ឌរដ្ឋបាលព្រៃឈើ ក្រុមប្រឹក្សាឃុំ នគរបាល។ ពាក្យបណ្តឹងដាក់ទៅមន្ទីរកសិកម្មរុក្ខា ប្រមាញ់ និងនេសាទខេត្តឧត្តរមានជ័យ ពុំទាន់មានដំណោះស្រាយ។ ការទប់ស្កាត់បទល្មើសបានជួយអោយសហគមន៍ ការពារបានខ្លះ និងកាត់បន្ថយនូវការកាប់ឈើ និងអនុផលព្រៃឈើខុសច្បាប់មួយចំនួន តែមិនអាចទុបស្កាត់បានទាំងស្រុងទេ។ សហគមន៍ដែលមានបទល្មើសច្រើនជាងគេមាន រំដួលវាសនា អណ្តូងបរ ដុងបេង សាមគ្គីសង្រោះព្រៃឈើ ក្បាលអូរស្វូភីគីរីព្រៃស្រោង។

*១.២.ប្រជុំប្រចាំឆមាសបណ្តាញព្រៃឈើថ្នាក់ខេត្តទាំង១៣សហគមន៍*

មានការប្រជុំបាន៣ដងរបស់បណ្តាញសហគមន៍ព្រៃឈើខេត្តឧត្តរមានជ័យមានការចូរួម២៦នាក់/ស្រី២នាក់មបានអញ្ជើញមកពី១២សហគមន៍ព្រៃឈើទូទាំងខេត្ត និងមានការចូលរួមពីសង្កាត់ ផ្នែក ខណ្ឌ មន្ទីរកសិកម្មខេត្ត។ ក្នុងនោះ សហគមន៍បានលើកឡើងពីបញ្ហាបទល្មើសមានការុករានដីព្រៃ ចូលកាប់ឈើ និងអនុផលព្រៃឈើខុសច្បាប់ សង់លំនៅឋានខុសច្បាប់ក្នុងព្រៃសហគមន៍។ សហគមន៍៥បានដាក់ពាក្យបណ្តឹងទៅមន្ទីរកសិកម្មខេត្ត មានសហគមន៍ព្រៃឈើអណ្តូងបរ សហគមន៍ព្រៃឈើដុងបេង រំដួលវាសនា និងសហគមន៍ ក្បាលអូរស្វូភីគីរីព្រៃស្រោង មិនទាន់មានដំណោះស្រាយទេ។ ទើបប្រធានបណ្តាញ បានរៀបចំជារបាយការណ៍រួមមួយដាក់ចូលមន្ទីរកសិកម្ម ពីបញ្ហារបស់សហគមន៍ទាំង១២។ មន្ទីរកសិកម្មបានលើកឡើងពីបញ្ហាទាំងអស់របស់សហគមន៍នៅពេលមានការប្រជុំនៅគណៈបញ្ជាការឯកភាពខេត្ត។

*១.៣.គាំទ្របណ្តាញសហគមន៍ក្នុងការដោះស្រាយបទល្មើសព្រៃឈើទៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ*

តំណាងសហគមន៍ព្រៃឈើ និងប្រធានបណ្តាញសហគមន៍ បានដាក់បណ្តឹងទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តឧត្តរមានជ័យ ស្តីពីទាហានកងពលតូចអន្តរាគមន៍លេខ៥ បានបោះទីតាំងទ័ព នៅក្នុងសហគមន៍ដុងបេងមាន៤ទីតាំង។ ទី១ស្ថិតនៅភ្នំដី២១ហិចតា ទី២ស្ថិតនៅប៉ោយយួន១៩ហិចតា ទី៣ស្ថិតនៅកញ្ចាន់១៧ហិចតា ទី៤ស្ថិតនៅថ្មចេញទឹកចំនួន២០ហិចតា សរុបរួមចំនួន៧៧ហិចតា។ តំណាងសហគមន៍ព្រៃឈើ និងលេខាបណ្តាញសហគមន៍បានសហការណ៍គ្នា រៀបចំពាក្យបណ្តឹងដាក់ទៅមន្ទីកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តឧត្តរមានជ័យ ដើម្បីអោយមន្ទីរចាត់វិធានការដោះស្រាយ បញ្ហាកាប់រុរានយកដីព្រៃសហគមន៍ ទាក់ទងបទល្មើសលួចកាប់ឈើ សហគមន៍ យកទៅធ្វើអាជីវកម្ម និងកាប់ព្រៃសហគមន៍ដើម្បីដុតធ្វើធ្យូងលក់ មានអ្នកចូលរួមមានចំនួន១២នាក់ ។

សហគមន៍ភ្នំដងរែកសំម្រែកព្រៃស្រស់ នៅថ្ងៃទី៥ ខែមេសា ឆ្នាំ ២០១៧ បានឡើងមកធ្វើការបកស្រាយ និងបំភ្លឺតាមការកោះហៅ របស់តុលាការខេត្តឧត្តរមានជយ៍ ស្តីអំពីជនល្មើសបានធ្វើការឈូសឆាយដីព្រៃសហគមន៍។ លោក អ៊ឹម សៅ រិទ្ធិនាយខណ្ឌរដ្ឋបាលព្រៃឈើបានធ្វើការព្រមានដល់ជនល្មើសជាលើកទី២ សុំអោយបញ្ឈប់ការឈូស ឆាយដីរបស់សហគមន៍ទៀត។

នៅថ្ងៃទី២៩ខែសីហាឆ្នាំ២០១៧តំណាងសហគមន៍អណ្តូងបរ និងដុងបេងបានយកពាក្យបណ្តឹងមកដាក់ជូនប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទខេត្តឧត្តរមានជ័យស្តីពីកងទ័ពកងពលតូចអន្តរាគមន៍ថ្មើជើងលេខ៥ចំណុះឱ្យកងពលធំអន្តរាគមន៍ថ្មើជើងលេខ២បានបង្កើតបន្ទាយកងទ័ពនៅក្នុងដីព្រៃសហគមន៍និងធ្វើការឈូសឆាយអស់ដីប្រហែល១, ៦០០ហិចតា ពាក្យបណ្តឹងខាងលើមិនទាន់មានដំណោះស្រាយទេ។

*១.៤.បណ្តុះបណ្តាលច្បាប់ស្តីពីព្រៃឈើ និងអនុក្រិតនៃការបង្កើតសហគមន៍ព្រៃឈើសម្រាប់អ្នកដែលជាប់ឆ្នោតថ្មី*

បានបណ្តុះបណ្តាលច្បាប់ស្តីពីព្រៃឈើ និងអនុក្រិតស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ៣វគ្គ ដល់សហគមន៍ សមាជិកគណកម្មការសហគមន៍អ្នកដែលជាប់ឆ្នោតថ្មីចំនួន៤៥នាក់។ ក្រោយវគ្គពួកគាត់មានការយល់ដឹងពីច្បាប់ ស្តីពីព្រៃឈើ និងអនុក្រិត នៃការបង្កើតសហគមន៍ព្រៃឈើមានដូចជា៖ រដ្ឋបាលព្រៃឈើ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ការហាមឃាត់

ប្រមូលផល អនុផលព្រៃឈើ សិទ្ធិប្រើប្រាស់ជាប្រពៃណី និងការគ្រប់គ្រងព្រៃសហគមន៍ និងព្រៃ ឯកជន បទល្មើសព្រៃឈើ និងទោសប្បញ្ញត្តិ។ លក្ខខណ្ឌនៃការបង្កើតសហគមន៍ព្រៃឈើ តួនាទី ភារកិច្ច និងសិទ្ធិរបស់សហគមន៍ព្រៃឈើ គណៈកម្មការគ្រប់ គ្រងសហគមន៍ព្រៃឈើ។ ស្ថាប័ន និងអាជ្ញាធរសម្ថកិច្ចទទួលខុសត្រូវកិច្ចព្រមព្រៀងព្រៃសហគមន៍ និងផែនការ គ្រប់គ្រង ព្រៃសហគមន៍ ប្រភពហិរញ្ញវត្ថុទ្រទ្រង់សហគមន៍ព្រៃឈើ។ គណៈកម្មការ និងអនុគណៈកម្មការសហគមន៍ព្រៃឈើ បានយល់ដឹងពីអនុក្រិតនៃការបង្កើតសហគមន៍ព្រៃឈើ និងច្បាប់ស្តីពីព្រៃឈើ។ ក្រោយពីបានចូលរៀនពួកគាត់បានចូលរួម និងទុបស្កាត់បទល្មើសជាប្រចាំក្នុងការពារព្រៃ និងផ្សព្វផ្សាយដល់អ្នកដ៏ទៃ។

*១.៥.គាំទ្រការប្រជុំបណ្តាញសហគមន៍ព្រៃឈើជាមួយអាជ្ញាធរពាក់ព័ន្ធថ្នាក់ខេត្ត*

ការប្រជុំនេះមានការត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញលើផែនទីបទល្មើសកាប់រានដែលបានធ្វើកន្លងមកដើម្បីឱ្យបានជាក់លាក់ហើយធ្វើការកែសម្រួលជាថ្មី។ សហគមន៍នីមួយៗដាក់ចេញជាផែនការរបស់ខ្លួនឱ្យបានជាក់លាក់ដោយ កំណត់យកតែបញ្ហាសំខាន់មួយឬពីរតែប៉ុណ្ណោះ។ លទ្ធផលនៃអង្គប្រជុំរួមមានអ្នកចូលរួមចំនួន២៨នាក់ស្រី២នាក់ ក្រោយពីបានជួបជុំហើយលោកសារថ្លៃប្រធានបណ្តាញបញ្ជាក់និងពិនិត្យឡើងវិញនូវបញ្ហាសំខាន់ៗដែលកើតមាន នៅក្នុងសហគមន៍និងគូសបញ្ជាក់លើផែនទីឲ្យបានជាក់លាក់ជាថ្មីដើម្បីបណ្តាញយកមករៀបចំចងក្រងធ្វើជាបទបង្ហាញនៅក្នុងកិច្ចប្រជុំថ្នាក់ខេត្តដែលនឹងរៀបចំធ្វើនៅពេលខាងមុខឆាប់ៗខាងមុខនេះជាមួយអភិបាលខេត្ត។ ការប្រ ជុំនេះពុំទាន់បានរៀបចំឡើយជាមួយអភិបាលខេត្តដោយផ្ទាល់ព្រោះមានការ ពន្យារហូតលើកទី២មានការប្រជុំពិភា ក្សាអំពីវឌ្ឍនៈភាពនៃការគ្រប់គ្រងព្រៃឈើសហគមន៍ទូទាំងខេត្តឧត្តរមានជ័យថ្ងៃទី២២ខែមិថុនាឆ្នាំ២០១៧សមាសភាពអ្នកចូលរួម៖ ក្រោមអធិបតីភាពរបស់ឯ.ឧ វ៉ាត ប៉ាវ៉ានីន អភបាលរងខេត្តទទួលបន្ទុក មន្ទីកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មន្ទីបរិស្ថាន ខណ្ឌផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើ ទីចាត់ការអន្តរិស័យ អង្គការដៃគូរពាក់ព័ន្ធ ប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើទាំ១៣ បណ្តាញសហគមន៍ព្រៃឈើខេត្ត លទ្ធផលនៃកិច្ចប្រជុំ៖ មានអ្នលរួមចំនួន៣៧នាក់ ក្នុងនោះមានស្ត្រីចូលរួម៣នាក់។ ជាចុងក្រោយលោកអភិបាលរងខេត្តបានធ្វើការលើក ឡើងបញ្ជាក់សរសើដល់គណៈកម្មការសហគមន៍ព្រៃឈើទាំង១៣ព្រោះធ្វើការអត់ប្រាក់ខែក៏នៅតែចូលរួមការពារព្រៃសហគមន៍ទាំងអស់មកដល់សព្វថ្ងៃនេះទោះបីជាជួបបញ្ហាប្រឈមច្រើនយ៉ាងណាក៏ដោយ។ លោកបានបន្ថែមទៀតថា កិច្ចប្រជុំនេះបានលើក ឡើងនូវចំណុចល្អៗមានច្រើនចំណុចសំខាន់ៗសូមសរុបយកចំណុចមកដាក់ក្នុងផែន ការទាំង ៦ចំណុច៖

១.ប្រគល់កិច្ចការអោយទៅលោក សា ថ្លៃ ជាអ្នកសំរបសំរួលគ្រប់សហគមន៍ ធ្វើការចងក្រងប្រវត្តិសហគមន៍ និមួយៗចងក្រងវឌ្ឍនៈភាពនៃការគ្រប់គ្រងពីលទ្ធផលសំរេចបាន ពីបញ្ហាប្រឈមដោយមានផែនទីចង្អុល បង្ហាញពីទីតាំងបទល្មើសនិងពីសំណូមពររបស់សហគមន៍និមួយៗ

២.ខណ្ឌរដ្ឋបាលព្រៃឈើ មន្ទីរកសិកម្ម និងមន្ទីបរិស្ថាន បូកសរុបរបាយការណ៍នៃការគ្រប់គ្រងសហគមន៍ ព្រៃឈើកំណត់យកថ្ងៃទី០៥ខែកក្កដាឆ្នាំ២០១៧។

៣.បន្តការសហការការពារព្រៃឈើដែលនៅសល់អោយបានគង់វង្ស ដោយរិតបន្តឹងការអនុវត្តច្បាប់ស្តីព្រៃឈើ

៤.ខេត្តរាយការណ៍អំពីវឌ្ឍនៈភាព អំពីបញ្ហារបស់សហគមន៍ទៅក្រសួងកសិកម្ម និងក្រសួងបរិស្ថានដើម្បីធ្វើការពិនិត្យសំរេច

៥.សុំអោយអង្គការដៃគូរបន្តជួយសហគមន៍ ទាំងបច្ចេកទេស និងថវិកាដល់សហគមន៍អោយបានទូរលំទូលាយជាងមុនទៀត។

ជាលទ្ធផលរហូតដល់ពេលនេះបញ្ហាសហគមន៍ដែលលើកក្នុងអង្គប្រជុំមិនមានដំណោះស្រាយអ្វីឡើយ។

*១.៦.ការដឹកធ្វើប្រឡាយព្រំដល់២សហគមន៍*

នៅថ្ងៃទី១៥និង១៦ខែមីនាឆ្នាំ២០១៧ សហគមន៍ព្រៃស្រស់បានជីកប្រឡាយបានចំនួន៧៧៨ម៉ែត្រ ដែលមានអ្នកចូលរួម៣៨នាក់និងស្រីក្នុងនោះមានអភិបាលរងស្រុកបន្ទាយអំពិលម្នាក់ នាយផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើ

បន្ទាយអំពិល ទាហ៊ានសឹករងក្រុងសំរោងម្នាក់ នគរបាលប៉ុស្តិ៍ឃុំគោកខ្ពស់ម្នាក់ ជំទប់ទី១ឃុំគោកខ្ពស់ មេភូមិមនោរម្យម្នាក់។ ការកាយព្រំនេះដោយសារតំបន់នោះមានការរុករានដីព្រៃសហគមន៍ពីប្រជាជនមកពីសង្កាត់បន្សាយរាក់ កងទ័ពមួយ ចំនួន និងតំបន់នេះជាប់នឹងព្រំប្រទល់ព្រៃសហគមន៍រំដួលវាសនាផងដែរដែលតែមានជំលោះជាមួយគ្នា ប្រវែងព្រំប្រទល់ដែលត្រូវជីកមាន៦,៥០០ម ចាប់ពី UTM (0329678-1584500 ដល់ 329326-1584992) ជីកបានសរុបស្មើនឹង12% នៃប្រវែងដីដែលត្រូវជីកសរុប ទំហំដែលត្រូវជីកជំរៅ០.៨ម និងទទឹង០.៨ម គឺស្មើនឹងមួយដៃExcavator ។ នៅថ្ងៃទី១៧ និង១៩ ខែឧសភា ឆ្នាំ២០១៧ សហគមន៍រតនរុក្ខា បានជីកប្រឡាយព្រំប្រទល់ព្រៃសហគមន៍បានចំនួនចំនួន៧៥០ម៉ែត្រទំហំដែលត្រូវជីកជំរៅ១មនិងទទឹង១មគឺស្មើនឹងមួយដៃExcavatorមានការចូលរួមពីគណៈកម្មការសហគមន៍ព្រៃឈើចំនួន៣នាក់និងCTOម្នាក់មុននឹងជីកព្រំនេះមានការចុះទៅសិក្សាជាក់ស្តែងមុនដែលមានការចូលរួមពីសង្កាត់រដ្ឋបាលព្រៃឈើសំរោង អភិបាលរងក្រុងសំរោង ក្រុមប្រឹក្សាសង្កាត់សំរោង និងគណៈកម្មការ សហគមន៍ព្រៃឈើ ដោយសម្រេចថាត្រូវជីកត្រង់ វាលចោលចៀល UTM (357199-1559668 ដល់ 357199-15660418) ប្រវែងព្រំប្រទល់សរុប96,000ម៉ែត្រ ជីកបានសរុប៨ភាគរយនៃផ្ទៃដីសរុប។ ប្រឡាយទាំងពីរសហគមន៍ដែលបាន ជីករួចមាន១,៥២៨ម៉ែត្រ។

*១.៧.ការប្រជុំគណៈកម្មការសហគមន៍ ជាមួយសមាជិកពិភាក្សាក្នុងការដាំដំណាំយុទ្ធសាស្ត្រតាមព្រំប្រទល់ព្រៃសហគមន៍ភ្នំដងរ៉ែកសម្រែកព្រៃស្រស់ និងរតនរុក្ខា*

សហគមន៍ភ្នំដងរ៉ែកសម្រែកព្រៃស្រស់ និងរតនរុក្ខា មានការប្រជុំពិភាក្សាគ្នាលើការដាំដំណាំយុទ្ធសាស្ត្រក្នុងការការពារព្រំប្រទល់ព្រៃសហគមន៍។ ក្រោយពីការប្រជុំសហគមន៍ទាំងពីរ បានសម្រចចិត្តជ្រើសរើសឬស្សីសម្រាប់យកទំពាំងដើម្បីដាំនៅ២កន្លែងដើម្បីដាំសាកល្បង គឺនៅក្នុងព្រៃសហគមន៍រតនរុក្ខាក្បែរផ្ទះ លោក ជា ជួង ប្រធានសហគមន៍ និងដាំក្បែរោងយាមសហគមន៍ព្រៃស្រស់ ស្ថិតនៅទល់មុខផ្ទះលោកមេភូមិមនោរម្យមួយ ក្បែរស្រះទឹកសហគមន៍សម្រាប់ស្រោចនៅរដូវប្រាំង។ ឫស្សីសរុបដាំបានក្នុងមួយសហគមន៍ចំនួន១៨០ដើម សរុបទាំងអស់៣៦០ដើមដែលបានដាំរួច។ សមាជិកសហគមន៍ចូលរួមដាំ៤៨នាក់/ស្រី១៦នាក់លោកមេឃុំគោកខ្ពស់បានចូលរួមក្នុងការដាំ នៅសហគមន៍ ព្រៃស្រស់ផងដែរ។

*១.៨.សម្របសម្រួលការស្នើសុំរបស់ប្រជាជនរងផលប៉ះពាល់ដីធ្លី ដើម្បីជួបផ្ទាល់ពិភាក្សាជាមួយអភិបាលខេត្ត រដ្ឋមន្រ្តីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ*

តំណាងសហគមន៍ភូមិអូរបាត់មាន់បានទៅជួប អភិបាលខេត្ត ប្រធានមន្ទីកសិកម្មខេត្តចំនួន១លើកដើម្បីស្នើសុំដោះស្រាយបញ្ហាដីធ្លីដែលលោកអភិបាលខេត្ត បានសន្យានៅក្នុងខែសីហាឆ្នាំ២០១៦។ លទ្ធផលនៃការទៅជួបអភិបាលខេត្តមានតំណាងសហគមន៍និងប្រជាជនចំនួន៥០នាក់ស្រី២៧នាក់លោកអភិបាលខេត្តនិងប្រធានមន្ទីកសិកម្មខេត្តបានធ្វើការបញ្ជាក់ដល់អ្នករងគ្រោះបញ្ហាដីធ្លីទាំងអស់និងតំណាងមេត្តាស្រង់ឈ្មោះគ្រួសារដែលរងផលប៉ះពាល់អោយបានជាក់លាក់ក្រោយពីបានបញ្ជីរឈ្មោះហើយក្រុមការងារនិងចុះទៅធ្វើការបញ្ជាក់បន្ថែមដល់គ្រួសារទាំងនោះរួចហើយអោយតំណាងធ្វើលិខិតស្នើសុំដីសម្បទានសង្គមកិច្ចយកមកប្រើប្រាស់ទៅតាមគ្រួសារ។ នៅថ្ងៃទី០៦ខែ កក្កដា ឆ្នាំ២០១៧ អភិបាលខេត្តបានហៅតំណាងប្រជាពលរដ្ឋចំនួន៩នាក់ ទៅជួបនៅដីក្រុមហ៊ុន ដោយសន្យាថា ចែកដីអោយគ្រួសារដែលបាត់បង់ដីក្នុងមួយគ្រួសារចំនួន២ហិកតានិងដីលំនៅដ្ឋានចំនួន៥០មX៥០ម។ តែតំណាង សហគមន៍ប្រជាពលរដ្ឋមិនទាន់សម្រេចចិត្តភ្លាមៗទេ។ ប្រហែលជាពាក់កណ្តាលខែ០៨នឹង និងប្រជុំជាមួយប្រជាពល រដ្ឋទាំងអស់ដើម្បីសម្រេចចិត្តចុងក្រោយក្នុងនោះអាជ្ញាធរក៏សន្យាចូលរួមដែរ។ ក្រុមការងារដែលចូលរួមជាមួយអភិបាលខេត្ត មានអភិបាលក្រុង មេឃុំ មេភូមិ ព្រមទាំងទូរទស្សន៍ ទទកប្រចាំខេត្តផងដែរ។ ក្រុមការងារអន្តរក្រសួង បានចុះវាស់ដីអោយពួកគាត់ហើយ តែមិនទាន់ចេញបន្លង់អោយពួកគាត់នៅឡើយទេ។

*១.៩.សម្របសម្រួលការជួបរបស់សហគមន៍ព្រៃឈើជាមួយរដ្ឋមន្រ្តីក្រសួងកសិកម្មរុក្ខា ប្រមាញ់និងនេសាទ*

ក្រោយពីធ្វើការប្រជុំសម្រេចគ្នារួចមកសហគមន៍ដែលមានបញ្ហាខ្លាំងចំនួន៤មានដូចជា: សហគមន៍ព្រៃឈើអណ្តូង បរ ដុងបេង រំដួលវាសនា និងសាមគ្គីសង្គ្រោះព្រៃឈើ បានដាក់ពាក្យបណ្តឹងទៅក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដើម្បីស្វែងរកដំណោះស្រាយ។ ក្នុងនោះមានតំណាងសហគមន៍៥នាក់បានចូលរួមកាន់ពាក្យបណ្តឹង ដោយរដ្ឋបាលក្រ សួងបានសន្យានឹងយកពាក្យបណ្តឹងនេះទៅជូនដល់ដៃរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទផ្ទាល់។

*១.១០.សម្របសម្រួលការប្រជុំថ្នាក់ស្រុកជុំវិញករណីដំណោះស្រាយព្រំប្រទល់ព្រៃស្រស់ និងរំដួលវាសនា*

ថ្ងៃទី១៨ខែវិច្ឆិកាឆ្នាំ២០១៧ក្រោយពីការជួបជាមួយអភិបាលស្រុកបន្ទាយអំពិលនិងអភិបាលក្រុងសំរោងសម្រេចបានការដោះស្រាយព្រំប្រទល់រួច។ ហើយមានការពិភាក្សាពីការដាក់បង្គោលព្រំនិងប្លាកសញ្ញាគឺដើម្បីអោយសហគមន៍បានយល់ដឹងនឹងរួមចំណែកការពារព្រៃឈើសហគមន៍អោយបានគង់វង្សសម្រាប់ក្មេងជំនាន់ក្រោយ។ ធ្វើការ ទប់ស្កាត់បទល្មើសដែលចូលលួចកាប់បំផ្លាញព្រៃឈើសហគមន៍បន្តទៀត។ អ្នកចូលរួមសិស្ស២៩នាក់ស្រី១៨នាក់ សហគមន៍ គ្រូបង្រៀន រដ្ឋាបាលព្រៃឈើ មេភូមិ បុគ្គលិកអង្គការ មានទាំងអស់២២នាក់ស្រី៣នាក់ សរុបអ្នកចូលរួមចំនួន៥១នាក់ស្រី២១នាក់។ មានបង្គោលថ្មចំនួន២៥ និងផ្លាកសញ្ញាចំនួន២៥ផ្ទាំង។ អ្នកភូមិដែលរស់នៅជិតព្រៃឈើសហគមន៍បានយល់ដឹងអំពីសារៈប្រយោជន៍ នៃការពារព្រៃសហគមន៍អោយបានគង់វង្ស សំរាប់កូនចៅជំនន់ ក្រោយ។ បើថែរក្សាព្រៃឈើបានគង់វង្ស គឺធ្វើអោយពួកគាត់មានប្រាក់ចំណូលប្រចាំគ្រួសារ ដោយទាញយកផល និងអនុផលពីព្រៃឈើ។

*១.១១.បង្ហាត់បង្ហាញបន្ថែមជាប្រចាំនិងតាមដានឆ្លុះបញ្ចាំងដល់គណៈកម្មការក្រុមសន្សំ២១ក្រុម ធនាគារស្រូវ៨ក្រុម*

អង្គការកែប្រែសហគមន៍ មានការតាមដាន និងជួយពង្រឹងសម្ថភាពបន្ថែមជាប្រចាំលើក្រុមសន្សំចំនួន២១ក្រុម និងធនាគាស្រូវចំនួន៨ក្រុម ដែលស្ថិតក្នុង២០ភូមិ។ ក្រុមសន្សំមាន៖ ក្នុងសង្កាត់សំរោង៨ភូមិស្មើនឹង៩ក្រុម ដែលមានភូមិ ឈូក២ក្រុម និងកូនក្រៀល៣ភូមិស្មើនឹង៣ក្រុម នៃក្រុងសំរោង។ សង្កាត់បន្សាយរាក់៥ភូមិស្មើនឹង៥ក្រុម។ ឃុំគោកខ្ពស់នៃស្រុកបន្ទាយអំពិលមាន៤ភូមិស្មើនឹង៤ក្រុម។ ធនាគាស្រូវមាន៖ ក្នុងសង្កាត់សំរោង៤ភូមិ ស្មើនឹង ៤ក្រុម សង្កាត់បន្សាយរាក់ក្រុងសំរោង២ភូមិស្មើនឹង២ក្រុម និងឃុំគោកខ្ពស់ស្រុកបន្ទាយអំពិល២ភូមិស្មើនឹង២ក្រុម។ ថវិកា និងស្រូវមានការកើនឡើងក្នុងតារាងសកម្មភាព១.១២។

*១.១២.ប្រជុំឆ្លុះបញ្ចាំង១ឆ្នាំម្តង(ក្រុមសន្សំ២១និងធនាគាស្រូវ ៨ និងកសិករគំរូ១៧*

ប្រជុំធ្វើការឆ្លុះបញ្ចាំងសកម្មភាពប្រចាំឆ្នាំក្រុម និងធនាគារស្រូវថ្ងៃទី៣០ខែ១២នៅមន្ទីផែនការខេត្តឧត្តរមានជ័យ សមាសភាពអ្នកចូលរួមមានអាជ្ញាធរឃុំមានទាំងសង្កាត់សំរោង បន្សាយរាក់ កូនក្រៀល និងឃុំគោកខ្ពស់ គណៈកម្មការសន្សំ និងធនាគារស្រូវសរុបទាំងអស់មានអ្នកចូលរួមចំនួន៣៩នាក់ស្រី២៣នាក់ ដែលមានមក ពីក្រុមសន្សំ ២១ក្រុម និងធនាគាស្រូវ៨ក្រុម។ អ្នកចូលរួមបានយល់ដឹងអំពីចំណុចខ្លាំងនៃការបង្កើតក្រុមសន្សំ និងធនាគារ ស្រូវនៅក្នុងភូមិព្រមទាំងដឹងអំពីចំណុចខ្វះខាតដែលបានអនុវត្តសកម្មភាពកន្លងមកដើម្បីស្វែងរកយុទ្ធសាស្ត្ររួមគ្នាក្នុង ការអនុវត្តសកម្មភាពបន្តក្នុងឆ្នាំ២០១៨ អោយមាននិរន្តភាពក្នុងការគ្រប់គ្រងសមាជិកនិងថវិកា។ អាជ្ញាធរបាន ដឹងនិងទទួលស្គាល់ក្នុងការជួយសម្របសម្រួលអោយដំណើរការគ្រប់ក្រុមមានភាពរីកចំរើន និងធ្វើការគៀងគររក អ្នកគាំទ្រដល់ក្រុមបន្ថែមទៀត។

ធនាគារស្រូវនៅភូមិឈើស្លាប់គណៈកម្មការ និងសមាជិកបានឯកភាពគ្នា លក់ស្រូវដើម្បីសាងសង់ជង្រុកស្រូវថ្មី និងជូនដល់សហគមន៍ព្រៃឈើចំនួន២០,០០០រៀលក្នុងការជីកប្រឡាយព្រំ។ ធនាគាស្រូវនៅភូមិឆ្អើប គណៈកម្មការ និងមេភូមិបានឯកភាពគ្នាកាត់ចោលលើសមាជិកជំពាក់ចាស់ហើយធ្វើការចំណាកស្រុកទៅខេត្តឆ្ងាយ ដែលមិន សង្ឃឹមថាសងវិញ។ ភូមិគាប និងគោកខ្ពស់ សមាជិកខ្លះសុំដកមូលហេតុពួកគេទៅធ្វើការឆ្ងាយនៅប្រទេសថៃ មិនអាចចូលរួមបន្ត។

**ទិន្នន័យក្រុមសន្សំចុង ឆ្នាំ ២០១៧(ថវិកាខាងក្រោមមេគុណ១០០)**

| ល | ឈ្មោះ | ចំនួនសមាជិក | សរុ | ចំនួន | ប្រាក់ដើ | សន្សំ | ស | សរុបចុង | ដើមឆ្នាំ | រីកចំរើន |
|---|---|---|---|---|---|---|---|---|---|---|

| រ | ភូមិ | ឃុំ/សង្កាត់ | ប | ស | ប | ក្រុម | ម | | គ្រោះ | ឆ្នាំ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | ពុរ | សំរោង | 1 | 21 | 22 | 1 | 35,200 | 14,950 | 260 | 50,410 | 13,600 | 36,810 |
| 2 | ឈូក | សំរោង | 3 | 33 | 36 | 2 | 27,000 | 37,700 | 920 | 65,620 | 23,300 | 42,320 |
| 4 | ដូនកែន | សំរោង | 3 | 27 | 30 | 1 | 28,000 | 27,390 | 2,000 | 57,390 | 28,500 | 28,890 |
| 4 | អូរកន្សែង | សំរោង | 4 | 15 | 19 | 1 | 30,000 | 6,000 | 700 | 36,700 | 8,300 | 28,400 |
| 5 | អូរឬស្សី | សំរោង | 2 | 17 | 19 | 1 | 30,390 | 5,600 | 420 | 36,410 | 9,500 | 26,910 |
| 6 | ឆ្អើប | សំរោង | 2 | 15 | 17 | 1 | 64,200 | 25,260 | 600 | 90,060 | 25,000 | 65,060 |
| 7 | កូនដំរី | សំរោង | 1 | 21 | 22 | 1 | 48,000 | 2,600 | 0 | 50,600 | 16,800 | 33,800 |
| 8 | បាក់និម | សំរោង | 1 | 20 | 20 | 1 | 102,000 | 7,000 | 0 | 109,000 | 8,800 | 100,200 |
| **9** | **សរុបរួម** | | **17** | **169** | **185** | **9** | **364,790** | **126,500** | **4,900** | **496,190** | **133,800** | **362,390** |
| 1 | បន្សាយរាក់ | បន្សាយរាក់ | 1 | 20 | 21 | 1 | 30,000 | 15,000 | 1,000 | 46,000 | 17,800 | 28,200 |
| 2 | រំដួលវាសនា | បន្សាយរាក់ | 1 | 21 | 22 | 1 | 77,500 | 15,000 | 880 | 93,380 | 22,500 | 70,880 |
| 3 | សំបួរមាស | បន្សាយរាក់ | 2 | 16 | 18 | 1 | 20,000 | 15,000 | 250 | 35,250 | 6,200 | 29,050 |
| 4 | ត្នោត | បន្សាយរាក់ | 3 | 19 | 22 | 1 | 16,000 | 15,000 | 0 | 31,000 | 17,500 | 13,500 |
| 5 | ពោធិវង្ស | បន្សាយរាក់ | 3 | 15 | 18 | 1 | 47,800 | 15,000 | 120 | 62,920 | 8,800 | 45,420 |
| **5** | **សរុបរួម** | | **10** | **91** | **101** | **5** | **161,300** | **60,000** | **1,250** | **222,550** | **46,200** | **158,850** |
| 1 | អូរទង | គោកខ្ពស់ | 1 | 20 | 21 | 1 | 85,800 | 25,900 | 0 | 111,700 | 27,600 | 84,100 |
| 2 | ឈើស្លាប់ | គោកខ្ពស់ | 3 | 17 | 20 | 1 | 116,600 | 3,970 | 690 | 121,260 | 17,500 | 103,760 |
| 3 | គាប | គោកខ្ពស់ | 4 | 12 | 16 | 1 | 0 | 4,000 | 300 | 4,300 | 6,200 | -1,900 |
| 4 | គោកខ្ពស់ | គោកខ្ពស់ | 5 | 11 | 16 | 1 | 4,000 | 2,340 | 285 | 6,625 | 27,800 | -21,175 |
| **4** | **សរុបរួម** | | **13** | **60** | **73** | **4** | **206,400** | **36,210** | **1,275** | **243,885** | **79,100** | **164,785** |
| 1 | ខ្ចុំ | កូនក្រៀល | 5 | 21 | 26 | 1 | 20,000 | 10,600 | 700 | 31,300 | 20,000 | 11,300 |
| 2 | តាម៉ាន | កូនក្រៀល | 3 | 19 | 22 | 1 | 80,000 | 13,200 | 0 | 93,200 | 11,800 | 81,400 |
| 3 | ត្រពាំងវែង | កូនក្រៀល | 10 | 9 | 19 | 1 | 67,000 | 3,000 | 0 | 70,000 | 4,800 | 65,200 |
| **3** | **សរុបរួម** | | **18** | **49** | **67** | **3** | **167,000** | **26,800** | **700** | **194,500** | **36,600** | **157,900** |
| 21 | សរុប | | 58 | 369 | 426 | 21 | 899,490 | 249,510 | 8,125 | 1,157,125 | 295,700 | 843,925 |

**ធនាគារស្រូវឆ្នាំ២០១៧**

| លរ | ឈ្មោះភូមិ | ឃុំ | ក្រុង | ចំនួនសមាជិក | | | ចំនួនស្រូវចុងឆ្នាំ/គីឡូក្រាម | ចំនួនស្រូវសរុបដើមឆ្នាំ | ចំនួនស្រូវកើនឡើង |
|---|---|---|---|---|---|---|---|---|---|
| | | | | ប្រុស | ស្រី | សរុប | | | |
| ១ | ភូមិឆ្អើប | សំរោង | សំរោង | ៤ | ២៥ | ២៩ | 10,070 | 10,070 | - |
| ២ | ភូមិកូនដំរី | សំរោង | សំរោង | ១២ | ២០ | ៣២ | 3,500 | 3,220 | 280 |
| ៣ | ភូមិបាក់និម | សំរោង | សំរោង | ១១ | ១៥ | ២៦ | 6,264 | 3,560 | 2,704 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៤ | គោក ច្រេស | សំរោង | សំរោង | ២ | ១៦ | ១៨ | 3,200 | 3,050 | 150 |
| | | | | ២៩ | ៧៦ | ១០៥ | 23,034 | 19,900 | 3,134 |
| ១ | ភូមិឈើស្លាប់ | គោកខ្ពស់ | បន្ទាយអំពិល | ៥ | ៣៤ | ៣៩ | 9,600 | 10,050 | (450) |
| ២ | ភូមិអូរទេង | គោកខ្ពស់ | បន្ទាយអំពិល | ៨ | ៥១ | ៥៩ | 11,078 | 7,877 | 3,201 |
| | | | | ១៣ | ៨៥ | ៩៨ | 20,678 | 17,927 | 2,751 |
| ១ | ភូមិសំបូរមាស | បន្សាយរាក់ | សំរោង | ៦ | ២៨ | ៣៤ | 4,300 | 5,269 | (969) |
| ២ | ភូមិត្នោត | បន្សាយរាក់ | សំរោង | ៣ | ១២ | ១៥ | 3,500 | 3,020 | 480 |
| | ៨ | | | ៩ | ៤០ | ៤៩ | 7,800 | 8,289 | (489) |
| | | សរុបរួម | | ៥១ | ២០១ | ២៥២ | 51,512 | 46,116 | 5,396 |

*១.១៣.ប្រជុំបណ្តាញសន្តិសុខស្បៀងថ្នាក់ជាតិ១ឆ្នាំ៣ដង*

(មិនបានអនុវត្តទេ) ដោយពុំបានរៀបចំគ្រោងថវិកាសកម្មភាពនេះឡើយ។

*១.១៤.កែលំអរធនាគារស្រូវ៨និងនិងដាក់ផ្លាកសញ្ញា៥បន្ថែមទៀតមានភូមិគោកច្រេស ភូមិឆ្អើប បាក់និម កូនដំរី*
ចុះធ្វើសកម្មភាពចាប់ថ្ងៃទី៧ដល់ថ្ងៃទី២៣ខែមីនាឆ្នាំ២០១៧ ដើម្បីការជួសជុលជង្រុកស្រូវសហាគមន៍ចំនួន៦កន្លែងដែលមានការខូចខាតនិងធ្លុះធ្លាយដំបូលនិងបាតជង្រុកធ្វើអោយបាត់បង់ស្រូវសហាគមន៍ជង្រុកដែលបានជួសជុលមាន៖ ភូមិអូរទេង ,ភូមិឈើស្លាប់, ភូមិសំបូរមាស, ភូមិកូនដំរី. ភូមិបាក់និមនិងភូមិឆ្អើប ក្រោយពីការជួសជុលបានដាក់ផ្លាកសញ្ញានៅតាមជង្រុកចំនួន៥កន្លែង មានភូមិកូនដំរី បាក់និម ឆ្អើប សំបូរមាស និងគោកច្រេស មានអ្នកចូលរួមចំនួន៦៨នាក់ក្នុងនោះមានស្រី៤៥នាក់។ លទ្ធផលការជួសជុលជង្រុកស្រូវសហាគមន៍ទាំង៨គឺមានចូលរួមពីសហាគមន៍ផងដែរ ទាំងស្មាតី សម្ភារៈ ក្នុងការរួមចំណែកការពារស្រូវអោយបានគង់វង្ស ។

| លរ | ឈ្មោះ ភូមិ | ប្រភេទជួសជុល |
|---|---|---|
| ១ | ឈើស្លាប់ | ជួយសង្កសីសម្រាប់ធ្វើជង្រុកថ្មី |
| ២ | អូរទេង | ស័ង្កសី និងក្តាបាត |
| ៣ | កូនដំរី | ធ្វើទ្វាជង្រុក ដំបូល និងដាក់ប្លាក |
| ៤ | បាក់និម | ជួសជុលទ្វាជង្រុក និងមេសោ |
| ៥ | ឆ្អើប | ជួសជុលក្តាបាត និងដាក់ប្លាក |
| ៦ | គោកច្រេស | ធ្វើទ្វារ ក្តាជញ្ជាំង និងដាក់ប្លាក |
| ៧ | សំបូរមាស | ជួសជុលក្តាបាត និងដំបូល ដាក់ប្លាក |
| ៨ | ត្នោត | ជួសជុលក្តាបាត និងដំបូល ដាក់ប្លាក |

| សូចនករ | ផែនការប្រចាំឆ្នាំ | លទ្ធផលប្រចាំឆ្នាំ | ពន្យល់ពីគម្លាត |
|---|---|---|---|
| ចំនួនសមាជិកដែលបានដកហូតអនុផលព្រៃឈើ | 3,226 | 3,226 | ជីកដំឡូង បេះផ្សិត រកឃ្មុំ ជីកទំពាំង ឬស្សី ស្បូវ បេះបន្លែ ព្រៃចកអណ្តើក ក្បុក បន្លែព្រៃ ស្តៅ វាំង អុស។ល។ |
| ចំនួនបទល្មើសដែលពួកគាត់បានទុបស្កាត់ និងដោះស្រាយ | 11 | 13 | បទល្មើសនៅតែកើតឡើង១ករណី |

| | | | |
|---|---|---|---|
| សមាជិកក្រុមសន្សំចំនួន២១៧នាក់ស្រ្តី/ 154នាក់មានប្រាក់សន្សំកើនឡើងនៅក្នុង ២១ក្រុម | 217 | 426 | មានការចូលរួមកើនឡើងរបស់សមាជិក២០៩នាក់ និងថវិកា៨៤,៣៩២,៥០០រៀល។ |
| ធនាគាស្រូវ៨ចំនួន220នាក់ស្រ្តី/ 110នាក់មានកាកើនឡើងចំនួនស្រូវរបស់ពួកាត់ | 8 | 8 | ស្រូវមានការកើនឡើងប្រចាំឆ្នាំ ២០១៧ 5,396 គីឡូក្រាម។ |

**លទ្ធផលទី២៖ កុមារចំនួន៥៨១នាក់/កុមារី៣៣៨នាក់ស្ថិតនៅឃុំសំរោងបន្ទាយរាក់និងគោកខ្ពស់មានការចូលរួមយ៉ាងសកម្មក្នុងការអភិឌ្ឍសហគមន៍ តាមរយៈ ការគូរសារ កម្មវិធីសប្បាយៗ ក្លឹបកុមារ និងការលើកកំពស់សិទ្ធិក្នុងសាលារៀន។**

*២.១.ប្រមូលសារកុមារ*

សម្រាប់ឆ្នាំ២០១៧ នេះស៊ីធីអូ បានធ្វើការប្រមូលសារ ក្មេងសរុប ៦១២នាក់ មានកុមារី ៣៥២នាក់ និងបានផ្ញើជូនអាក់សិនអេត ៥៨២នាក់មានកុមារី៣៣៩នាក់។ ក្នុងនោះកុមារគូរសារបានចំណាកស្រុកចំនួន៣០នាក់ មានកុមារីចំនួន១៣នាក់។ ការដឹកនាំកុមារគូរសារនេះគឺអោយកុមារដឹងពីផលប្រយោជន៍នៃការគូរគំនូររបស់ពួកគេ ហើយអោយពួកគេចេះសំអាតខ្លួនប្រាណចេះដុសធ្មេញនិងចេះលាងដៃមុនពេលហូបចំនីអាហារ និងការពង្រឹងឲ្យកុមារមានភាពក្លាហាន។ លទ្ធផលដែលទទួលបានកុមារចេះជួយពន្យល់មិត្តភក្តិមកចូលរួមគូររូប។ កុមារដែលគូររូបបានស្អាតជួយបង្រៀនកុមារដែលពុំសូវចេះគូររូបអោយចេះគូរ និងចេះសំអាតខ្លួនមុនពេលទៅសាលា ចេះលាងដៃមុនពេលហូបចំនីអាហារ និងមានភាពក្លាហានក្នុងការចូលរួមគូរសារ និងការឆ្លើយរាល់សំនួរដែលបានសួរទៅពួកគាត់។

*២.២.ប្រជុំជនបង្គោលស្ម័គ្រចិត្ត*

មានការប្រជុំជនបង្គោលស្ម័គ្រចិត្តបានចំនួន២ដង អ្នកចូលរួមទាំងអស់ ២៨នាក់/ ស្រី ២៤នាក់។ អ្នកស្ម័គ្រចិត្តទាំងអស់បានយល់ដឹងច្បាស់ពីកម្មវិធីកុមារនិងការគ្រប់គ្រងកុមារនៅក្នុងសហគមន៍។ ហើយពួកគាត់បានយល់ដឹងពីតួនាទីរបស់ខ្លួនដូចជា៖

- គ្រូបង្គោលត្រូវមានភាពទទួលខុសត្រូវទាំងសម្ភារះ តារាងឈ្មោះសិស្ស គូរសា និងទីកន្លែងជាក់លាក
- ធ្វើការទំនាក់ទំនងជាមួយឪពុកម្តាយ អជ្ញាធរ និងលោកគ្រូអ្នកគ្រូ
- ផ្តល់ពតិមានដល់ក្មេងនៅពេលមានការចុះជួបពីអង្គការ ស៊ី ធី អូ
- អប់រំ និងពន្យល់ ដល់ក្មេងអំពី ប្រយោជន៍នៃការគូរសា
- ផ្តល់ពតិមានមកអង្គការ នៅពេលមានករណីចាំបាច់ ដូចជា ( រំលោភ ជួញដូរ ឬហឹង្សាកុមារជាដើម)
- រៀបចំផែនការសកម្មភាព មុនពេលចុះនាំក្មេងគូរសា
- ពន្យល់ ពីរបៀប ផាត់ពណ៌ របៀបគូរសា ត្រួតពិនិត្យសារ និងសម្របសម្រួលក្នុងការគូរសា។
- បង្កើតភាពស្និតស្នាលជាមួយក្មេងគូសារ
- ➢ ជាពិសេសអ្នកគ្រូស្ម័គ្រចិត្តទាំង២០ ភូមិបានយល់ដឹងពី៖
- កម្មវិធីកុមារកាន់តែច្បាស់និងជួយបញ្រ្ជាប់ដល់កុមារនិងឪពុកម្តាយគូរសារអោយបានយល់ ពីកម្មវិធីគូរសារ
- បានយល់ដឹងពី ឧបករណ៍ តាមដានកុមារចំណាកស្រុក
- ➢ ហើយពួកគាត់បានយល់ដឹងការរៀបចំទុកដាក់ឯកសារមួយចំនួន៖
- ការតំកល់តាមអក្ខរក្រម
- ការតំកល់តាមប្រធានបទ
- ការតំកល់តាមកាលបរិច្ឆេទ

- ការតំកល់តាមភូមិសាស្ត្រ
- ការតំកល់តាមលេខ

ជនបង្គោលស្ម័គ្រចិត្តបានធ្វើផែនការរួមគ្នា សម្រាប់ប្រមូលសារកុមារលើកទី២ឆ្នាំ២០១៧ ដើម្បីពួកគាត់ងាយស្រួលក្នុងការសហការណ៍។ ជនបង្គោលស្ម័គ្រចិត្តទាំងអស់មានការចូលរួមយ៉ាងសកម្ម ក្នុងកម្មវិធីសប្បាយៗ និងការគូសារដែលពួកគាត់មកពី១៨ភូមិ។

*២.៣.ចែកសម្ភារៈក្លឹបកុមារ*

អង្គការស៊ីធីអូ បានរៀបចំចែកសម្ភារៈក្លឹបកុមារចំនួន១០ សាលា នៅក្នុង ខេត្តឧត្តរមានជ័យ ថ្ងៃទី ១៤-១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ ដែលមានអ្នកចូលរួមសរុប ១១៥ នាក់ស្រី ៥៦ នាក់ ដែលមានសាលាដូចជា បឋមដូនកែនត្បៀត បឋមសិក្សាសំរោង បឋមសិក្សាគោកគរ បឋមសិក្សាហ៊ុនសែនឆ្អើប បឋមសិក្សាបន្សាយរាក់ បឋមសិក្សាអូរទេង បឋមសិក្សាត្នោត បឋមសិក្សាពោធិវង្ស បឋមសិក្សាឈើស្លាប់ និង បឋមសិក្សាគោកខ្ពស់ថ្មី ។ លទ្ធផលទទួលបានៈ

- បានផ្តល់សម្ភារៈក្លឹបកុមារ ចំនួន១០ក្លឹប
- បានផ្តល់សម្ភារៈដល់ក្លឹបមានដូចជា កន្ទ្រៃ ប៊ិច សៀវភៅសរសេរ ក្រដាសផ្ទាំងធំ បាល់ទាត់ សីទាត់ ក្រដារព័ណទូរផ្តៅ សៀវភៅរឿងព្រេង ខ្មៅដៃ រ៉ាកែត ម្មូលសប់បាល

| **សុចនាករ** | **ផែនការ៦ខែ** | **លទ្ធផល៦ខែ** | **ពន្យល់ពីគម្លាត** |
|---|---|---|---|
| កុមារគូសារ | ៦១២/៣៥២ | ៦១២/៣៥២ | មានការប្រមូលបន្ថែម |

**លទ្ធផលទី ៣៖ អង្គការCTOជាស្ថាប័នដែលមានគណនេយ្យភាព និងតម្លាភាពចំពោះម្ចាស់ជំនួយ និងអ្នកទទួលផល**

*៣.១.ការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ*

ដោយយោងទៅលើកាលវិភាគផែនការប្រជុំប្រចាំឆ្នាំនិងស្ថានភាពចាំបាច់ដែលត្រូវដោះស្រាយមួយចំនួន ទើបយើងបានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំនេះ ក្នុងនោះសមាសភាពមកពីក្រុមប្រឹក្សាភិបាលចំនួន ៩/៥នាក់ និងបុគ្គលិក បម្រើការនៅក្នុងអង្គការកែប្រែសហគមន៍មកពីការិយាល័យក្នុងខេត្តសៀមរាបនិងខេត្តឧត្តរមានជ័យសរុបមានអ្នកចូលរួម១៨នាក់/ស្រី៨នាក់។ជាកិច្ចចាប់ផ្តើមលោកនាយកអង្គការកែប្រែសហគមន៍បានធ្វើមតិស្វាគមន៍បង្ហាញពីគោលបំណង របៀបវរៈសំខាន់ៗ សម្រាប់កិច្ចប្រជុំ បន្ទាប់មកធ្វើការណែនាំឈ្មោះអោយបុគ្គលិកបម្រើការនិងតួនាទី រៀងខ្លួនរួចហើយក៏ធ្វើការប្រគល់ទៅអោយលោកប្រធានក្រុមប្រឹក្សាភិបាលធ្វើចំណាប់អារម្មណ៍ចូលរួម និងប្រកាស បើកកម្មវិធីប្រជុំដែលមានកិច្ចពិភាក្សាទៅតាមរបៀបវរៈនីមួយៗជាលំដាប់លំដោយដូចខាងក្រោមនេះ៖

-របាយការណ៍វឌ្ឍនៈភាពប្រចាំឆមាសទី១នៃឆ្នាំ២០១៧របស់អង្គការកែប្រែសហគមន៍
-ពិភាក្សាដើម្បីកែសម្រួលគោលនយោបាយស្តីពីការគ្រប់គ្រងបុគ្គលិក និងគណៈគ្រប់គ្រងអង្គការ
-សំណើជ្រើសរើសប្រធានកម្មវិធី ដែលជានាយកស្តីទី
-ពិភាក្សាកែសម្រួលគោលនយោបាយប្រាក់បៀវត្សរ៍ (ប្រាក់បំណាច់មុខងារ និងប្រាក់បៀវត្សរ៍ទីខែទី១៣)
-បច្ចុប្បន្នភាពម្ចាស់ជំនួយ និងប្រភពថវិកា
-លើកទិសដៅផែនការសកម្មភាពដែលត្រូវអនុវត្តបន្ត
-សេចក្តីថ្លែងអំណរគុណដល់ក្រុមប្រឹក្សាភិបាល
-ផ្សេងៗ

*៣.២.ត្រួតពិនិត្យនិងឆ្លុះបញ្ចាំងការអនុវត្តសកម្មភាពប្រចាំត្រីមាស (comprehensive monitoring)*

អង្គការអាក់ស៊ិនអេត ចុះត្រួតពិនិត្យចំនួន៣ដង។ លើកទីមួយជួបជាមួយ CTO ចំនួន៥នាក់/ស្រី៣នាក់ និងចុះទៅភូមិឈើស្លាប់ ពីធនាគាស្រូវ និងក្រុមសន្សំចូលរួមចំនួន៧នាក់/ស្រី៣នាក់។ លើកទី២ អង្គការអាក់ស៊ិនអេត ចុះត្រួត

ពិនិត្យសហគមន៍ព្រៃឈើភ្នំដងរ៉ែកសម្រែកព្រៃស្រស់ និងទី៣ចុះទៅជួបសហគមន៍ព្រៃឈើរំដួលវាសនា និងចុះត្រួតពិនិត្យការសាងសង់ក្លិប នៅភូមិពោធិវង្ស និងឈើស្លាប់។

*៣.៣.រៀបចំ និងត្រួតពិនិត្យផែនការឆ្នាំ ២០១៧*

ថ្ងៃទី១៦ខែកញ្ញាឆ្នាំ២០១៧ ការប្រជុំនេះមានអ្នកចូលរួមចំនួន៣១នាក់ស្រី៤នាក់។ លទ្ធផលនៃអង្គប្រជុំ ៖

**I. សកម្មភាពធនធានធម្មជាតិ**

- សហការជាមួយអាជ្ញធរ និងរដ្ឋបាលព្រៃឈើដើម្បីទប់ស្កាត់បទល្មើសក្នុងព្រៃឈើសហគមន៍។
- ប្រជុំបណ្តាញសហគមន៍ ថ្នាក់ខេត្ត មន្ទីរកសិកម្ម រដ្ឋបាលព្រៃឈើ និងអាជ្ញាធរមូលដ្ឋាន។
- គាំទ្រសកម្មភាពបណ្តាញក្នុងការដោះស្រាយបទល្មើសព្រៃឈើសរសេររបាយការណ៍ជួយសម្របសម្រួលសហគមន៍ផ្សេងៗទៀតទាំង១៣។
- ជួបជាមួយ ឃុំ ស្រុក ខេត្ត មន្ទីរកសិកម្ម ក្រសួងកសិកម្ម ក្នុងការដោះស្រាយបញ្ហាទាក់ទង សហគមន៍ ព្រៃឈើទាំង១៣។
- ចូលរួមវាទិកាសាធារណៈថ្នាក់ ឃុំ ស្រុក ខេត្ត។
- ស្រង់ស្ថិតិរណាយន្តតាមភូមិ និងសំណើរប្រើប្រាស់រណាយន្តទាក់ទងនឹងភូមិសហគមន៍ព្រៃឈើ។
- ជីកប្រឡាយបង្គោលព្រំប្រទល់ព្រៃសហគមន៍នៅសហគមន៍ព្រៃឈើទាំងបី។
- ដាក់ផ្ទាំងផែនទីតាមសាលាឃុំ និងទីតាំងសហគមន៍ព្រៃឈើ។
- គៀងគោសមាជិកសហគមន៍ក្នុងការដាំដំណាំយុទ្ធសាស្រ្តគ្រាប់ត្នោតឬស្សីការពារព្រំប្រទល់ព្រៃសហគមន៍
- បុណ្យខួបសហគមន៍ព្រៃឈើប្រចាំឆ្នាំ
- ធ្វើកិច្ចសន្យាអ្នកដែលមានដីអាស្រ័យផលក្នុងព្រៃសហគមន៍។
- ប្រជុំសហគមន៍ រវាងអាជ្ញាធរភូមិ ឃុំ ប្រចាំខែ
- បណ្តុះបណ្តាល និងផ្សព្វផ្សាយ វិទ្យុ ទូរទស្សន៍ សន្និសីទកាសែតពីច្បាប់ស្តីពីព្រៃឈើ និងអនុក្រិតស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ។
- ចូលរួមធ្វើផែនការវិនិយោគប្រចាំឆ្នាំ
- ទស្សនៈកិច្ចព្រៃដៃគូនៅពោធិសាត់

**II. ផ្នែកអប់រំ**

- ការសាងសង់កន្លែងលាងដៃសិស្ស
- សាងសង់ប្រព័ន្ធទឹកស្អាត
- សាងសង់ឡដុតសំរាម
- សាងសង់រោងអាហារសិស្ស
- ធ្វើការផ្សព្វផ្សាយទូរលំទូរលាយអំពីថវិPB
- មាតាបិតាសិស្សគ្រូជួបគ្នា១ឆ្នាំ២ទៅ៣ដង
- សាងសង់របងសាលារៀន
- ទិញសំភារៈកីឡាសិស្ស
- រៀបចំសួរកុមារ
- រៀបចំកន្លែងបណ្ណាល័យដាក់សៀវភៅ

**III. ផ្នែកជីវិភាព**

- ប្រជុំធ្វើកិច្ចសន្យាជាមួយសមាជិកចាស់ដែលនៅជំពាក់ស្រូវនិងថវិកា
- ធ្វើការសាងសង់ជង្រុកថ្មីនិងរកកន្លែងទុកដាក់ជង្រុកអោយមានសុវត្ថិភាពនិងជួសជុលបន្ថែម

- ប្រជុំធ្វើការផ្សព្វផ្សាយក្នុងការប្រើប្រាស់ពូជដំណាំតាមតំរូវការទីផ្សារ
- ផ្តល់វគ្គបណ្តុះបណ្តាលដល់គណៈកម្មការនិងសមាជិកស្តីពីការគ្រប់គ្រងបញ្ជីស្នាមនិងសមាជិក
- អោយមាននិន្តរភាព រៀបចំរចនាសម្ព័ន្ធថ្មីនិងជ្រើសរើសគណៈកម្មការបន្ថែម
- បណ្តុះបណ្តាលពីការជ្រើសរើសពូជនិងការទុកដាក់ពូជ( ស្រូវ និងដំណាំ)

*៣.៤.ចូលរួមសិក្ខាសាលាភាពជាដៃគូរប្រចាំឆ្នាំ*

នៅខែមករាប្រជុំភាពជាដៃគូជាមួយអង្គការAAC៤៩នាក់/ស្រី២៦នាក់ ដែលអញ្ជើញមកពីអង្គការដៃគូAAC ទាំង៥ខេត្ត

- ចូលរួមដើម្បីឆ្លុះបញ្ចាំងពីលទ្ធផលឆ្នាំ២០១៦និងភាពជាដៃគូ។
- ចែករំលែកប្រភពថវិកាដែលទទួលបានពីការគូសារតាមដៃគូនីមួយៗ។
- ការសម្រេចសមិទ្ធិផលរបស់អង្គការដៃគូ។
- ការពិភាក្សាជាក្រុមក្នុងការរកយុទ្ធសាស្ត្របន្ត។

នៅខែមីនាបុគ្គលិកគាំពារកុមារ និងមន្ត្រីគម្រោងម្នាក់បានទៅចូលរួមប្រជុំជាមួយAACទាក់ទងនឹងអប់រំ ដែលមានអ្នកចូលរួមសរុប១៦/ស្រី៦នាក់និងពួកគាត់បានទទួលចំណេះដឹងពីអង្គការដៃគូនឹងរៀនសូត្របានបទពិសោធន៍ល្អៗពីគ្នាទៅវិញទៅមកនិងកាន់តែមានភាពជឿជាក់ក្នុងការអនុវត្តន៍ឧបករណ៍PRSនិងSIPអោយកាន់តែមានប្រសិទ្ធិភាពខ្ពស់។ មន្ត្រីអប់រំរបស់អង្គការដៃគូនឹងទទួលបានចំនេះដឹងបន្ថែមទាក់ទងនឹងគោលនយោបាយអប់រំនិងការវិវឌ្ឍន៍ថ្មីៗនៅថ្នាក់ជាតិនិងអាចមានលទ្ធភាពចែកចាយបន្តដល់អ្នកពាក់ព័ន្ធផ្សេងៗក្របខ័ណ្ឌនិងគោលដៅយុទ្ធសាស្ត្រនៃកម្មវិធីអប់រំសំរាប់ឆ្នាំ២០១៧របស់អង្គការអាក់សិនអេតនឹងត្រូវបានគាំទ្រនិងអនុវត្តន៍អោយស្របជាមួយគោលដៅយុទ្ធសាស្ត្ររបស់អង្គការដៃគូផងដែរ។

*៣.៥.ការប្រជុំជាមួយបណ្តាញផ្សេងៗ AAC, NEP, WGPD, CHF, NGO forum*

អង្គការកែប្រែសហគមន៍បានចូលជាបណ្តាញជាមួយNEPដើម្បីទទួលបានបទពិសោធន៍ពីគោលការណ៍អប់រំនានាពីអង្គការដៃគូ និងNEP។ មន្ត្រីគម្រោងរបស់អង្គការកែប្រែសហគមន៍បានចូរួមសន្និសិទ្ធការសែតនៅភ្នំពេញជាមួយAAC ពីបញ្ហាបាត់បង់ ដីធ្លីនៅភូមិអូរបាត់មាន់។ ដែលមានការចូលរួមចំនួន៣៨នាក់/១១នាក់ជាស្ត្រីដែលសហគមន៍ទាំងនោះមិនទាន់បានសំណងពីរដ្ឋាភិបាល។ អង្គការកែប្រែសហគមន៍បានចូលរួមបណ្តាញNGOនៅក្នុងខេត្តដែលមានសមាជិកសរុប២៣អង្គការ ទាំងជាតិ និងអន្តរជាតិ ដែលមានការប្រជុំ៦ខែម្តង និងប្រចាំឆ្នាំ និងប្រជុំវិសាមញ្ញដែលចាំបាច់។ អ្នកសម្របសម្រួលកម្មវិធីរបស់អង្គការកែប្រែសហគមន៍បានចូលរួមប្រជុំជាមួយណ្តាញពហុវិស័យទាក់ទងនឹងច្បាប់ដីកសិកម្មនៅការិយាល័យAAC។ អ្នកសម្របសម្រួលកម្មវិធីរបស់អង្គការកែប្រែសហគមន៍បានចូលរួមប្រជុំជាមួយAACអំពីគម្រោង (Empowering CSOs and Marginalized Communities in Cambodia to Claim Land Tenure Security)មានអ្នកចូលរួម១០នាក់/៣នាក់។ ក្នុងនោះបានពិភាក្សាពីលទ្ធផល បញ្ហានានា និងដំណោះស្រាយ លើកឡើងផែនការបន្តសម្រាប់ត្រីមាសបន្ទាប់។

<u>អនុគម្រោងទី១</u>

| ល.រ | សង្ខេបលទ្ធផល |
|---|---|
| ១ | ក្រោយមានការពិគ្រោះយោបល់ជាមួយសហគមន៍ពីផែនការសាងសង់ក្លឹបកុមាររីករាយ ហើយមានការផ្តល់ដីដោយសហគមន៍ គម្រោងបានសម្រេចសាងសង់អាគារក្លឹបកុមាររីករាយ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការគៀងគរកុមារដែលទំនេរពីម៉ោងសិក្សាអាចមានទីកន្លែងប្រមូលប្រផ្តុំមួយកន្លែងក្នុងការលែងកំសាន្តស្វ័យសិក្សារ ជៀសវាងការដើរឆ្វាយក្អែកចាស់ទុំអាចប្រឈមនឹងសុវត្ថិភាព និងសន្តិសុខ។ អាគារក្លឹបកុមារសង់ជាន់ផ្ទាល់ដីទំហំ ៥ម៉ែត្រ គុណ ៩ម៉ែត្រ ជញ្ជាំងពាក់កណ្តាលឥដ្ឋ និងស័ង្កសី កំរាលចាក់សាប ដំបូលប្រក់ស័ង្កសី សង់នៅលើដីសហគមន៍ដែលបរិច្ចាកទំហំ ១៥ម៉ែត្រ គុណ ៣៥ ម៉ែត្រ។ គម្រោងបានផ្តល់សម្ភារៈក្មេងមានទាំងកីឡា គ្រឿងលែងបង្កើនបញ្ញា ហ្វីត ប៊ិច ក្តាឈ្នួន តុកតា ផ្ទាំងគំនូរអប់រំ កំរ៉ងពាក្យស្លោក ។ល។ |

| | |
|---|---|
| | គម្រោងក៏បានបានសង់បង្គន់អនាម័យភ្លោះស្រីប្រុសក្បែរក្លឹបនឹងរៀបចំភ្ជាប់ប្រភពទឹកសម្រាប់ការលើកកំពស់ អានាម័យកុមារ។ ហើយក៏បានបំពាក់សួនកុមារមួយកន្លែងមួយឈុត មានដូចជាទោងយោល ទោងវិល ទោងបាស់បើក និងធ្មេីរអិល។ ហើយគម្រោងបានចងក្រងក្លឹបកុមារដោយបានចុះបង្វឹក និងចាត់ចែងការគ្រប់គ្រងប្រើប្រាស់អាគារក្លឹបកុមារអោយស្របតាមគោលបំណងនៃការប្រើបាស់។ អាគារក្លឹបនេះសង់នៅក្នុងភូមិពោធិវង្ស សង្កាត់បន្សាយរាក់ក្រុងសំរោង និងភូមិឈើស្លាប់ ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល។ វានឹងក្លាយទៅជាគម្រូអាគារមួយដែលសហគមន៍ផ្សេងនឹងយកគម្រូតាមដើម្បីគោលដៅ ជម្រុញការអប់រំកុមារ។ តាមរយៈក្លឹប២នេះមានអ្នកទទួលផលសរុប ១០៦នាក់ ស្រី៦០នាក់។ |
| ២ | រៀបចំប្រជុំចែករម្លែកចំណេះដឹងជុំវិញខ្លឹមសារសិទ្ធិទាំង១០ក្នុងសាលារបស់កុមារដែលដកស្រង់ចេញពីអនុសញ្ញាឬកិច្ចព្រមព្រៀងនានាស្តីពីសិទ្ធិរបស់កុមារទៅដល់អាជ្ញាធរមូលដ្ឋាន គណៈគ្រប់គ្រង សាលា មន្ត្រីជំនាញ គណៈកម្មការទ្រទ្រង់សាលា ក្នុងសាលាគោលដៅគម្រោង ដើម្បីបង្កើនចំណេះដឹងជម្រុញការកែលំអរ ពង្រឹងគុណភាពអប់រំអោយកាន់តែប្រសើរជាងមុន។ អ្នកចូលរួមបានដឹងបន្ថែមពីអ្វីដែលធ្លាប់ដឹងពីសិទ្ធិកុមារ និងមានមូលដ្ឋានក្នុងការយកទៅកែលំអរ ចំនុចខ្វះខាតដែលមានជុំវិញការអនុវត្តកន្លងមកដែលមានអ្នកចូលរួមសរុប ២៣នាក់ស្រី៨នាក់។<br>បន្ថែមទៅលើការចែករម្លែកដល់អាជ្ញាធរមូលដ្ឋាន យើងក៏បានបន្តធ្វើទៅកាន់ប្រជាសហគមន៍នៅ ១០ភូមិគោលដៅគម្រោងនៃឃុំគោកខ្ពស់ និងសង្កាត់សំរោង ដែលមានអ្នកចូលរួមសរុប៥៦៨នាក់ ស្រី៣៩៩នាក់។ នឹងធ្វើការផ្សព្វផ្សាយទៅដល់សាលាបឋមសិក្សាគោលដៅចំនួន៥ ដើម្បីអោយសិស្សានុសិស្សបានយល់ដឹងបន្ថែមជុំវិញប្រធានបទនេះ ដែលមានអ្នកចូលរួមសរុប ១៦៨នាក់ ស្រី១០៨នាក់។<br>ខ្លឹមសារសិទ្ធិទាំង១០នោះមាន៖<br>១-សិទ្ធិទទួលបានការអប់រំដោយឥតបង់ថ្លៃនិងកំណត់ដោយច្បាប់<br>២-សិទ្ធិរួចផុតពីការរើសអើង<br>៣-សិទ្ធិទទួលបានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន<br>៤-សិទ្ធិទទួលបានការសិក្សាជាមួយគ្រូបង្រៀនដែលមានការបណ្តុះបណ្តាលប្រកបដោយគុណភាព<br>៥-សិទ្ធិទទួលបានបរិយាកាសនៃការសិក្សាដោយមានសុវត្ថិភាពនិងគ្មានហឹង្សា<br>៦-សិទ្ធិទទួលបានការអប់រំដែលមានខ្លឹមសារពាក់ព័ន្ធ<br>៧-សិទ្ធិយល់ដឹងពីសិទ្ធិរបស់ខ្លួន<br>៨-សិទ្ធិចូលរួម<br>៩-សិទ្ធិទទួលបានពត៌មានដែលមានតម្លាភាពនិងគណនេយ្យភាពរបស់សាលារៀន<br>១០-សិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព<br>ក្រោយពីធ្វើការផ្សព្វផ្សាយចែករម្លែកដោយផ្ទាល់យើងក៏បានបោះពុម្ពជាផ្ទាំងផ្សព្វផ្សាយ៦៨ផ្ទាំងស្តីពីគោលការណ៍សិទ្ធិទាំង១០នេះបែងចែកទៅសាលាទាំង១០នៃគោលដៅគម្រោងទុកបន្តប្រើប្រាស់ផ្សព្វផ្សាយខ្លឹមសារទៅដល់អ្នកផ្សេងទៀតជាពិសេសសិស្សដែលមិនទានបាទទួលការផ្សព្វ ផ្សាយនេះ។ |
| ៣ | ក្រុមយុវជនដើម្បីកិច្ចការសង្គម១ត្រូវបានចងក្រង ដែលមានសមាជិកសរុប៥០នាក់។ ក្រៅពីការចែករម្លែកនៅគោលការណ៍សិទ្ធិទាំង១០ក្នុងសាលាទៅដល់ពួកគាត់ដើម្បីជាមូលដ្ឋានអោយពួកគាត់បន្តចែករម្លែកទៅកាន់យុវជនផ្សេងទៀត យើងបានផ្តល់ការបណ្តុះបណ្តាលជំនាញកុំព្យូទ័រ ដែលជ្រើសរើសអ្នកបង្វឹកចេញក្រុមគាត់ ហើយនឹងសម្របសម្រួលអោយគាតដាក់ប្រធានបទពិភាក្សាក្រុម និងកិច្ចការលើកគម្រោងដើម្បីចូលរួមការការលើកកំពស់ការយល់ដឹងពីការសិក្សា ការស្រលាញ់ព្រៃឈើ និងការចូលរួមថែរក្សាអនាម័យសន្តាប់ធ្នាប់ បរិស្ថានក្នុងសហគមន៍ តាមរយះការប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គម ជាពិសេសហ្វេសបុក។ |

| | |
|---|---|
| ៤ | យើងបានរៀបចំក្រុមការងារសិក្សាស្រាវជ្រាវ២ក្រុមសម្រាប់នៅក្រុងសំរោង និងស្រុកបន្ទាយអំពិល។ ដោយបានធ្វើការបណ្តុះបណ្តាលជុំវិញបច្ចេកទេស និងវិធីសាស្ត្រក្នុងការចុះប្រមូលទិន្នន័យស្រាវជ្រាវ PRS និងបង្កើតគម្រោងសំនួរ។ សមាសភាពក្រុមការងារមកពីក្រុមប្រឹក្សាឃុំ ការិយាល័យអប់រំស្រុក គណកម្មការទ្រទ្រង់សាលា តំណាងសិស្ស និងអាណាព្យាបាលសិស្ស។ ក្រុមការងារចុះសិក្សាស្រាវជ្រាវ PRS សម្រាប់ចុះទៅលើសាលាគោលដៅ៥ គឺសាលាឈើស្លាប់ ពោធិវង្ស ត្នោត គោកខ្ពស់ អូរទង។ ក្រោយពេលចុះស្រាវជ្រាវរួចហើយក្រុមការងារបានធ្វើការបង្ហាញលទ្ធផលស្រាវជ្រាវ ដើម្បីលើកបញ្ហាអទិភាពដើម្បីយកទៅដាក់ចូលក្នុងផែនការអភិវឌ្ឍសាលាទាំង៥។គម្រោងក៏បានវិភាជថវិកាខ្លះ ដើម្បីចូលរួមក្នុងផែនការអភិវឌ្ឍសាលាផ្អែកតាមការរកឃើញពីការស្រាវជ្រាវ។សកម្មភាពនេះមានអ្នកចូលរួមសរុប១៤២នាក់ ស្ត្រី៧៨នាក់។ ហើយអ្នកចូលរួមទាំងអស់គាំទ្រចំពោះការប្រើប្រាស់ឧបករណ៍PRSនេះ ព្រោះដំណើរការមានការចូលរួមតាមបែបប្រជាធិបតេយ្យ និងឆ្លុះបញ្ចាំងពីការចូលរួមពេញលេញ។ លទ្ធផលនៃរបាយការណ៍ស្រាវជ្រាវនេះក៏បានដាក់ឆ្លងមន្ទីរ និងការិយាល័យអប់រំ និងធ្វើការឆ្លុះបញ្ចាំងពីអ្វីដែលរកឃើញក្នុងចំនោមអ្នកពាក់ព័ន្ធផងដែរ។ ផ្អែកលើរបាយការណ៍សិក្សាស្រាវជ្រាវនេះ យើងបានជួយសម្របសម្រួលរៀបចំផែនការកែលំអរសាលា រួចហើយចុះត្រួតពិនិត្យតាមដានទៅលើដំនើរការនៃការលើកស្នើរកែលំអរសាលានេះរហូតចុងនៃគម្រោង។ |
| ៥ | រៀបចំវេទិកាសាធារណៈនៅសាលាកម្រងអូរទង នៃឃុំគោកខ្ពស់ ដែលមានអ្នកចូលរួមសរុប ៩០នាក់ ស្រី៤០នាក់។ វេទិកានេះរៀបចំឡើងក្នុងគោលបំណងជម្រុញការចូលរួមរវាងសហគមន៍ អាជ្ញាធរដែនដី លោកគ្រូការិយាល័យអប់រំ និងអ្នកពាក់ព័ន្ធ ដែលជាគំនិតផ្តួចផ្តើមមួយអង្គការកែប្រែសហគមន៍ចង់បង្ហាញដល់អ្នកពាក់ព័ន្ធប្រើក្នុងការពង្រឹងការអប់រំកុមារតាមរយៈការចូលរួមសហការគ្នារវាងគ្រូនិងអាណាព្យាបាលសិស្ស។ ដោយយើងតែងតែលេចលឺពាក្យនិយាយបាចសាចឆ្លើយបន្ទោសដាក់គ្នាជុំវិញបញ្ហាការសិក្សារបស់សិស្ស។ ហើយកត្តានេះបណ្តាលមកពីគម្លាតនៃការចូលរួមរវាងអាណាព្យាបាលសិស្សនិងគ្រូ មិនស៊ីសង្វាក់គ្នា ព្រោះមិនបានជួបគ្នាដើម្បីយកបញ្ហាមកជជែកនៅលើតុ ហើយជម្រុញអោយអ្នកនៅមូលដ្ឋានរួមគ្នាដោះស្រាយបញ្ហាណាដែលអាចដោះស្រាយបាន ជាជាងរង់ចាំតែថ្នាក់ជាត់មកដោះស្រាយ។ ក្រោយពេលវេទិកានៃកម្មវិធីនេះបានបញ្ចប់អ្នកចូលរួមមានការសាទរ ដោយចង់អោយមានអង្គវេទិកានេះជាទៀងទាត់ យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំដើម្បីអោយមាតាបិតាសិស្ស លោកគ្រូអ្នកគ្រូ អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធបានយកបញ្ហាមកជជែករកដំណោះស្រាយទាន់ពេលឆ្លើយតបទៅនឹងបញ្ហាអប់រំរបស់កុមារ។ |
| ៦ | ការកសាងសមត្ថភាពទៅដល់ប្រធានក្លឹបកុមារ ហើយនឹងសមាជិកក្លឹបអំពីគោលការណ៍លើកកំពស់សិទ្ធិក្នុងសាលារៀន អនាម័យខ្លួនប្រាណ ទឹកស្អាត និងបញ្ជ្រាបការកាត់បន្ថយគ្រោះភ័យមហន្តរាយធម្មជាតិ។ កម្មវិធីបានរៀបចំដោយមានតំណាងប្រធានក្លឹបទាំង១០ មានសរុប ២០នាក់ ស្រី៧នាក់ ក្រៅពីប្រធានបទខាងលើក៏បានបង្វឹកដល់ប្រធានក្លឹបអោយចេះធ្វើការកាត់ត្រាសកម្មភាពក្រុម ការអភិវឌ្ឍសមត្ថភាពក្រុម និងសមាជិកអោយកាន់តែសកម្មថែមទៀត ជាពិសេសបន្តចែករម្លែកពីសិទ្ធិទាំង១០ដល់សមាជិកក្លឹប។ |
| ៧ | ធ្វើការប្រជុំឆ្លុះបញ្ចាំងទៅដល់គណៈកម្មការទ្រទ្រង់សាលាមកពី៧សាលាគោលដៅ ដែលមានអ្នកចូលរួមសរុប ២៥នាក់ ស្រី៨នាក់។ កិច្ចប្រជុំផ្តោតទៅលើការពង្រឹងសមត្ថភាពតួនាទី និងការទទួលខុសត្រូវរបស់គណកម្មការដូចដែលមានចែងក្នុងលក្ខខន្តិកៈ សំដៅជម្រុញការងារអភិបាលកិច្ចតាមសាលា ជម្រុញអោយការរៀនរបស់កុមារ និងការបង្រៀនរបស់លោកគ្រូ បានបំពេញតាមកាតព្វកិច្ចដែលក្រសួងបានកំណត់ ត្រួតពិនិត្យទៅលើ Checklist តាមសាលា ការរៀបចំពាក្យបណ្តឹង កំណត់ហេតុ និងការគ្រប់គ្រងអោយកាន់តែប្រសើរឡើង។ ក្រោយមានកិច្ចប្រជុំពង្រឹងតួនាទីនេះហើយ គណកម្មការទ្រទ្រង់សាលាបានខិតខំបំពេញកិច្ចការសំដៅអនុវត្តតួនាទីអោយកាន់តែសកម្ម ជាពិសេសការត្រួតពិនិត្យ ដើម្បីពង្រឹងការគ្រប់គ្រងតាមសាលាអោយមានប្រសិទ្ធិភាព។ ក្រុមការងារក៏បានធ្វើការចូលរួមត្រួតពិនិត្យជាមួយគណកម្មការទ្រទ្រង់សាលា |

| | |
|---|---|
| | ដើម្បីអោយប្រាកដថាពួកគាត់បានយល់ពីការអនុត្តតួនាទីបានត្រឹមត្រូវឬអត់។ |
| ៨ | ដឹកនាំកម្មវិធីទស្សនកិច្ចកុមារពីសាលាជនបទមកកាន់សាលាគម្រូក្នុងខេត្ត។ មានតំណាងសិស្សសាលា៤៤នាក់ ស្រី១៧នាក់ ដោយមានទាំងតំណាគ្រូម្នាក់មកពីតាមសាលាបឋមសិក្សាទាំង១០ មកធ្វើការទស្សនកិច្ចនៅបឋមសិក្សាសំរោង។ ក្រោយពីកម្មវិធីទស្សនកិច្ចនេះ ពួកគាត់សំដែងការត្រេកអរ និងសប្បាយរីករាយដោយការទទួលបាននូវការចែករម្លែកចំណេះដឹងល្អៗ ជុំវិញការរៀបចំចាត់ចែង សណ្តាប់ធ្នាប់ សោភ័ណ្ឌភាព អនាម័យ និងបរិស្ថានសាលា ដោយការរៀបចំសួនសាលា ចំណតកង់ អ្នកលក់ដូរ ការរៀបចំរបៀបរយតាមថ្នាក់រៀន វិធីសាស្ត្របង្រៀន វិន័យ និងគោលការណ៍គ្រប់គ្រងការរៀន និងការបង្រៀនជាដើម។ សិក្ខាកាមដែលចូលរួមបានប្តេជ្ញាចិត្តចូលរួមនឹងយកចំណេះដឹងទាំងនេះទៅពង្រឹងការអនុវត្តតាមសាលារៀងខ្លួន |
| ៩ | ធ្វើការជួសជុលកែលំអរបណ្ណាល័យចំនួនបីកន្លែងព្រមទាំងទទួលសៀវភៅថ្មីតាមសាលាបន្ថែម៨៣ក្បាលក្នុងមួយសាលា។ ក្រោយមានការកែលំអរយើងឃើញថាក្មេងមានការចូលអានកើនឡើង ហើយទិន្នន័យក្មេងសរុបដែលចូលអានប្រមូលបានក្រោយពេលគម្រោងមានចំនួនសរុប ២៥៣នាក់ ស្រី១២៨នាក់។ |
| ១០ | មុនពេលបើកបវេសនកាលថ្មី យើងបានសហការណ៍តាមសាលាគោលដៅដែលនៅដាច់ស្រយាលចំនួន៧ មានដូចជាសាលាពោធិវង្ស ត្នោត ឈើស្លាប់ សំបួរមាស អូទង គោកគរ និងគោកខ្ពស់ថ្មី ដែលមានអ្នកចូលរួមសរុប ៨២៨នាក់ ស្រី៤១៨នាក់។ ការរៀបចំយុទ្ធនាការផ្សព្វផ្សាយចុះឈ្មោះចូលរៀននេះសំដៅ ដើម្បីធ្វើលើកកំពស់ការយល់ដឹងពីសារះសំខាន់នៃការបញ្ជូនកូនទៅសាលា ការដាស់តឿនក្រើនរំលឹកដើម្បីពញ្ញាក់ស្មារតីដល់មាតាបិតាសិស្សអោយស្រូតរូសរាន់បញ្ជូនកូនទៅចុះឈ្មោះចូលរៀនគ្រប់គ្នាៗ ជាពិសេសកុមារដែលគ្រប់អាយុត្រូវចូលរៀនកុំអោយខកខាន។ ក្រោយមានការរៀបចំយុទ្ធនាការណ៍ដោយមានការចាក់ជាភ្លេងបញ្ជូនសារទាក់ទងនឹងការបញ្ជូនកុមារទៅសាលា ការលែងភ្លេងឆៃយ៉ាំ ការហែរជាក្បួនតាមភូមិ ការដាក់បដាពាក្យអប់រំផ្សព្វផ្សាយ និងសំលែងអំពាវនាវតាមឧឃោសនស័ព្ទ អោយបានលឺដល់ប្រជាជនក្នុងភូមិអោយមានការត្រៀមខ្លួនបំពេញកាតព្វកិច្ចជាអាណាព្យាបាលល្អ ខិតខំបញ្ជូនអោយបានចូលរៀនជៀសផុតពីភាពល្ងង់ខ្លៅអវិជ្ជា។ តាមរបាយការណ៍ចំនួនសិស្សកើនឡើង ១០៧នាក់ ស្រី៤២នាក់បើធៀបនឹងឆ្នាំមុន។ |

<u>អនុគម្រោងទី២</u>

| ល.រ | សង្ខេបលទ្ធផល |
|---|---|
| ១ | ចុះសិក្សាស្រាវជ្រាវគ្រួសាររងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍសំណង់ទំនប់ស្ទឹងស្រែងនៅភូមិគោកសំព័រ<br>គ្រួសាររងគ្រោះ ១២៣គ្រួសារ ដីស្រែ១៧៦ហាត ចំការ ៣៤៨ហាត ដីលំនៅដ្ឋាន ១០ហាត ផ្ទះ៣០ខ្នង |
| ២ | ចុះសិក្សាស្រាវជ្រាវគ្រួសាររងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍសំណង់ទំនប់ស្ទឹងស្រែងនៅភូមិចារថ្មី<br>ចារ្យថ្មីគ្រួសាររងគ្រោះ ១៧គ្រួសារ ដីស្រែ៩៤.៦៣ហាត ចំការ ៤៧ហាត ដីលំនៅដ្ឋាន គ្មាន ផ្ទះ គ្មាន<br>ចារ្យចាស់គ្រួសាររងគ្រោះ ២៦គ្រួសារ ដីស្រែ១២៤ហាត ចំការ ៩.៧២ហាត ដីលំនៅដ្ឋាន គ្មាន ផ្ទះ គ្មាន |
| ៣ | ចុះសិក្សាស្រាវជ្រាវគ្រួសាររងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍសំណង់ទំនប់ស្ទឹងស្រែងនៅភូមិទំនប់ថ្មី<br>គ្រួសាររងគ្រោះ ២៩គ្រួសារ ដីស្រែ២៧៣ហាត ចំការ ៦០ហាត ដីលំនៅដ្ឋាន ៥ហាត ផ្ទះ គ្មាន |
| ៤ | ចុះសិក្សាស្រាវជ្រាវគ្រួសាររងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍសំណង់ទំនប់ស្ទឹងស្រែងនៅភូមិបាក់នឹម<br>គ្រួសាររងគ្រោះ ២៥គ្រួសារ ដីស្រែ១២៥ហាត ចំការ ២២ហាត ដីលំនៅដ្ឋាន ៤ហាត ផ្ទះ គ្មាន |
| ៥ | ចុះសិក្សាស្រាវជ្រាវគ្រួសាររងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍសំណង់ទំនប់ស្ទឹងស្រែងនៅភូមិស្រះកែវ<br>គ្រួសាររងគ្រោះ ១៥៨គ្រួសារ ដីស្រែ១៨៦៨ហាត ចំការ ៧១៧ហាត ដីលំនៅដ្ឋាន ៣៤ហាត ផ្ទះ ១៥៨ខ្នង |

## III. របាយការណ៍ហិរញ្ញវត្ថុ

ខេត្តសៀមរាប

| ចំណូលសរុប២០១៧ | ចំណាយសរុប២០១៧ | សមតុល្យ |
|---|---|---|
| 70,505.00$ | 62,538.74$ | 1,154.60$ |

ខេត្តឧត្តរមានជ័យ

| ចំណូលសរុប២០១៧ | ចំណាយសរុប២០១៧ | សមតុល្យ |
|---|---|---|
| 90,787.28 USD | 83,363.53 USD | 7,423.74 USD |

## IV. ផែនការទិសដៅការងារបន្ត

**ខេត្តសៀមរាប**

**គម្រោងទី១៖**

1-ស្រីមកពីអង្គការសហគមន៍អាចទទួលបានការសិក្សាពីកសិដ្ឋានបង្ហាញដំណាំចម្រុះដែលជោគជ័យ
2-រៀបចំកសិដ្ឋានបង្ហាញគម្រូ ២២កន្លែងដែលស្របទៅនឹងខ្សែរសង្វាក់ផលិតកម្មដល់សមាជិកសហគមន៍កសិកម្ម
3-កសាងសមត្ថភាពកសិករជាសមាជិកសហគមន៍កសិកម្មពីកសិកម្មបន្សាំនឹងការប្រែប្រួលអាកាសធាតុ
4-ផ្សព្វផ្សាយពត៌មាន និងឯកសារគតិយុត្តិជុំវិញសិទ្ធិដីធ្លីដល់សមាជិកសហគមន៍កសិកម្ម
5-លើកកំពស់ការទទួលបាននូវសុវត្ថិភាពដីធ្លីរបស់សមាជិកសហគមន៍កសិកម្ម
6-ស្ត្រីអាចធ្វើការចូលរួមសម្រេចចិត្តសកម្មក្នុងការទាមទាសិទ្ធីដីធ្លីដោយការលើកកំពស់សមភាពយែនឌ័រ
7-កសិករជាស្ត្រីអាចទទួលបាននូវការផ្សព្វផ្សាយសេវាកម្មកសិកម្ម និងធនធាន
8-ផលិតផលសហគមន៍ដែលមានសក្តានុពលនឹងទទួលបានការចុះបញ្ជីរអត្តសញ្ញាណ
9-ស្ត្រីអាចទទួលបាននូវការកសាងសមត្ថភាពទៅលើមូលដ្ឋានចំណេះដឹងស្ដីពីហិរញ្ញវត្ថុ
10-ណែនាំនូវបច្ចេកទេសបែបច្នៃប្រឌិតដែលផ្តល់ភាពងាយស្រួលដល់ស្ត្រី
12-ស្ត្រីជាសមាជិកសហគមន៍កសិកម្មអាចចូលរួមសម្រេចចិត្តយ៉ាងសកម្មជាមួយប្តី
13-សហគមន៍លើកគំនិតផ្តួចផ្តើមរៀបចំគោលនយោបាយដើម្បីផ្តល់ប្រយោជន៍ដល់ស្ត្រី
14-សហគមន៍អាចទទួលបានកំចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើម្បីយកទៅពង្រីកមុខជំនួញ
15-បុគ្គលិកគម្រោងនឹងទទួលបានការបណ្តុះបណ្តាលពីឧបករណ៍ GALS ហើយនឹងគាំទ្រសហគមន៍ដើម្បីកសាងឧបករណ៍ GALS ហើយនឹងអនុវត្តទៅដល់សមាជិកនិងសហគមន៍
16-បង្កើនការចូលរួមរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំតាមអង្គការសហគមន៍
17-អំពើហឹង្សាស្ត្រីត្រូវបានកាត់បន្ថយ

**គម្រោងទី២៖**

1. ផ្តល់ធនធាន យោបល់បច្ចេកទេស និង ការលើកទឹកចិត្តដល់កសិករចំនួន ១០០ គ្រួសារមាន (ស្ត្រី៥០នាក់) មកពីភូមិចំនួនយ៉ាងហោចណាស់៦ភូមិ ក្នុងចំណោម៨ភូមិឱ្យចាប់ផ្តើមអនុវត្តន៍ក្សេត្របរិស្ថានបែបច្នៃប្រឌិតឆ្លាតវៃតាមលក្ខ័ណ្ឌអាកាសធាតុ (CSA) និង កសិកម្មបែបអភិរក្ស (CA) និង
ក្លាយជាកសិដ្ឋានគំរូសំរាប់ឱ្យប្រជាជនក្នុងសហគមន៍អនុវត្តតាម។
2. តាមដានផ្តល់បច្ចេកទេសពេលអនុវត្ត និង ការលើកទឹកចិត្តដល់កសិករដែលអនុវត្តន៍ក្សេត្រ បរិស្ថានបែបច្នៃប្រឌិតឆ្លាតវៃតាម លក្ខខណ្ឌអាកាសធាតុ (CSA) និង កសិកម្មបែបអភិរក្ស (CA) និងផ្តល់យោបល់អំពីការប្រើប្រាស់ថ្នាំកសិកម្មប្រកបដោយសុវត្ថិភាព។

3. សំរបសំរួលការប្រជុំរវាងកសិករ និង អាជីវករអំពីទីផ្សារ តំរូវការផលិតផលកសិកម្មរបស់អាជីវករ ផ្នែកម្ហូបអាហារក្នុងតំបន់ទឹកធ្លាក់ និង សំរបសំរួលអោយមានការឯកភាពក្នុងការទិញផលិតផលពីកសិករ គោលដៅ។
4. ចុះត្រួតពិនិត្យតាមដាន និង វាយតំលៃអំពីប្រសិទ្ធភាព ការអនុវត្ត និងលទ្ធផល និងចងក្រងករណីសិក្សា និង Lesson Learn ។
5. រៀបចំ និង សំរបសំរួលអោយប្រជាសហគមន៍ចំនួន៥០ នាក់/គ្រួសារ (ស្ត្រី២៥) អោយមកទស្សនកិច្ចសិក្សា និង ការតំរង់ទិសពីកសិករ ដែលអំពីអនុវត្តន៍ក្បេត្របរិស្ថានបែបច្នៃប្រឌិតឆ្លាតវៃតាមលក្ខខណ្ឌ អាកាសធាតុ (CSA) និង កសិកម្មបែបអភិរក្ស (CA) ពីកសិករដែលអនុវត្តន៍បានជោគជ័យចំនួន ៣ លើក។
6. សំរបសំរួល និង រៀបចំកិច្ចពិភាក្សាអំពីបទពិសោធន៍ ភាពងាយស្រួលចំណេញ និង ចែករំលែកចំណេះដឹងអំពី (CSA) និង (CA) រវាងកសិករដែលបានអនុវត្ត និង កសិករដែលមិនទាន់អនុវត្ត។
7. សំរបសំរួលការប្រជុំរវាង ក្រុមប្រឹក្សាឃុំ មន្ទីរកសិកម្ម មន្ទីរបរិស្ថាន ជាមួយកសិករចំនួន៥០នាក់/គ្រួសារ (ស្ត្រី២៥) ដែលទស្សនកិច្ចសិក្សា និង ការតំរង់ទិសពីកសិករដែលអំពីអនុវត្តន៍ក្បេត្របរិស្ថាន បែប ច្នៃប្រឌិតឆ្លាតវៃតាមលក្ខ័ណ្ឌ អាកាសធាតុ (CSA) និង កសិកម្មបែបអភិរក្ស (CA) សំរាប់ស្វែងរកការគាំទ្រជាហិរញ្ញវត្ថុ និង បច្ចេកទេសសំរាប់អនុវត្ត (ក្នុងករណីគម្រោង មិនអាចរ៉ាប់រងថវិកាទាំងអស់យើងនឹងរើសតែតំណាងកសិករតាម លទ្ធភាពថវិកា ដែលគម្រោងមានប៉ុណ្ណោះ)។
8. ពិនិត្យតាមដាន និង វាយតំលៃ និង ផលិតករណីសិក្សា សំរាប់កសិករដែលអនុវត្តក្បេត្រ បរិស្ថាន បែបច្នៃប្រឌិតឆ្លាតវៃតាមលក្ខខណ្ឌអាកាសធាតុ (CSA) និង កសិកម្មបែបអភិរក្ស (CA) ដោយខ្លួនឯង ឬគាំទ្រ ដោយស្ថាប័នផ្សេងក្រៅពីគំរោង។
9. ប្រជុំពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ អង្គភាព ឧទ្យានុរក្ស មន្ទីរបរិស្ថានខេត្ត ប្រជាជនមូលដ្ឋាន អំពីគោលបំណងដើម្បីធ្វើ ការការពារ និង ការដាំស្តារឡើងវិញនៅតំបន់ក្បាលជប់សំខាន់ៗនៅលើខ្នងភ្នំ។
10. សំរបសំរួលដាំដើមឈើប្រណិតចំនួន ២០០០ ដើមជាព្រំធម្មជាតិជុំវិញ និង ក្នុងតំបន់ ទឹកជប់ទាំង៨(ដាំនៅដើមរដូវភ្លៀង)។
11. ពិភាក្សាជាមួយឧទ្យានុរក្ស ក្រុមប្រឹក្សាឃុំ អាជ្ញាធរ អប្សរា រកទីតាំងដែលឈើអាចលូតលាស់បានសំរាប់ដាំកូនឈើ ប្រណិត (រួមទាំងគូលែនព្រៃ)។
12. ប្រជុំជាមួយក្រុមប្រឹក្សាឃុំ គណៈកម្មការសហគមន៍ និង ប្រជាជនក្នុងការចូលរួមថែទាំកូនឈើដែលដាំហើយ និង ដាំជួសកូនឈើណាដែលងាប់។
13. ពិនិត្យតាមដាន និង វាយតំលៃ និង ផលិតករណីសិក្សា។
14. សំរបសំរួលបោះបង្គោលព្រំបេតុងសំគាល់តបន់ក្បាល ទឹកជប់ដោយមានការចូលរួម។
15. បិទផ្សាយលទ្ធផល និង ផ្ទៀងផ្ទាត់លទ្ធផលមុនពេល មានការរៀបចំប្រគល់ផ្លូវការ។
16. សំរបសំរួល និង រៀបចំកម្មវិធីប្រគល់ និង ទទួល ដីក្នុងតំបន់ទឹកជប់ពីប្រជាសហគមន៍ និង លិខិតពាក់ព័ន្ធនិងដីធ្លី។
17. ពង្រឹងលើការទទួលខុសត្រូវរបស់គណៈកម្មការ តួនាទី ភារកិច្ច បទបញ្ជាផ្ទៃក្នុងលក្ខន្តិកៈ របស់ព្រៃតំបន់ការពារទាំង៥។
18. ធ្វើការកសាងសមត្ថភាពគណៈកម្មកា CPAs ទាំង៥ តំបន់ព្រៃការពារ ស្មើ៣៥នាក់ ស្តីពី ការគ្រប់គ្រងប្រើប្រាស់តំបន់ក្បាលជប់ ប្រកបដោយនិរន្តភាព ការរៀបចំស្តារឡើងវិញ និង ការអនុវត្តតាមបែប កសិកម្មវៃឆ្លាត។
19. រៀបចំវគ្គបណ្តុះបណ្តាលដល់គណៈកម្មការគ្រប់គ្រងតំបន់ក្បាលទឹកជប់ និងគណៈកម្មការតំបន់ព្រៃការពារពី ការគ្រប់គ្រង ដឹកនាំ ចាត់ចែងក្នុងសហគមន៍ការប្រើប្រាស់ផល និង អនុផលព្រៃឈើប្រកបដោយនិរន្តភាព។

20. ពង្រឹងកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធការធ្វើផែន ការល្បាតជាប្រចាំរបស់សហគមន៍តំបន់ព្រៃការពារ និង ការស្តារឡើងវិញ ទាំងតំបន់ក្បាលទឹកជប់ និង តំបន់ព្រៃការពារ។
21. សម្របសម្រួលជាមួយគណៈកម្មកាទាំងអស់ និង ប្រជាពលរដ្ឋធ្វើការត្រួតពិនិត្យ តាមដាន និង វាយតំលៃរាល់សកម្មភាពនៃលទ្ធផលការស្តាឡើងវិញទាំងតំបន់ក្បាលទឹកជប់ និងសហគមន៍តំបន់ព្រៃការពារ។
22. ចងក្រងករណីសិក្សាចំនួន ៨ និងបង្កើតទំព័រ facebook ចងក្រងខ្សែវីដេអូឯកសារស្តីពី ភាពជោគជ័យរបស់គម្រោង។
23. សហការជាមួយអង្គការ OOO និង ANKOរៀបចំប្រជុំ ប្រចាំត្រីមាសរួមគ្នា ដើម្បីចែករំលែកបទពិសោធន៍ និងមេរៀននានា ពីការ អនុវត្តគម្រោង (៤ ដងក្នុងមួយឆ្នាំ)។
24. ចុះត្រួតពិនិត្យតាមដាន និង វាយតំលៃអំពីប្រសិទ្ធភាព ការអនុវត្ត និង លទ្ធផល។
25. ការត្រួតពិនិត្យ និង វាយតម្លៃពីខាងក្រៅនៅចុងបញ្ចប់គម្រោង។
26. ការតាមដានត្រួតពិនិត្យ វាយតម្លៃផ្ទៃក្នុង និង ប្រជុំប្រចាំ ត្រីមាសអំពីវឌ្ឍនភាពគម្រោង។

<u>ខេត្តឧត្តរមានជ័យ</u>

**លទ្ធផល.1:សមាជិកសហគមន៍ព្រៃឈើទាំងបីសហគមន៍សរុប៣,២២៦នាក់ស្ត្រី/១,៥៥៥នាក់ និងបណ្តាញសហគមន៍ព្រៃឈើ ទាំង១៣ ធ្វើការគ្រប់គ្រង ថែរក្សានិងដកហូតធនធានពីព្រៃសហគមន៍ប្រកបដោយនិរន្តរភាព។**

1.1. សហការជាមួយអាជ្ញធរ និងរដ្ឋបាលព្រៃឈើ និងមានការចូលរួមពីយុវជនដើម្បី ទុបស្កាត់បទល្មើសក្នុងព្រៃឈើសហគមន៍។
1.2. ប្រជុំបណ្តាញសហគមន៍ ថ្នាក់ខេត្ត មន្ទីរកសិកម្ម រដ្ឋបាលព្រៃឈើ និងអាជ្ញាធរមូលដ្ឋាន។
1.3. គាំទ្រសកម្មភាពបណ្តាញក្នុងការដោះស្រាយបទល្មើសព្រៃឈើ និងដីព្រៃសហគមន៍ សរសេររបាយការណ៍ ជួយសម្របសម្រួលសហគមន៍ផ្សេងៗទៀតទាំង១៣។
1.4. ជួបជាមួយ ឃុំ ស្រុក ខេត្ត មន្ទីរកសិកម្ម ក្រសួងកសិកម្ម ក្នុងការដោះស្រាយ បញ្ហាទាក់ទងសហគមន៍ ព្រៃឈើ និងដីព្រៃសហកមន៍ទាំង១៣។
1.5. ចូលរួមវាទិកាសាធារណៈថ្នាក់ ឃុំ ស្រុក ខេត្ត។
1.6. ដឹកប្រឡាយបង្គោលព្រំប្រទល់ព្រៃសហគមន៍នៅសហគមន៍ព្រៃឈើទាំងបី(ភ្នំដងរ៉ែកសម្រែកព្រៃស្រស់ និងរតនរុក្ខា)
1.7. ដាក់ផ្ទាំងផែនទីសហគមន៍ព្រៃឈើតាមសាលាឃុំ និងទីតាំងសហគមន៍ព្រៃឈើ
1.8. គៀងគរសមាជិកសហគមន៍ក្នុងការដាំដំណាំយុទ្ធសាស្ត្រគ្រាប់ត្នោត និងឫស្សីក្នុងការ ការពារ ព្រំប្រទល់ព្រៃសហគមន៍។
1.9. គណៈកម្មការសហគមន៍ព្រៃឈើចូរួមប្រជុំជាមួយអាជ្ញាធរភូមិ ឃុំ ប្រចាំខែនៅសលាឃុំ/សង្កាត់
1.10. ចូលរួមធ្វើផែនការវិនិយោគប្រចាំឆ្នាំ
1.11. ធ្វើថ្នាលបណ្តុះកូនឈើ២សហគមន៍
1.12. វេទិការជួបជុំរំតែចំណាងសាមគ្គីរវាងអង្គការកែប្រែសហគមន៍ ក្រុមបណ្តាញសហគមន៍ក្នុងតំបន់គោលដៅ និង អាជ្ញាធរ ឃុំ ស្រុក ខេត្ត បូកសុរបសមទ្ធិផលជោគជ័យប្រចាំឆ្នាំ

**លទ្ធផលទី២៖ កសិករក្រីក្រចំនួន៩៣២គ្រួសារ នឹងអាចមានជីវភាពរស់ នៅប្រសើរឡើងដើម្បីអាចធានា កាសិក្សារបស់កូនៗអោយបានយ៉ាងទាបថ្នាក់ទី៩តាមរយៈការគ្រប់គ្រងក្រុមសន្សំ ២១ក្រុម និងធនាគា ស្រូវចំនួន៨ក្រុម ដែលមានការសហការណ៍ជាមួយក្រុមប្រឹក្សាឃុំ សំរោង បន្សាយរាក់ កូនក្រៀល និងគោកខ្ពស់។**

2.1. វគ្គបណ្តុះបណ្តាលការចុះបញ្ជីស្នាមគណៈកម្មការសន្សំ និងធនាគារស្រូវដល់គណៈកម្មការថ្មី
2.2. តំណាងក្រុមប្រឹក្សាឃុំ និងតំណាងគណៈកម្មកាថ្នាក់ឃុំសហគមន៍បង្ហាត់បង្ហាញបន្ថែមជាប្រចាំ និងធ្វើការ តាមដានឆ្លុះបញ្ចាំងដល់គណៈកម្មការក្រុមសន្សំ21ធនាគារស្រូវ8ក្រុម២ខែ ម្តង។

2.3. ប្រជុំឆ្លុះបញ្ចាំង១ឆ្នាំម្តង(ក្រុមសន្សំ២១ និងធនាគារស្រូវ ៨ និងកសិករគំរូ

2.4. ប្រជុំបណ្តាញសន្តិសុខស្បៀងថ្នាក់ជាតិ១ដង

**លទ្ធផលទី៣៖កុមារចំនួន ៦៦០នាក់/កុមារី៣៨៣នាក់ ស្ថិតនៅ ឃុំ សំរោង បន្សាយរាក់និងគោក ខ្ពស់មានការចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសហគមន៍ តាមរយៈ ការគូរសារ កម្មវិធីសប្បាយៗ ក្លឹបកុមារ និងការ លើក កំពស់សិទ្ធិក្នុងសាលារៀន។**

3.1. សកម្មភាពគូសារ អប់រំទូទៅតាមសាលារៀន (ថែមកុមារ៣០០នាក់ថ្មី)

3.2. ប្រជុំគ្រូស្មគ្រ័ចិត្តចំនួន២៦នាក់រៀងរាល់6ខែម្តង

3.3. សម្ភារៈគូសារកុមារ

3.4. កម្មវិធីថតរូបកុមារ(Uploud)

3.5. កម្មវិធីសប្បាយនៅតាមភូមិ

3.6. រៀបចំកម្មវិធីសិក្សាបន្ថែមជាមួយក្លិបកុមារទាំងពីរដែលទើបសាងសង់រួច

3.7. ពង្រឹងពីការតាមដានការបង្រៀន និងរៀនតាមសាលារៀន និងការជួយចូលរួមថែរក្សា និងអនាម័យសាលារៀន

3.8. គណៈកម្មការទ្រទ្រង់សាលាថ្នាក់ឃុំ ធ្វើការជាមួយគកសកក្នុងការជួយដល់កុមារតាមសាលារៀន ក្នុងការផ្សព្វផ្សាយពី PRS សិទ្ធិកុមារ សិទ្ធិស្ត្រី អំពើហឹង្សា គ្រោះថ្នាក់ពេលធ្វើចំណាកស្រុក។

3.9. ចងក្រងរបាយការណ៍PRSថ្នាក់ជាតិដើម្បីតស៊ូមតិ(MPC,CWDCC,CTO,COFAP,RFCD)

**លទ្ធផលទី៤៖CTOជាស្ថាប័នដែលមានគណនេយ្យភាព និងតម្លាភាពចំពោះម្ចាស់ជំនួយ និងអ្នកទទួលផល។**

4.1 ការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ(ខែវិច្ឆិការ)

4.2 ត្រួតពិនិត្យនិងឆ្លុះបញ្ចាំងការអនុវត្តសកម្មភាពប្រចាំត្រីមាស (comprehensive monitoring)

4.3 រៀបចំ និងត្រួតពិនិត្យផែនការឆ្នាំ ២០១៩

4.4 . ចូលរួមសិក្ខាសាលាភាពជាដៃគូរប្រចាំឆ្នាំ

4.5 . ការចូលរួមនិងប្រជុំជាមួយបណ្តាញផ្សេងៗ AAC, NEP, WGPD, CHF, NGO forum and AAC-partnership

សៀមរាបថ្ងៃទី............ខែ..................... ឆ្នាំ២០១៨

**រៀបចំរបាយការណ៍ដោយ**

បានឃើញនិងពិនិត្យ

**ប្រធានក្រុមប្រឹក្សាភិបាល**

...............................